១២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៤១ ខែ ធ្នូ

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-

១២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ


| អត្ថបទ | ទំព័រ |
| --- | --- |
| **ផ្នែកសាសនា** | |
| ១– រូប ជីវតិ មជ្ឈាន់ តាមគោត្ត ន ជីវតិ សហ.ផេង-ស្រីវ រៀបរៀង | ១២៦៣ |
| ២– រឿងសុមនសាមណេរ លោក ប៊ូ-ប៊ូ រៀបរៀង . . . . | ១២៦៧ |
| **ផ្នែកអក្សរសាស្ត្រ** | |
| ៣– វចនានុក្រមសំស្ក្រឹតខ្មែរ ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . | ១២៩២ |
| ៤– រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែរៀបរៀង . . . . | ១២៩៦ |
| ៥– ឯកសារ : សត្វចិញ្ចឹម សហ. ចាប-រិត រៀបរៀង . . . | ១៣១៤ |
| ៦– រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ អ្នកស្រីពេជ-សល់ ប្រែរៀបរៀង. . | ១៣៤២ |
| ៧– ប្រវត្តិគ្រូក្មេង នៅកំពង់ចាម អ្នកស្រី ពេជ-សល់ រៀបរៀង . . | ១៣៥៩ |
| **ផ្នែកកំណត់-ប្រវត្តិការណ៍** | |
| ៨– ព្រះសង្ឃដីកា នៃសម្ដេចព្រះមហាសុមេធាធិបតីស្ដីពីការរួបរួមសាមគ្គី . | ១៣៦៧ |
| ៩– បុគ្គលិកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ចូលក្រាបបង្គំគាល់ព្រះបរមសព នៃសម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ ជួត-ណាត . . . | ១៣៧៥ |
| ១០– បញ្ជីអត្ថបទដែលបានចុះផ្សាយក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៦៩ . . | ១៣៨៧ |

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ។

**ផ្នែកសាសនា**

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណែមក ឲ្យធ្វើល្អទៅ,
ឲ្យដុសខាត់ចិត្ត កុំឲ្យហ្មងសៅ
បីនេះលោកហៅ ពុទ្ធសាសនា "

ក ព

# វិចារណកថា

## សេចក្តីអត្ថាធិប្បាយព្រះពុទ្ធភាសិត

### រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ

លោក ដេង - ស្រីវ រៀបរៀង

---

*សម្តេចព្រះសង្ឃរាជជោតញ្ញាណោ ជួន-ណាត ជាទីគោរពសក្ការៈ របស់យើង ដែលព្រះអង្គទើបតែយាងចូលទិវង្គត ដ៏ជាទីសោកស្តាយនោះ ព្រះអង្គទ្រង់មានព្រះចំណារមួយ លើកម្រងអត្ថបទជាច្រើនដែលទ្រង់ប្រគល់ឲ្យទៅទស្សនាវដ្តីពុទ្ធចក្រ សម្រាប់បោះពុម្ពនោះ មានពុទ្ធភាសិតមួយឃ្លាថា "រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ" ហើយព្រះអង្គទ្រង់បាននិពន្ធបន្ថែម ជាពាក្យកាព្យថា ៖*

*រីរូបនៃសព្វសត្វ តែងវិបត្តិចាស់ជរា*
*ឯនាមនិងគោត្តា ឥតជរាដូចរូបឡើយ ។*

សូន្យបាត់តែរូបទៅ　　កេរ្តិ៍ឈ្មោះនៅជិតបង្កើយ
បើគេមិនគោះតើយ　　គេអាចស្គាល់យូរអង្វែង ។

ព្រះឱវាទនៃព្រះពុទ្ធបរមគ្រូ ដែលសម្តេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់លើកយកមកទូន្មាន ចុះក្នុងកថាខណ្ឌចុងក្រោយនៃព្រះរាជបណ្តាំ របស់ព្រះអង្គនោះ មានអត្ថន័យដ៏ជ្រាលជ្រៅ យ៉ាងទូលំទូលាយពន់ពេកណាស់ ចំពោះមនុស្សទាំងឡាយ ពិសេស ចំពោះជនជាតិខ្មែរ ជាពុទ្ធសាសនិកយើងនេះ ។

ដូច្នេះ យើងសូមធ្វើអត្ថាធិប្បាយ ដោយសង្ខេប នូវព្រះពុទ្ធភាសិតនេះ ដើម្បីជាសណ្តាប់ នៃពុទ្ធបរិស័ទទាំងឡាយ ដូចតទៅ :

“ រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ ” ប្រែថា :

រូបកាយនៃសព្វសត្វទាំងឡាយ រមែងតែជួបប្រទះនូវភាពគ្រាំគ្រា និងចាស់ជរាជានិច្ច ដោយហេតុក្តៅនឹងធាតុត្រជាក់ ប្រកែកពុំបានឡើយ ហើយរមែងដល់ភាពសោះសូន្យ ក្នុងទីបរំសាន គ្មានសត្វលោកណាម្នាក់ អាចជៀសផុតបានទាល់តែសោះ គឺថារូបកាយសត្វលោក បើកាលណាវិញ្ញាណនិងភ្លើងធាតុថយចេញផុតហើយ តែងតែដេកនៅលើផែនដី ដូចអង្កត់ឧសរកប្រយោជន៍គ្មាន ព្រមទាំងគ្មាននរណានឹកនាឡើយ មានតែនាមនិងគោត្រប៉ុណ្ណោះទេ ដែលមិនចេះគ្រាំគ្រាមិនចេះចាស់ និងមិនសាបសូន្យ ។ ចំណុច ព្រះបច្ឆិមវាចា នៃសម្តេចព្រះសង្ឃរាជ

ជាអម្ចាស់នេះ សឲ្យឃើញនូវទឹកព្រះរាជហឫទ័យប្រកបដោយធម៌មេត្តា
ករុណារបស់ព្រះអង្គ មុននិងទ្រង់សោយព្រះទិវង្គត ចំពោះពុទ្ធបរិស័ទ
ជាជនជាតិខ្មែរយើងទាំងឡាយជាកូនចៅព្រះអង្គក្នុងកម្ពុជរដ្ឋ ក្រែងពុំបាន
យល់ច្បាស់នូវរឿងនេះ ហើយបេះតែបណ្តែតបណ្តោយអាត្មាឲ្យប្រព្រឹត្ត
ទៅតាមយថាកម្ម ៗ ព្រះអង្គទ្រង់មានព្រះបំណងក្នុងគ្រាអវសាន ចង់
ប្រៀនប្រដៅពុទ្ធបរិស័ទទាំងឡាយឲ្យយល់ច្បាស់ថា គួរគប្បីណែនាំគ្នា
ខំប្រឹងកសាងកុសលឬកិច្ចកសាងអ្វីជាប្រយោជន៍មនុស្សផងគ្នា កុំបីធ្វេស
ប្រហែសឲ្យសោះ ព្រោះតែកាលណារូបរាងកាយយើងរលត់គ្នា ត្រូវ
សេចក្តីស្លាប់គ្របសង្កត់ ហើយរូបកាយនេះ ត្រូវគេនាំយកទៅបោះបង់
ចោល ឬកប់ចោល ឬក៏យកទៅបូជាក្នុងទីសមសានជាអសារបង់ គ្មាន
សំណល់អ្វីជាការណ៍មានប្រយោជន៍ឡើយ គឺនៅសល់តែនាមនិងគោត្រ
ឬកេរ្តិ៍ឈ្មោះប៉ុណ្ណោះទេ ដែលមិនបាត់ទៅណា ៗ កេរ្តិ៍ឈ្មោះនេះរមែងឋិត
នៅជាប់ក្នុងដួងវិញ្ញាណនៃបច្ឆាជនជាធម្មតា កេរ្តិ៍ឈ្មោះនោះបើល្អក្តី ឬ
អាក្រក់ក្តីមិនបាត់ទៅណាឡើយ អ្នកមានកេរ្តិ៍ឈ្មោះល្អរមែងធ្វើឲ្យគេពោល
សរសើរ ឲ្យគេបេះតែនឹករលឹក ឲ្យគេស្តាយស្រណោះគ្មានឈប់ អ្នក
មានកេរ្តិ៍ឈ្មោះអាក្រក់រមែងធ្វើឲ្យគេស្អប់ខ្ពើម ឲ្យគេប្រទេចផ្តាសា មិនតែ
ប៉ុណ្ណោះសោតថែមទាំងធ្វើឲ្យកូនចៅរបស់ខ្លួន ត្រូវទទួលការអាម៉ាស់មុខ
ការអៀនខ្មាសដោយសារផង ៗ គុណសម្បត្តិនិងគុណវិបត្តិទាំងពីរបែប

នេះ ស្រេចលើយើងជាអ្នកជ្រើសយកចុះ តែព្រះរាជហឫទ័យនៃសម្តេចសង្ឃរាជជាអម្ចាស់ ទ្រង់ប្រាថ្នាឲ្យយើងជ្រើសយកគុណសម្បត្តិហើយ ។

ដូច្នេះ គួរយើងទាំងឡាយចំរៀវចាកអំពីពុករលួយ ទាំងប្រាំប្រការ ឲ្យជ្រះស្រឡះចេញពីខ្លួនសន្តាន នោះកេរ្តិ៍ឈ្មោះរបស់យើងនឹងបិតនៅក្រអូបប្រាសខ្យល់រវាំងបជ្ជាជនទាំងឡាយ បើពុំដូច្នោះទេ រូបកាយស្លាប់បាត់បង់ទៅ យើងថែរជាទុកកេរ្តិ៍អសោច ឲ្យកូនចៅនៅឯក្រោយមិនខានឡើយ ។

នេះហើយជាចំណុចសំខាន់បំផុត ខាងមានព្រះរាជហឫទ័យប្រកបដោយព្រហ្មវិហារធម៌នៃសម្តេចព្រះសង្ឃរាជជាអម្ចាស់ មកលើយើងគ្រប់គ្នាជាសិស្សគណ ជាពុទ្ធបរិស័ទ ពិសេសជនជាតិខ្មែរទាំងមូល ក្នុងកម្ពុជរដ្ឋនេះឯង ។ បំណាច់មានភ័ព្វវាសនា បានកើតមកជាមនុស្សម្តង កាលបាត់បង់ជីវិតទៅ ត្រូវឲ្យមានស្នាដៃអ្វីមួយ ទុកជាប្រយោជន៍នៃបជ្ជាជន យ៉ាងហោចណាស់ក៏ឲ្យមានឈ្មោះល្អ ទុកជាតម្រាប់ ឬ ជាគ្រូនៃកូនចៅ ព្រមទាំងជនរួមជាតិផងកុំខាន កុំឲ្យគេពោលថាថារស់នៅគ្រាន់តែទម្ងន់ផែនដីនោះ ។

# រឿងសុមនសាមណេរ

## អដ្ឋកថាធម្មបទ ភិក្ខុវគ្គទី ២៥ ភាគទី ៨

ព្រះមហាឡ៊ូ ឡ៉ូ រៀបរៀង

កាលព្រះបរមសាស្តាគង់ក្នុងបុព្វារាម ទ្រង់ប្រារព្ធនឹង សុមនសា-មណេរ សម្តែងធម៌ដោយបទគាថា ថា យោ ហវេ ដូច្នេះជាដើម ។

អនុបុព្វីកថា ក្នុងរឿងនេះ ដូចតទៅ ៖

សេចក្តីពិស្តារថា កាលគ្រាសាសនានៃព្រះពុទ្ធព្រះនាមថា បទុ-មុត្តរៈ មានកុលបុត្រម្នាក់ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូបទុកក្នុងតំណែង ជាអ្នកប្រសើរលើសជាងភិក្ខុបណ្តាដែលបានទិព្វចក្ខុ ក៏ប្រាថ្នាឲ្យបានទិព្វចក្ខុនោះ ទើបនិមន្តព្រះសាស្តាថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធាន អស់ ៧ ថ្ងៃ តាំងសេចក្តីប្រាថ្នាទុកថា បពិត្រព្រះអង្គដ៏ចម្រើន ! សូមឲ្យខ្ញុំព្រះអង្គ បានជាអ្នកកំពូលប្រសើរជាងភិក្ខុបណ្តាដែលបានទិព្វចក្ខុក្នុងសាសនានៃព្រះពុទ្ធមួយព្រះអង្គ ។ ព្រះសាស្តាទ្រង់ពិចារ-ណាមើលទៅមុខ រហូតមួយសែនកប្ប ទ្រង់ជ្រាបថា សេចក្តីប្រាថ្នារបស់គេនឹងបានសម្រេច ទើបទ្រង់ព្យាករថា ក្នុងទីបំផុតនៃសែនកប្ប តាំងអំពីនេះទៅ អ្នកនឹងបានជាព្រះ អនុរុទ្ធត្ថេរ ជាកំពូលប្រសើរជាងភិក្ខុបណ្តាដែលបានទិព្វចក្ខុក្នុងសាសនានៃព្រះពុទ្ធព្រះនាមថា គោតម ។ កុលបុត្រ

បានព្យាករណ៍នោះ នឹកសម្គាល់សម្បត្តិនោះថា ហាក់ដូចជាខ្លួននឹងបានសម្រេចក្នុងថ្ងៃស្អែក ។ លុះព្រះសាស្តាបរិនិព្វានទៅ កុលបុត្រនោះសួរភិក្ខុអ្នកបរិកម្មទិព្វចក្ខុទាំងឡាយ ហើយកសាងគោមជាច្រើនពាន់ ព័ទ្ធជុំវិញព្រះស្តូបមាសចម្ងាយរយៈផ្លូវ៧ យោជន៍ ឲ្យយកគោមនោះបូជា, លុះច្យុតចាកភពនោះ ហើយបានទៅកើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវតានិងមនុស្សអស់មួយសែនកប្ប ហើយទៅកើតក្នុងត្រកូលអ្នកកម្សត់ទុគ៌តក្នុងនគរពារាណសី ទីពឹងអាស្រ័យនឹង សុមនសេដ្ឋី ជាអ្នកទទួលប្រតដឹកនាំស្មៅឲ្យសេដ្ឋីនោះចិញ្ចឹមជីវិត ។ បុរសនេះមាននាមប្រាកដថា អន្នភារៈ ។ ឯលោកសុមនសេដ្ឋីបានថ្វាយទានធំៗ ក្នុងនគរនោះជានិច្ចកាល ។ បំណាលក្រោយមក ថ្ងៃមួយ ព្រះឧបរិដ្ឋបច្ចេកពុទ្ធចេញចាកសមាបត្តិនៅភ្នំគន្ធមាទន៍ត្រិះរិះថា ថ្ងៃនេះអាត្មានឹងអនុគ្រោះដល់អ្នកណាហ្ន៎! ទើបបានជ្រាបថា ថ្ងៃនេះ អាត្មាអញគួរនឹងអនុគ្រោះដល់អន្នភារបុរស ដ្បិតឥឡូវនេះ គេកំពុងតែដញ្ជូនស្មៅចេញពីព្រៃមកផ្ទះ, គិតស្រេច ក៏កាន់បាត្រនិងចីវរ ហោះមកដោយឫទ្ធិ ប្រាកដចំពោះមុខអន្នភារបុរស ។ ឃើញលោកកាន់បាត្រមកទទេគ្មានបាយដូច្នោះ ក៏សួរថា "លោកម្ចាស់! បានភិក្ខាហារខ្លះហើយឬនៅ?" កាលលោកឆ្លើយថា "នឹងបាន អ្នកមានបុណ្យច្រើន!" ទើបទូលថា "បើដូច្នោះសូមលោកម្ចាស់មេត្តាប្រោសសត្វរង់ចាំបន្តិចសិន" ដាក់ចោលបាច់ស្មៅហើយ

ប្រញាប់ទៅផ្ទះសួរភរិយាថា "នាង ! អាហារជាចំណែកដែលចាប់ទុកឲ្យយើង មានដែរឬទេ?" កាលបានឮនាងភរិយាឆ្លើយថា "មាន" ក៏ប្រញាប់មកទទួលយកបាត្ររបស់ ព្រះបច្ចេកពុទ្ធទៅ គិតថា "កាលអញប្រាថ្នាទឹងឲ្យទាន គ្មានទេយ្យធម៌ គឺតែសម្រាប់ឲ្យទាន, កាលមានទេយ្យធម៌ហើយ, គ្មានលោកអ្នកទទួលទាន, ប៉ុន្តែ មកដល់ថ្ងៃនេះ លោកអ្នកទទួលទាន ក៏អញបានជួប, ទាំងទេយ្យធម៌ក៏មាន, នេះ ជាលាភរបស់អញប្រសើរណាស់" គិតហើយ ទៅដល់ផ្ទះ យកអាហារដាក់ចុះក្នុងបាត្រហើយនាំត្រឡប់មកប្រគេនព្រះ បច្ចេកពុទ្ធវិញ រួចតាំងសេចក្តីប្រាថ្នាទុកថា "ដោយការឲ្យទាននេះ,សេចក្តីទលក្រ សូមកុំឲ្យកើតមានដល់ខ្ញុំឡើយ, សូម្បីតែពាក្យថា "គ្មាន" ក៏សូមកុំឲ្យមានដល់ខ្ញុំគ្រប់ ៗ ភពរៀងទៅ, បពិត្រលោកម្ចាស់ ! សូមឲ្យខ្ញុំរួចផុតអំពីការចិញ្ចឹមជីវិតដោយទលក្រលំបាកយ៉ាងនេះ, សូម្បីតែបទថា "គ្មាន" ក៏សូមកុំឲ្យខ្ញុំបានឮសោះឡើយ" ។ ព្រះ បច្ចេកពុទ្ធ ធ្វើការអនុមោទនាថា ចូរឲ្យបានផលសម្រេចតាមប្រាថ្នានោះចុះ, ម្នាលអ្នកមានបុណ្យធំ" ! រួចលោកនិមន្តចេញទៅ ។ ចំណែកទេវតាដែលបិតនៅក្នុងឆត្រ (សម្រាប់យស) របស់លោកសុមនសេដ្ឋី ក៏ឲ្យសាធុការដល់បីដងថា :

គួរឲ្យរីកពយចិត្តពេកណាស់ ! ទានដ៏ជាកំពូល ដែល អន្នភារបុរសថ្វាយហើយដល់ព្រះ ឧបរិដ្ឋ ដូច្នេះ ។ ខណៈនោះ សេដ្ឋីសួរ

ថា "យើងថ្វាយទានអស់វេលាប៉ុណ្ណេះឆ្នាំ អ្នកមិនឃើញទេឬ ?" ទេវតាឆ្លើយថា "ខ្ញុំមិនឲ្យសាធុការព្រោះវត្ថុទានរបស់លោកទេ !, ក៏សាធុការនេះខ្ញុំបន្លឺឡើង ព្រោះជ្រះថ្លានឹងបិណ្ឌបាតទាន ដែលអន្នការបុរស ថ្វាយដល់ព្រះឧបរិដ្ឋ" ។ សេដ្ឋីគិតថា គួរឲ្យអស្ចារ្យណាស់ ! អញថ្វាយទានអស់វេលាដល់ប៉ុណ្ណេះឆ្នាំ មិនអាចនឹងញ៉ាំងទេវតាឲ្យសាធុការបាន, ឯអន្នការបុរសអាស្រ័យទីពឹងអញចិញ្ចឹមជីវិត ធ្វើឲ្យទេវតាឲ្យសាធុការបាន ព្រោះបិណ្ឌបាតទានតែមួយប៉ុណ្ណោះ, អញត្រូវតែធ្វើទ្រព្យឲ្យល្មមសមគួរក្នុងទាននោះ យកបិណ្ឌបាតទាននោះមកជារបស់អញវិញ, ទើបប្រើបម្រើឲ្យហៅអន្នការបុរស មកសួរថា "ថ្ងៃនេះ តើឯងបានឲ្យអ្វីទៅអ្នកណាខ្លះ ?", អន្នការបុរសឆ្លើយថា "ទានព្រោស ! ថ្ងៃនេះ ខ្ញុំបាទបានថ្វាយអាហារដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ" ។ សេដ្ឋីប្រាប់ថា "ណ្ហើយចុះ ! ឯងយកកហាបណៈ(១)នេះទៅ ហើយឲ្យចូរបិណ្ឌបាតនោះមកយើង" ។ អន្នការបុរសឆ្លើយថា "ជូនមិនបានទេ ទានព្រោស !" ។ សេដ្ឋីបន្ថែមប្រាក់ឡើងដល់មួយពាន់រៀល ។ សូម្បីសេដ្ឋីឲ្យប្រាក់ឡើងដល់មួយពាន់រៀល ក៏នៅតែអន្នការបុរសមិនព្រមឲ្យបិណ្ឌបាតនោះដែរ ។ ខណៈនោះ សេដ្ឋីនិយាយទៀតថា "ណ្ហើយចុះ ! បើឯងមិនឲ្យបិណ្ឌបាតទេ ក៏ត្រូវយកប្រាក់មួយពាន់រៀលនេះទៅចុះ ហើយចូរឲ្យចំណែក

---

១- គឺមួយរៀល ។

បុណ្យខ្លះមកយើង ។ បុរសនោះឆ្លើយថា "ចាំខ្ញុំបាទរត់ទៅសួរលោកសិន រួចនឹងមកជម្រាបវិញ" ថាហើយក៏ រត់យ៉ាងលឿន ទៅតាមព្រះបច្ចេកពុទ្ធ "ទាន់ហើយទូលសួរថា ពានព្រោស! លោកសុមនសេដ្ឋី ឲ្យប្រាក់ខ្ញុំមួយពាន់រៀល ហើយសូមយកចំណែកបុណ្យខ្លះក្នុងបិណ្ឌបាតរបស់ព្រះគុណម្ចាស់, ដូច្នេះ តើនឹងឲ្យខ្ញុំធ្វើដូចម្ដេច ព្រះករុណា ? ។

ខណៈនោះ ព្រះបច្ចេកពុទ្ធ បានពន្យល់ដោយៈប្រៀបធៀបឲ្យអ្នកការបុរសនោះស្ដាប់ថា "ម្នាល បណ្ឌិត! បបរមួយបាយក្ដី បាយមួយវែកក្ដី ដែលអ្នកបានឲ្យទានរួចហើយ, កាលបើអ្នកចែកចំណែកបុណ្យក្នុងបបរឬបាយនោះទៅឲ្យអ្នកឯទៀតហើយ, បបរឬបាយមួយវែកនោះ រឹតតែចម្រើនទ្វេច្រើនភាគឡើងទៀត, បើឲ្យគេចំនួនប៉ុន្មានភាគ ក៏ចម្រើនឡើងចំនួនប៉ុណ្ណោះភាគដែរ, ឯអ្នកឯងឲ្យបិណ្ឌបាតត្រឹមតែមួយចំណែកដល់អាត្មា, កាលបើអ្នកចែកចំណែកបុណ្យក្នុងទាននេះទៅឲ្យលោក សុមនសេដ្ឋី, បិណ្ឌបាតមួយចំណែកប៉ុណ្ណោះ នឹងកើតកើនឡើងទៅដល់ពីរចំណែក គឺរបស់អ្នកឯងមួយចំណែក របស់លោកសេដ្ឋីនោះមួយចំណែក, ប្រៀបដូចប្រទីបតែមួយគេអុជទុកក្នុងផ្ទះមួយ ហើយមានអ្នកផ្ទះរាប់រយត្រកូលឯទៀតយកប្រទីបរបស់ខ្លួនមួយ ៗ ម្នាក់ មានទាំងប្រេងទាំងប្រឆេះស្រាប់ ទៅអុជចម្លងយកភ្លើងពីប្រទីបមួយ

នោះបន្តទៅទៀត ដូច្នេះ តើអ្នកយល់ថា ពន្លឺភ្លើងរបស់ប្រទីបដើមមួយនោះនៅមានដែរឬក៏អស់ ? ។

បុរសឆ្លើយថា ពន្លឺភ្លើងរបស់ប្រទីបដើមមួយនោះ រឹតតែភ្លឺខ្លាំងឡើងជាងពន្លឺមុនទៅទៀត លោកម្ចាស់ ! ។

រួច អន្នការបុរស ទូលថា "បើដូច្នោះ ជាការប្រពៃណាស់ព្រះគុណម្ចាស់ !" ថារួច ថ្វាយបង្គំលាព្រះ បច្ចេកពុទ្ធ វិលមកជម្រាបលោកសេដ្ឋីវិញថា" ទានប្រោស ! សូមលោកទទួលយកចំណែកផលបុណ្យចុះ" ។ សេដ្ឋីទទួលថា "បើដូច្នោះ អ្នកចូរទទួលយកប្រាក់ទាំងអស់នេះទៅចុះ" ។ អន្នការបុរស ប្រកែកថា "ទានប្រោស ! ខ្ញុំបាទមិនបានលក់បិណ្ឌបាតទេ, ខ្ញុំបាទសូមចែកជូនតែចំណែកផលបុណ្យប៉ុណ្ណោះដោយសទ្ធា" ។ សេដ្ឋីឆ្លើយថា "បើអ្នកឲ្យដោយសទ្ធា, ខ្ញុំសូមបូជាគុណរបស់អ្នក, ចូរយកប្រាក់ទៅចុះ, ហើយតាំងពីថ្ងៃនេះទៅ អ្នកកុំធ្វើការងារអ្វីឡើយ, ចូរសង់ផ្ទះនៅក្បែរផ្លូវចុះ, ត្រូវការរបស់អ្វីជាចាំបាច់ របស់គ្រប់មុខ អ្នកចូរមកយកអំពីខ្ញុំចុះ ។

រីឯបិណ្ឌបាត ដែលថ្វាយដល់លោកចេញពីនិរោធ រមែងបានទទួលផលក្នុងខណៈនោះ ។ ព្រោះដូច្នោះ សូម្បីព្រះរាជាបានទ្រង់ព្រះសណ្ដាប់ដំណឹងនោះហើយ ទ្រង់ត្រាស់បញ្ជាឲ្យហៅ អន្នការបុរសចូលទៅគាល់ ទ្រង់ទទួលយកចំណែកបុណ្យ ហើយប្រោសព្រះរាជទាន

សម្បត្តិជាច្រើន រួចព្រះរាជទានតំណែងសេដ្ឋី ដល់បុរសនោះទៀត ។ សេដ្ឋីថ្មីនេះ បានជាសម្លាញ់នឹងសុមនសេដ្ឋី ធ្វើបុណ្យដរាបដល់ក្ស័យជីវិត ច្យុតចាកភពនោះហើយទៅកើតក្នុងទេវលោក អន្ទោលទៅមកក្នុងទេវតានិងមនុស្ស, លុះមកដល់ពុទ្ធុប្បាទកាលនេះ បានមកចាប់បដិសន្ធិក្នុងវាំងស្តេចសក្យៈ ព្រះនាម អមិតោទនៈ, ព្រះប្រយូរញាតិបានដាក់នាមថា អនុរុទ្ធ ជាព្រះកនិដ្ឋភាតារបស់ស្តេចសក្យៈមហានាម ជាព្រះឱរសរបស់ព្រះ ចុល្លបិតា (មា) របស់ព្រះសាស្តា ជាបរមសុខ-មាលជាតិមានបុណ្យច្រើន ។

បានឮថា ថ្ងៃមួយ កាលដែលស្តេចសក្យៈទាំងប្រាំមួយអង្គ ទ្រង់ក្រសាលអង្គុញយកនំធ្វើជាខាប់ (គ្រឿងសម្គាល់នៃការចាញ់ឈ្នះ) ព្រះអង្គម្ចាស់អនុរុទ្ធ ចាញ់ ក៏ប្រើបម្រើទៅដល់ព្រះមាតា ដើម្បីត្រូវការនំ ។ ព្រះមាតាយកភាជនៈមាសខ្នាតធំដាក់នំពេញបញ្ជូនទៅឲ្យ ។ អ្នកបម្រើមកយកនំទៅដូច្នោះ ដល់បីលើក, ក្នុងលើកទីបួន ព្រះមាតាប្រាប់ទៅថា ឥឡូវនេះនំគ្មានទេ ។ ព្រះអង្គម្ចាស់អនុរុទ្ធ បានឮពាក្យប្រាប់របស់ព្រះមាតាហើយ យល់ថា ឥឡូវនេះ ប្រហែលជានឹងមាននំដែលឈ្មោះថា "គ្មាន" ព្រោះមិនធ្លាប់ឮពាក្យថា "គ្មាន" សោះ, ទើបប្រើអ្នកបម្រើថា "ចូរឯងទៅយកនំគ្មាននោះមកចុះ" ។ កាលព្រះមាតារបស់ព្រះអង្គម្ចាស់ បានឮពាក្យ ដែលអ្នកបម្រើមកទូលថា "បពិត្រព្រះនាងម្ចាស់ ! សូម

ព្រះនាងឲ្យនំគ្មានមកចុះ" ដូច្នេះហើយក៏គិតថា "បុត្ររបស់អញ មិនធ្លាប់ឮពាក្យថា"គ្មាន"ទេ, ធ្វើម្តេចហ្ន៎ អញនឹងឲ្យបុត្របានដឹងសេចក្តីដែលនំនោះគ្មាន" គិតយ៉ាងនេះហើយ ក៏លាងថាសមាសឲ្យស្អាត ហើយយកថាសមាសមួយទៀតគ្របឲ្យជិតពីលើ ហើយប្រាប់ថា "ហ៎ ! យកទៅចុះ ! ឯងចូរយកថាសនេះទៅឲ្យបុត្ររបស់អញ" ។

ខណៈនោះ ទេវតាអ្នករក្សាព្រះនគរគិតថា "ម្ចាស់របស់អញ កាលគ្រាកើតជា អន្នភារបុរស បានថ្វាយអាហារជាចំណែករបស់ខ្លួនដល់ព្រះ ឧបរិដ្ឋបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាទុកថា សូមកុំឲ្យខ្ញុំបានឮបទថា'គ្មាន' ឡើយ, ដូច្នេះ បើអញដឹងសេចក្តីនោះហើយនៅតែធ្វើព្រងើយកន្តើយ, ក្បាលរបស់អញក៏ត្រូវបែកចេញជា ៧ ភាគ" គិតរួចក៏យកនំទិព្វដាក់ក្នុងថាសទាល់តែពេញ ។ បុរសនោះនាំយកថាសមកហើយ តម្កល់ទុកក្នុងសម្នាក់របស់ព្រះអង្គម្ចាស់សក្យៈទាំងនោះ ហើយបើកគម្របឡើង ។ ក្លិនរបស់នំនោះ ធុំសាយផ្សាយទៅពេញព្រះនគរ ។ ក៏កាលដែលព្រះអង្គម្ចាស់ទាំងនោះលើកនំឡើង ដាក់ក្នុងព្រះឱស, ឯឱជារស ក៏បានជ្រួតជ្រាបទៅសព្វសរសៃសម្រាប់ទទួលរសជាតិទាំង ៧ ពាន់ ។ ព្រះអង្គម្ចាស់ អនុរុទ្ធ ទ្រង់ត្រិះរិះថា "កាលមុនពីពេលនេះ ព្រះមាតាប្រហែលជាមិនស្រឡាញ់អញទេ បានជាក្នុងវេលាមុនៗ លោកមិនដែលធ្វើនំគ្មានឲ្យអញ", ទើបទៅទូលសួរព្រះមាតាថា "ម៉ែ ! ខ្ញុំមិនជា

ទីស្រឡាញ់របស់ម៉ែទេឬ ?

ព្រះមាតាឆ្ងល់ សួរថា កូន! ឯងថាម៉េច ? ឯងជាទីស្រឡាញ់យ៉ាងក្រៃលែងរបស់ម៉ែ ជាងភ្នែកទាំងពីរ ជាងដួងហឫទ័យ ។

ព្រះអនុរុទ្ធ ឆ្លើយថា ម៉ែ! បើខ្ញុំជាទីស្រឡាញ់របស់ម៉ែ ហេតុអ្វីបានជាកាលពីដើម ម៉ែមិនដែលធ្វើនំគ្មាននេះឲ្យខ្ញុំខ្លះផង ។ ព្រះមាតាសួរអ្នកបម្រើថា នែអ្នក! ក្នុងថាសមានវត្ថុអ្វីខ្លះដែរឬ ? អ្នកបម្រើឆ្លើយថា មាន ព្រះនាង!, ថាសពេញទៅដោយនំ, នំបែបនេះ ខ្ញុំមិនដែលឃើញសោះឡើយ ។ ព្រះមាតាគិតថា បុត្ររបស់អញបានធ្វើបុណ្យទុកមក ទេវតាឃើញថាសទទេ ក៏បញ្ជូននំទិព្វទៅឲ្យ ។ ព្រះអនុរុទ្ធបាននិយាយនឹងមាតាតទៅទៀតថា ម៉ែ! នំបែបនេះ ខ្ញុំមិនដែលបានទទួលទានសោះ ចាប់ដើមតាំងតែពីថ្ងៃនេះទៅ សូមម៉ែធ្វើតែនំគ្មានម្យ៉ាងប៉ុណ្ណោះឲ្យខ្ញុំ ។ តាំងពីថ្ងៃនោះមក កាលបើព្រះ អនុរុទ្ធ និយាយថា ចង់បរិភោគនំ ព្រះមាតាក៏លាងថាសមាស ហើយយកថាសមាសមួយទៀតគ្របផ្ញើទៅឲ្យ ។ ទេវតាក៏ដាក់នំទិព្វពេញថាសនោះ ។ ព្រះអនុ-រុទ្ធ កាលនៅជាឃរាវាស មិនបានដឹងសេចក្ដីរបស់បទថា "គ្មាន" ទេ, បរិភោគតែនំទិព្វប៉ុណ្ណោះ ។ ក៏កាលដែលឱរសរបស់ស្ដេចសក្យៈនាំគ្នាចេញបួសតាមលំដាប់ត្រកូល ដើម្បីជាបរិវាររបស់ព្រះសាស្ដា, កាលស្ដេចសក្យៈមហានាមនិយាយថា កូនក្នុងត្រកូលរបស់យើង នៅពុំ

ទាំងមានអ្នកណាចេញបួសទេ, អ្នកឬខ្ញុំ គួរតែនឹងបួស ? ។ ព្រះអនុរុទ្ធ ឆ្លើយថា ខ្ញុំជាមនុស្សទន់ខ្សោយ មិនអាចនឹងបួសបានទេ ។ ស្តេចមហានាម ឆ្លើយថា បើដូច្នោះ អ្នកចូររៀនការងារចុះ, យើងនឹងទៅបួស ។ ព្រះអនុរុទ្ធ សួរថា ដែលហៅថាការងារ គឺអ្វី ? ក៏ព្រះអនុរុទ្ធ មិនបានដឹងសូម្បីតែទីកើតនៃអាហារ ( ឆ្នាំងបាយ ) ដូម្តេចនឹងទៅដឹងដល់ការងារ ? ព្រោះដូច្នោះ បានជាសួរយ៉ាងនោះ ។

ថ្ងៃមួយ ស្តេចទាំងបីអង្គគឺ អនុរុទ្ធ១ ភទ្ទិយៈ១ កិម្ពិលៈ១ ប្រឹក្សាគ្នាថា បាយកើតឡើងពីទីណា ? បណ្តាស្តេចបីអង្គនោះ ព្រះកិម្ពិលៈ ឆ្លើយឡើងថា បាយកើតឡើងក្នុងជង្រុក ។ បានឮថា ថ្ងៃមួយ ព្រះកិម្ពិលៈ បានឃើញស្រូវដែលគេជញ្ជូនដាក់ក្នុងជង្រុក, បានជានិយាយយ៉ាងនោះ ដោយសម្គាល់ថា បាយ កើតក្នុងជង្រុក ។ ខណៈនោះ ព្រះភទ្ទិយៈ ឃាត់ព្រះកិម្ពិលៈថា អ្នកមិនទាន់ដឹងទេ, បាយរមែងកើតឡើងក្នុងឆ្នាំងបាយទេតើ ។ បានឮថា ថ្ងៃមួយ ព្រះភទ្ទិយៈ បានឃើញគេដួសបាយចេញពីឆ្នាំង ទើបចូលចិត្តថា បាយកើតឡើងក្នុងឆ្នាំងនោះឯង បានជានិយាយដូច្នោះ ។ ព្រះអនុរុទ្ធនិយាយនឹងបងប្រុសទាំងពីរអង្គថា ព្រះអង្គទាំងពីរក៏នៅតែមិនទាន់ជ្រាបដែរ បាយតែងកើតឡើងក្នុងថាសមាសធំកម្ពស់មួយគក់ ។ ព្រះអនុរុទ្ធ មិនដែលបានឃើញគេបុកអង្ករដណ្តាំបាយទេ, ធ្លាប់បានឃើញតែ

បាយ ដែលគេដួសដាក់ជាសមាបតម្កល់ទុកខាងមុខខ្លួនប៉ុណ្ណោះ, ព្រោះ ដូច្នោះ បានជាសម្គាល់ថា បាយកើតឡើងក្នុងថាសមាសនោះឯង ទើបនិយាយដូច្នោះ ។ កុលបុត្រអ្នកមានបុណ្យច្រើន សូម្បីតែទីកើតបាយក៏មិនដឹង ធ្វើម្តេចនឹងដឹងការងារបាន! ។

ព្រះ អនុរុទ្ធ នោះ ដែលដឹងការងារតិចបំផុតនេះ ដោយសារបងនិយាយប្រាប់ មានន័យជាដើមថា "មកណេះ អនុរុទ្ធ ប្អូន ! យើងនឹងរៀនប្រដៅកិច្ចការរបស់អ្នកនៅគ្រប់គ្រងផ្ទះដល់អ្នក, មុនដំបូងត្រូវឲ្យភ្ជួរស្រែ" ដូច្នេះ, ព្រះ អនុរុទ្ធ ត្រិះរិះថា "ប្រយោជន៍អ្វីដល់អញដោយការគ្រប់គ្រងផ្ទះ" ទើបបង្គំលាមាតា ហើយចេញទៅជាមួយនឹងសាក្យកុមារ ប្រាំអង្គ មានព្រះ ភទ្ទិយៈ ជាប្រធាន, ចូលទៅគាល់ព្រះសាស្តានៅអនុបិយម្ពវ័ន ហើយសូមបួស ។ ព្រះអនុរុទ្ធ បួសស្រេចហើយ ជាអ្នកប្រតិបត្តិត្រូវផ្លូវ ធ្វើឲ្យជាក់ច្បាស់វិជ្ជាទាំងបី អង្គុយនៅលើអាសនៈតែមួយអាចនឹងសំឡឹងមើលលោកធាតុកប់ពាន់ ដោយទិព្វចក្ខុ ឃើញដូចជាផ្លែកន្ទួតព្រៃដែលដាក់លើបាតដៃដូច្នោះ, ទើបបានបន្លឺឧទានឡើងថា: "អញព្រេកនិវាសនៈ ខាងក្រោយបាន, ទិព្វចក្ខុអញក៏បានជម្រះហើយ, អញបានដល់សេចក្តីសម្រេចវិជ្ជាបីហើយ, ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ អញបានធ្វើតាមរួចហើយ" ដូច្នេះហើយពិចារណាមើលថា "សម្បត្តិនេះ អញបានព្រោះធ្វើអ្វីនេះ" បាន

ក្រាបថា “ព្រោះបានតាំងសេចក្តីអញប្រាថ្នា ក្នុងទីជិតព្រះបាទរបស់ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា បទុមុត្តរៈ” ហើយក្រាបតទៅទៀតថា “កាលអញត្រាច់ផ្គាត់នៅក្នុងវដ្តសង្សារ បានកើតជាបុរសឈ្មោះអន្នភារៈ ពឹងពាក់អាស្រ័យនឹងសុមនសេដ្ឋីចិញ្ចឹមជីវិត នៅក្នុងព្រះនគរពារាណសី កាលជាតិឯណោះ” ដូច្នេះ ហើយពោលថា៖

“កាលជាតិមុន ខ្ញុំកើតជាអន្នភារបុរស ជាមនុស្សកម្សត់ ទុគ៌តអ្នករកស្មៅ, ខ្ញុំបានថ្វាយបិណ្ឌបាតដល់ព្រះឧបរិដ្ឋ អ្នកទ្រង់យស” ដូច្នេះ ៗ

ខណៈនោះ គំនិតនេះកើតឡើងដល់លោកថា “សុមនសេដ្ឋីជាសម្លាញ់របស់អញ ដែលបានឲ្យកហាបណៈ អំពីបិណ្ឌបាតដែលអញថ្វាយដល់ព្រះឧបរិដ្ឋ ហើយសូមទទួលយកចំណែកបុណ្យកាលគ្រានោះ ឥឡូវនេះ ទៅកើតនៅទីណា” ? ៗ ខណៈនោះ លោកបានឃើញសេដ្ឋីនោះ ទៅកើតជាចូឡសុមនៈ ក្នុងចំនួនបុត្រពីរនាក់គឺ មហាសុមនៈនិងចូឡសុមនៈ ជាបុត្ររបស់ឧបាសកនាមថា មហាមុណ្ឌកៈ នៅក្នុងមុណ្ឌនិគមជិតជើងភ្នំ ដែលក្បែរព្រៃឆេះហើយ ៗ លុះលោកឃើញហើយក៏គិតថា កាលបើអញទៅក្នុងទីនោះ នឹងមានប្រយោជន៍ខ្លះដែរឬទេ? ៗ លោកពិចារណាមើលឃើញថា កាលអញទៅក្នុងទីនោះ ចូឡសុមនៈ មានអាយុត្រឹមតែ ៧ ឆ្នាំនឹងចេញបួស ហើយនឹងបានសម្រេចព្រះអរហត្ត ក្នុងវេលាដែលកោរសក់នុ៎ះឯង ៗ កាល

លោកឃើញហើយ ដល់ថ្ងៃជិតចូលវស្សា បាននិមន្តទៅតាមផ្លូវអាកាស ចុះត្រង់មាត់ទ្វារ ។ ចំណែកមហាមុណ្ឌកឧបាសក កាលពីមុនក៏ជាមនុស្សធ្លាប់ស្និទ្ធស្នាលរបស់ព្រះថេរៈដែរ ។ គាត់បានឃើញព្រះថេរៈកំពុងឃ្លុំចីពរក្នុងពេលនឹងបិណ្ឌបាត ទើបប្រាប់មហាសុមនៈ ជាបុត្រថា កូន! ព្រះអនុរុទ្ធត្ថេរជាម្ចាស់យើងនិមន្តមកហើយ កូនចូរទៅទទួលយកបាត្ររបស់លោកមកទុក រហូតដល់វេលាដែលពុំមានអ្នកណាទទួល, អញនឹងក្រាលអាសនៈ ។ មហាសុមនៈ បានធ្វើតាមពាក្យបិតានោះហើយ ។ ឧបាសកអង្គាសព្រះថេរៈដោយគោរព ក្នុងស្រុករបស់ខ្លួនរួចហើយទទួលបដិញ្ញាដើម្បីការឲ្យនៅចាំវស្សាអស់ត្រៃមាស ។ ព្រះថេរៈទទួលនិមន្តហើយ ។ ឧបាសកក៏នៅចាំមើលថែរក្សាបម្រើព្រះថេរៈអស់បីខែ ហាក់ដូចតែមួយថ្ងៃ, ដល់ថ្ងៃមហាបវារណា បាននាំយកត្រៃចីវរនិងវត្ថុជាច្រើនមុខ មានស្ករអំពៅ ប្រេងនិងអង្ករជាដើម មកតម្កល់ទុកជិតបាទាព្រះថេរៈ ហើយទូលថា និមន្តលោកម្ចាស់ទទួលទុកចុះ ។

ព្រះថេរៈ — ណ្ហើយ! កុំអីឧបាសក! អាត្មាមិនត្រូវការនឹងវត្ថុទាំងនេះទេ ។

ឧបាសក — នេះសំពត់ចំណាំវស្សា សូមលោកម្ចាស់ទទួលទុកចុះ ។

ព្រះថេរៈ — ណ្ហើយកុំ ឧបាសក !

ឧបាសក — ហេតុអ្វីបានជាលោកម្ចាស់មិនព្រមទទួលយក ?

ព្រះថេរៈ — ដ្បិតសាមណេរជាកប្បិយការកៈ ក្នុងសម្នាក់របស់អាត្មាគ្មានទេ ។

ឧបាសក បើដូច្នោះមហាសុមនៈ ជាបុត្ររបស់ខ្ញុំព្រះករុណានឹងបួសជាសាមណេរ ។

ព្រះថេរ — ឧបាសក ! អាត្មាមិនត្រូវការ មហាសុមនៈទេ ។

ឧបាសក— បើដូច្នោះ លោកម្ចាស់ឲ្យ ចូឡសុមនៈបួសចុះ ។

ព្រះថេរៈ ព្រមទទួលពាក្យ ហើយឲ្យចូឡសុមនៈបួស ។ ចូឡសុមនៈ នោះ បានសម្រេចព្រះអរហត្តក្នុងវេលាដែលកោរសក់នុ៎ះឯង ។ ព្រះថេរៈ គង់នៅជាមួយនឹងសាមណេរក្នុងទីនោះ ប្រមាណអស់កន្លះខែ (រាប់ពីត្រឹមថ្ងៃមហាបវារណាមក) តាំងព្រះទ័យថានឹងទៅគាល់ព្រះសាស្ដា, ទើបបានលាពួកញាតិរបស់សាមណេរ ទៅតាមផ្លូវអាកាស ចុះត្រង់ខ្ទម (កុដិ) ដែលនៅក្នុងព្រៃនាហិមវន្តប្រទេស ។ ឯព្រះថេរៈជាអ្នកប្រារព្ធសេចក្ដីព្យាយាមតាមប្រក្រតី កាលលោកកំពុងចង្ក្រមក្នុងយប់មុន និងយប់តមកទៀត ក្នុងព្រៃនោះ ខ្យល់ចុកសៀតពោះបានកើតឡើងហើយ ។ ខណៈនោះ សាមណេរឃើញព្រះថេរៈលំបាក ទើបទូលសួរថា បាន ព្រោស ! ព្រះគុណមិនសប្បាយឬអ្វី ?

ព្រះថេរៈ– ខ្យល់ចុកសៀតពោះកើតឡើងដល់យើង ។

សាមណេរ – កាលពេលមុន ធ្លាប់ជាបាត់ចុកឬទេ ។

ព្រះថេរៈ- ញាប់ជាបាត់បុក សាមណេរ!

សាមណេរ- ធ្វើម្ដេចទើបនឹងបានជា ព្រះគុណ!

ព្រះថេរៈ- កាលបើបានទឹកក្នុងស្រះអនោតត្តមកឆាន់ ទើបជាសាមណេរ!

សាមណេរ- បើដូច្នោះ ខ្ញុំនឹងទៅយកមកប្រគេន ។

ព្រះថេរៈ- នឹងទៅយកបានឬ សាមណេរ!

សាមណេរ- ទៅយកបាន ទានព្រោស!

ព្រះថេរៈ- បើដូច្នោះ ស្ដេចនាគនាមថា បន្នកៈ នៅស្រះអនោតត្តស្គាល់យើង, អ្នកចូរប្រាប់ដល់គេ ហើយយកទឹកមួយក្អមមក ដើម្បីប្រើជាថ្នាំ ។ សាមណេរទទួលពាក្យថ្វាយបង្គំលាព្រះឧបជ្ឈាយ៍ ហើយហោះឡើងកាន់វេហាស៍, ទៅដល់ទីស្រះនោះចម្ងាយផ្លូវប្រាំរយយោជន៍ ក៏ថ្ងៃនោះ ស្ដេចនាគមានអ្នកកំពោមពេមប្រាថ្នានឹងលេងទឹក គ្រាន់តែក្រឡេកឃើញសាមណេរទៅដល់ភ្លាម ស្រាប់តែក្រោធខឹងថា "សមណៈត្រកោលនេះ ត្រាប់ទៅជ្រុះផង់ធូលីនៅបាតជើងលើក្បាលរបស់អញ នឹងមកយកទឹកក្នុងស្រះអនោតត្ត, ឥឡូវនេះ អញមិនឱ្យយកទឹកបានទេ" ខឹងយ៉ាងនេះហើយ បានដេកដកពពារបិទស្រះអនោតត្តទំហំដល់៥០យោជន៍ ជិតដូចជាគេយកថាសខ្ទាតធំគ្របឆ្នាំងបាយទុកដូច្នោះ ។ សាមណេរលុះបានឃើញអាការរបស់ស្ដេចនាគ ក៏ជ្រាបថាគេខឹង, ទើបពោលគាថា

នេះ សេចក្ដីថា ៖

ស្ដេចនាគអ្នកមានតេជៈក្លា មានកម្លាំងច្រើន សូមចាំស្ដាប់ពាក្យអាត្មាសិន, ឲ្យទឹកដល់អាត្មាបន្ដិចមកចុះ, អាត្មាត្រូវការធ្វើជាថ្នាំ បានជាមកយក ។

ស្ដេចនាគស្ដាប់ពាក្យនោះ ទើបពោលគាថានេះសេចក្ដីថា ៖

ខាងទិសបូព៌ា ស្ទឹងធំឈ្មោះគង្គា នៅជាប់ជិតមហាសមុទ្រ លោកចូរទៅយកទឹកនាន់អំពីនោះទៅចុះ ។

សាមណេរបានឮដូច្នោះ គិតថា "ស្ដេចនាគនេះ មុខជាមិនព្រមឲ្យទឹកដោយសេចក្ដីស្ដាប់របស់ខ្លួន, អញនឹងធ្វើពលការឲ្យគាត់ដឹងមហានុភាពនិងវិសេសក្ដាត់ គាត់ ហើយយកទឹកទៅឲ្យបាន" គិតដូចពោលថា "មហាបពិត្រ! ព្រះឧបជ្ឈាយ៍ប្រើអាត្មាឲ្យមកយកទឹក អំពីស្រះអនោតត្តនេះ, ហេតុនោះ អាត្មានឹងយកទឹកនេះទៅឲ្យទាល់តែបាន, ចូរមហារាជចៀសចេញទៅ, កុំឃាត់កាំងអាត្មាឡើយ" ហើយពោលគាថានេះ សេចក្ដីថា៖

អាត្មានឹងយកទឹកអំពីស្រះនេះឲ្យបាន, អាត្មាត្រូវការដោយទឹកនេះឯង, បើកម្លាំងខ្លាំងក្លារបស់ព្រះអង្គមាន អញ្ជើញកាំងខាំងទុកចុះ, លោកជាស្ដេចនាគ.

ខណៈនោះ ស្ដេចនាគឆ្លើយថា "លោកសាមណេរ! បើលោកមានសេចក្ដីព្យាយាម, ខ្ញុំពេញចិត្តនឹងពាក្យសម្ដីរបស់លោកហើយ អញ្ជើញ

លោកយកទឹករបស់ខ្ញុំទៅចុះ" ។

ពេលនោះ សាមណេរឆ្លើយថា "មហាបពិត្រ! បើដូច្នោះ អាត្មានឹងយកទឹកទៅ", កាលដែលស្តេចនាគឆ្លើយថា "បើលោកអាចយកបាន, ចូរយកទៅចុះ" ដូច្នេះហើយ ក៏ទទួលបេដ្ញាត្រង់បីដងថា "បើដូច្នោះ មហាបពិត្រ ចូរជ្រាបឲ្យច្បាស់ចុះ" ហើយគិតថា "ញ្ញគួរតែសម្តែងអានុភាពរបស់ព្រះពុទ្ធសាសនា រួចចាំយកទឹកទៅ" ទើបទៅកាន់សម្នាក់របស់ពួកអាកាសដ្ឋកទេវតាជាមុន ។ ទេវតាពួកនោះនាំគ្នាមកថ្វាយបង្គំហើយសួរថា "មានកិច្ចអ្វី លោកម្ចាស់!" ហើយនាំគ្នាឈប់ចាំស្តាប់ ។ សាមណេរប្រាប់ថា សង្គ្រាមរវាងអាត្មានិងស្តេច បន្នគ-ជាតរាជ នឹងកើតនៅលើខ្នងស្រះអនោតត្ត; អ្នកទាំងឡាយចូរទៅចាំមើលការចាញ់និងឈ្នះក្នុងទីនោះ" ។ សាមណេរនោះ ចូលទៅរកស្តេចលោកបាលទាំងបួនអង្គ, និងព្រះឥន្ទ្រ, ស្តេចសុយាម, ស្តេចសន្តុសិត, ស្តេចសុនិម្មិតៈ និងស្តេចវសវត្តី ហើយប្រាប់សេចក្តីនោះ ដោយអាការដូចប្រាប់ពួកអាកាសដ្ឋកទេវតាដែរ ។ តពីនោះមកសាមណេរ ទៅដោយលំដាប់ រហូតដល់ព្រហ្មលោក ។ ពួកព្រហ្មថ្វាយបង្គំហើយសួរថា មានរឿងអ្វី? លោកម្ចាស់! ។ សាមណេរប្រាប់រឿងដូចខាងដើម ។ សាមណេរ ត្រាច់ទៅប្រាប់សព្វច្រកល្ហកសល់តែអសញ្ញិសត្វនិងអរូបព្រហ្ម ដោយវេលាត្រឹមតែមួយក្ពុតប៉ុណ្ណោះ

ដោយអាការយ៉ាងនេះ ៗ ពួកទេវតាគ្រប់ជាន់ ស្ដាប់ពាក្យរបស់សាម-ណេរ ហើយបានមកប្រជុំគ្នាចង្អៀតណែនតាន់តាប់ក្នុងផ្ទៃអាកាស ត្រង់ខ្នងស្រះអនោតត្ត ហាក់ដូចផង់កម្មួចទំដែលបុគ្គល ច្រកចូលក្នុងនាឡិ ៗ កាលបើទេវសមាគមប្រជុំព្រមគ្នាហើយ សាមណេរក៏ទៅឈរលើអាកាស និយាយនឹងស្ដេចនាគថា៖ សូមស្ដាប់ពាក្យរបស់អាត្មាចុះ លោកស្ដេចនាគ អ្នកមានតេជះ ឧក្កោស គឺខ្លាំងពូកែ មានកម្លាំងច្រើន! ចូរឲ្យទឹកអាត្មាមួយក្អម, អាត្មាត្រូវការធ្វើជាថ្នាំ ៗ គ្រានោះ ស្ដេចនាគឆ្លើយថា ឱសាមណេរតូច! បើលោកមានសេចក្ដីព្យាយាម, ខ្ញុំពេញចិត្តនឹងពាក្យសម្ដីរបស់លោកហើយ អញ្ជើញលោកយកទឹករបស់ខ្ញុំទៅចុះ ៗ

សាមណេរទទួលបេជ្ញារបស់ស្ដេចនាគគ្រប់បីដងហើយ ឡើងឈរលើអាកាស និម្មិតកាយជាមហាព្រហ្មធំ កំពស់ ១២ យោជន៍ ចុះអំពីអាកាសមកជាន់ចុចលើពពារបស់ស្ដេចនាគ សង្កត់ឲ្យមុខស្ដេចនាគផ្កាប់ចុះក្រោម ៗ គ្រាន់តែសាមណេរចុះជាន់សង្កត់លើពពា របស់ស្ដេចនាគភ្លាម ផែនពពាបានស្រុតផតលិចចុះក្រោមប្រមាណប៉ុនវែក ដូចបុរសអ្នកមានកម្លាំងខ្លាំងឈរជាន់លើផ្ទាំងស្បែកបត្ថប្រស់ទុក ៗ ក្នុងទីមាត់ស្រះ ដែលផុតពីពពាស្ដេចនាគ, ខ្សែទឹកប្រមាណប៉ុនដើមត្នោតខ្ពុរបញ្ចាញ់ឡើងទៅលើ ៗ សាមណេរត្រងទឹកបានពេញក្អម ក្នុង

អាកាសនោះឯង ៗ សមាគមនៃទេវតា បានឲ្យសាធុការដល់សាមណេរ គង់តែង ៗ ស្ដេចនាគអៀនខ្មាសផង ក្រោធខឹងនឹងសាមណេរផង ៗ ពែកករបស់ស្ដេចនាគមានពណ៌ដូចផ្កាចក្រ ៗ ស្ដេចនាគខឹងថា "សាម-ណេរនេះ ឲ្យទេវតាមកប្រជុំគ្នារួចបានយកទឹកទៅ (ម៉េចក៏មិនយកឲ្យស្អាតៗ) ធ្វើអញឲ្យអាប់មុខ, អញនឹងតាមទៅចាប់សាមណេរឲ្យបានយកមក ហើយលូកដៃទៅក្នុងមាត់ច្របាច់បេះដូងឲ្យបែកខ្ទេចខ្ទី ឬនឹងចាប់ជើងទាំងពីរគ្រវែងបោលទៅត្រើយសមុទ្រខាងនាយឯណោះ" គិតរួច ក៏ស្ទុះដេញតាមសាមណេរយ៉ាងលឿន ៗ សូម្បីស្ដេចនាគលឿនយ៉ាងណា ក៏នៅតែមិនទាន់សាមណេរដែរ ៗ សាមណេរមកដល់ហើយ ប្រគេនទឹកទៅព្រះឧបជ្ឈាយ៍ ទូលថា និមន្តឆាន់ចុះព្រះគុណម្ចាស់ ៗ ចំណែកស្ដេចនាគមកដល់ក្រោយឃាត់ថា លោកម្ចាស់ អនុរុទ្ធ សាមណេរយកទឹកដែលខ្ញុំមិនបានឲ្យមក លោកម្ចាស់កុំឆាន់ឡើយ ៗ

ព្រះអនុរុទ្ធត្ថេរ— មែនឬទេ ? សាមណេរ ! ៗ

សាមណេរ— និមន្តឆាន់ចុះ ព្រះគុណម្ចាស់ ! ទឹកដែលខ្ញុំយកមក ស្ដេចនាគនេះបានឲ្យហើយ ៗ ព្រះថេរៈ បានជ្រាបស្រេចហើយថា "ធម្មតាការនិយាយកុហករបស់សាមណេរជាព្រះខីណាស្រព គ្មានទេ", ទើបឆាន់ទឹកនោះ ៗ អាពាធបុកសៀតឧទរ ក៏ជាបាត់ក្លាយ ៗ ស្ដេចនាគទូលព្រះថេរៈទៀតថា លោកម្ចាស់ ! សាមណេរបានប្រជុំទេវតាទាំង

ពួនឲ្យមកមើល ធ្វើខ្ញុំឲ្យអាប់មុខ, ខ្ញុំប្រុងនឹងវះយកបេះដូងរបស់លោក ចេញ ឬនឹងចាប់លោកគ្រវែងទៅត្រើយសមុទ្រខាងនាយឯណោះ ។ ព្រះថេរៈឆ្លើយថា មហាបពិត្រ ! សាមណេរមានអានុភាពច្រើនណាស់, មហាបពិត្រ មិនអាចតតាំងច្បាំងនឹងសាមណេរបានទេ, ចូរសូមខ្មាលាទោសនឹងសាមណេរ ហើយអញ្ជើញស្ដេចត្រឡប់ទៅវិញទៅ ។ ស្ដេចនាគនោះ សូម្បីដឹងអានុភាពរបស់សាមណេរដោយខ្លួនឯងរួចហើយ ប៉ុន្ដែព្រោះសេចក្ដីអាប់មុខ បានជាដេញតាមមក ។ គ្រានោះ ស្ដេចនាគសូមខ្មាលាទោសនឹងសាមណេរតាមបង្គាប់ព្រះថេរៈ ហើយបានជាមិត្តស្និទ្ធស្នាលនឹងសាមណេរនោះ រួចបវារណាទុកថា "តាំងពីថ្ងៃនេះទៅ, កាលបើលោកម្ចាស់ត្រូវការទឹកក្នុងស្រះអនោតត្ត, លោកម្ចាស់មិនបាច់និមន្ដទៅព្រះអង្គឯងទេ គ្រាន់តែឲ្យដំណឹងទៅដល់ខ្ញុំ នឹងនាំយកទឹកមកថ្វាយភ្លាម" ទូលរួចហើយត្រឡប់ទៅវិមានវិញ ។ ចំណែកព្រះថេរៈ ក៏នាំសាម - ណេរចេញពីទីនោះទៅគាល់ព្រះសាស្ដា ។

ព្រះបរមសាស្ដាទ្រង់ជ្រាបថា "ព្រះថេរៈនឹងចូលមកគាល់ព្រះអង្គ" ក៏គង់ចាំទតមើលដំណើរមករបស់ព្រះថេរៈ នៅក្នុងប្រាសាទរបស់មាតាមិគារសេដ្ឋី ។ ចំណែកពួកភិក្ខុ ឃើញព្រះថេរៈនិមន្ដមក បានក្រោកទទួលបាត្រនិងចីវរ ។ ខណៈនោះ ភិក្ខុពួកខ្លះជាបុថុជ្ជន បានចាប់អង្រួនសាមណេរត្រង់ក្បាលខ្លះ ត្រង់ត្រចៀកខ្លះ ត្រង់ដើមដៃខ្លះ ហើយ

សួរថា ម៉េចមិនទាន់ចង់សឹកទេឬ សាមណេរ ។ ព្រះសាស្ដាទ្រង់ទតឃើញកិរិយារបស់ភិក្ខុទាំងនោះ ទ្រង់ព្រះតម្រិះថា កម្មរបស់ភិក្ខុទាំងនេះធ្ងន់ណាស់ ដ្បិតចាប់សាមណេរដូចជាគេចាប់អសិរពិសត្រង់ក, មិនទាន់ដឹងអានុភាពរបស់សាមណេរទេ, ថ្ងៃនេះ តថាគតគួរតែនឹងសម្ដែងសេចក្ដីល្អរបស់សាមណេរឲ្យឃើញច្បាស់ប្រាកដ ។ ព្រះថេរៈនិមន្តមកដល់ ថ្វាយបង្គំព្រះសាស្ដារួចគង់ស្ងៀម ។ ព្រះសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈនឹងព្រះថេរៈហើយត្រាស់ហៅព្រះអានន្ទត្ថេរមកប្រាប់ថា អានន្ទ! តថាគតត្រូវការយកទឹកក្នុងស្រះអនោតត្តមកលាងជើង, អ្នកចូរយកក្អមឲ្យពួកសាមណេរទៅដងទឹកយកមក ។ ព្រះថេរៈទើបឲ្យហៅសាមណេរក្នុងព្រះវិហារប្រមាណប្រាំរយរូបចូលមកប្រជុំគ្នា បណ្ដាសាមណេរទាំងនោះ សុមនសាមណេរ ជាអ្នកបួសថ្មីជាងគេបំផុត ។ ព្រះថេរៈប្រាប់សាមណេរដែលមានវស្សាច្រើនជាងគេថា នែសាមណេរ! ព្រះសាស្ដាមានព្រះបំណងនឹងយកទឹកក្នុងស្រះអនោតត្ត, មកលាងព្រះបាទ, អ្នកចូរយកក្អមទៅដងទឹកយកមកថ្វាយ ។

សាមណេរនោះ បដិសេធគឺប្រកែកថា ខ្ញុំមិនអាចនឹងទៅដងទឹកនោះ យកមកបានទេ ។ ព្រះថេរៈបានសួរសាមណេរដទៃទៀតតាមលំដាប់ ។ សូម្បីសាមណេរទាំងនោះ ក៏និយាយបដិសេធដូចគ្នា ។ បើនឹងតាំងជាប្រស្នាឡើងថា ក្នុងទីប្រជុំនោះ សាមណេរជាព្រះខីណាស្រព

ពុំមានទេឬ?, ក៏អាចឆ្លើយបានភ្លាមថា មានជាប្រាកដ, ប៉ុន្តែលោកមិនប្រាថ្នានឹងទៅយកទឹកទេ ដោយគិតថា កម្រងផ្កានេះ ព្រះសាស្តាមិនបានទ្រង់ក្រងទុកដើម្បីឲ្យពួកយើងទេ, ទ្រង់ក្រងទុកដើម្បីឲ្យ សុមនសាមណេរ តែមួយអង្គប៉ុណ្ណោះ ។ ទៅទីបំផុត ក៏ដល់វារៈរបស់ សុមនសាមណេរ ។ ព្រះថេរៈប្រាប់ថា នែសាមណេរ! ព្រះសាស្តាមានព្រះបំណងនឹងយកទឹកក្នុងស្រះអនោតត្ត មកលាងព្រះបាទ, អ្នកចូរយកក្អមទៅដងទឹកយកមក ។ សុមនសាមណេរ គិតថា "កាលបើព្រះសាស្តាទ្រង់ប្រើឲ្យទៅយក ក៏ត្រូវតែទៅយកមក" ទើបថ្វាយបង្គំព្រះសាស្តា ហើយទូលសួរថា បានឮថា ព្រះអង្គប្រើឲ្យខ្ញុំព្រះអង្គឲ្យទៅយកទឹកអំពីស្រះអនោតត្តមែនឬ? ព្រះអង្គ! ។

ព្រះសាស្តាត្រាស់ថា អើ សុមនៈ! មែនហើយ ។

សុមនសាមណេរនោះ យកដៃចាប់ក្អមធំចំណុះទឹក បានដល់ ៦០ ក្អម យកតែក្អមមួយ ក្នុងបណ្តាក្អមដែលដាក់តម្រៀបទុកក្នុងសេនាសនៈ សង់ជាមាសសុទ្ធដែលនាងវិសាខា កសាងទុក គិតថា "អញមិនត្រូវការនឹងលើកក្អមនេះ ដាក់លើស្មាទេ" ទើបយួរក្អមហើយហោះឡើងកាន់វេហាស៍ បែរមុខទៅត្រង់ព្រៃហិមពាន្ត ។ ស្តេចនាគឃើញសាមណេរ កំពុងតែហោះមកអំពីចម្ងាយលើមេឃ ក៏ស្ទុះទៅទទួលយកស្មាលីក្អមនិយាយថា លោកម្ចាស់! កាលបើមានអ្នកបម្រើដូចជាខ្ញុំ

នេះហើយ ម្ដេចក៏ចាំនិមន្តមកព្រះអង្គឯង, កាលបើមានសេចក្ដីត្រូវការ ដោយទឹក ម្ដេចក៏មិនផ្ដាំផ្ញើតែដំណឹងមក ?” ហើយយកក្អមដងទឹកលើក ឡើងខ្លួនឯងទូលថា និមន្តលោកម្ចាស់ទៅខាងមុខមុនចុះ ខ្ញុំនឹងយកទឹក ទៅប្រគេនខ្លួនឯង ។ សាមណេរឆ្លើយថា “មហាបពិត្រ ! សូមព្រះអង្គ ឈប់សិន កុំស្ដេចជូនទៅ ព្រោះអាត្មាត្រូវព្រះសម្មាសម្ពុទ្ធត្រាស់ប្រើមក” ប្រាប់ឲ្យស្ដេចនាគត្រឡប់ទៅវិញ ហើយយកម្រាមដៃចាប់ ត្រង់កណ្ដាប់ មាត់ក្អមយួរមកតាមអាកាស ។

ខណៈនោះ ព្រះសាស្ដា ទតឃើញសាមណេរកំពុងតែហោះមក ត្រាស់ហៅភិក្ខុទាំងឡាយមកប្រាប់ថា ភិក្ខុទាំងឡាយ ! ពួកអ្នកចូរមើល លីលារបស់សាមណេរចុះ ល្អដូចស្ដេចហង្សត្រង់អាកាស ។ ចំណែក សាមណេរដាក់ក្អមទឹកហើយ ថ្វាយបង្គំព្រះសាស្ដា ហើយឈរគាល់ ។ គ្រានោះ ព្រះសាស្ដាត្រាស់សួរសាមណេរថា សុមនៈ! អ្នកមានអាយុ បានប៉ុន្មានឆ្នាំហើយ ? ។

សុមនសាមណេរ– បាន ៧ ឆ្នាំហើយ ព្រះអង្គ !

ព្រះសាស្ដា– សុមនៈ! បើដូច្នោះ តាំងពីថ្ងៃនេះទៅ អ្នកចូរជា ភិក្ខុចុះ ដូច្នេះហើយ ទ្រង់ប្រទានឲ្យឧបសម្បទ ។ បានឮថាសាមណេរដែលមានអាយុ ៧ ឆ្នាំ បានទទួលឧបសម្បទមានតែពីរអង្គប៉ុណ្ណោះ គឺ សុមនសាមណេរនេះ មួយអង្គ សោបាកសាមណេរ

មួយអន្លើទៀត ។ កាលសុមនសាមណេរ នោះឧបសម្ប័ទហើយយ៉ាងនេះ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម៌ថា អស្ចារ្យណាស់ អាវុសោ ! អានុភាពរបស់សាមណេរតូចមានដល់ប៉ុណ្ណេះ មុនអំពីពេលនេះ អានុភាពដូច្នោះ ពួកយើងមិនដែលបានឃើញសោះឡើយ ។ ព្រះសាស្តាស្តេចមកដល់ហើយត្រាស់សួរថា "ភិក្ខុទាំងឡាយ ! ឥឡូវនេះ ពួកអ្នកអង្គុយសន្ទនាគ្នាពីរឿងអ្វី ?" កាលភិក្ខុទាំងនោះក្រាបទូលទ្រង់ជ្រាបហើយត្រាស់ថា "ភិក្ខុទាំងឡាយ ! ក្នុងព្រះសាសនារបស់តថាគត សូម្បីជាក្មេងតូច ប៉ុន្តែជាអ្នកប្រតិបត្តិប្រពៃ ក៏រមែងបានសម្បត្តិឃើញច្បាស់បែបនេះដូចគ្នា" កាលទ្រង់សម្តែងធម៌ត្រាស់គាថានេះថា ៖

យោ ហវេ ទហរោ ភិក្ខុ យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

ភិក្ខុណា នៅកម្លោះ ប្រឹងប្រែង ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះរមែងញុំាងលោកនេះឲ្យភ្លឺស្វាងបាន ដូចព្រះចន្ទដែលរះផុតអំពីពពក ។

ក្នុងទីបំផុតនៃទេសនា ជនជាច្រើននាក់បានសម្រេចមគ្គផល មានសោតាបត្តិផលជាដើម ។

សេចក្តីសង្ខេបក្នុងរឿងសុមនសាមណេរ ៖

ពីអតីតកាល សុមនសេដ្ឋី បានសុំចែកចំណែកផលបុណ្យនៃបិណ្ឌបាតទានអំពី អន្នភារបុរស ហើយបានធ្វើមហាទានជាច្រើនជាតិ

មកៗទៀត លុះដល់ជាតិជាទីបំផុត បានកើតក្នុងត្រកូលឧបដ្ឋាកនៃព្រះអនុរុទ្ធត្ថេរ, ដល់អាយុ ៧ ខួបបួសជាសាមណេរ, គ្រាន់តែកោរសក់រួចភ្លាមបានសម្រេចព្រះអរហត្តផល ឈ្មោះ សុមនសាមណេរ ។

បានឮថា សាមណេរដែលមានអាយុ ៧ ឆ្នាំ បានទទួលទាយជ្ជ-ឧបសម្បទតែពីរអង្គប៉ុណ្ណោះ គឺ សុមនសាមណេរមួយអង្គ និងសោបាកសាមណេរ មួយអង្គទៀត ដោយព្រះពុទ្ធានុញ្ញាតថា «តាំងពីថ្ងៃនេះទៅ អ្នកចូរជាភិក្ខុចុះ» ហើយទ្រង់ប្រោសប្រទានទាយជ្ជឧបសម្បទ ។

រឿងសុមនសាមណេរ ចប់ ។

| |
|---|
| អ្នកមានឫទ្ធិជាមហាអំណាច<br>មិនអាចផ្ចាញ់អ្នកមានបុណ្យបានទេ |

ផ្នែកអក្សរសាស្ត្រ

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ឆាំង-ខាត់ រៀបរៀង*

អភិក្រម៌ ក្រិ.វិ. និរន្តរ៍ ។ អភិក្រុគស៌ ដូចគ្នា ។

អភិត គុ. ឥតខ្លាច ។ —វត៌ ក្រិ.វិ. ដោយឥតខ្លាច ។

—ហារិន៌ គុ. ដែលបេចូលទៅឥតភ្លឹក ។

អភិប្សិត គុ. គួររីករាយ ។

អភិប្សិន៌ គុ. ដែលប្រាថ្នា ។ —អភិម្ប្សុ គុ. ដូចគ្នា ។

អភិរុ គុ. ឥតខ្លាច ។ —ក៏ គុ. ដូចគ្នា ។ ស្ត្រី ឈ្មោះឈើ ។

អភិឝុ បុំ. បង្ហៀរសេះ ។ កាំពន្លឺ ។ —មន្ត៍ គុ. ដែលភ្លឺ ។ បុំ. ព្រះអាទិត្យ ។

អភិឞ ធាតុ តម្រង់ ប្រាថ្នា ។ អភិឞ្ដ គុ. ដែល

ប្រាជ្ញា ថ្លៃថ្លា ។ នបុំ.បំណង ។ –អភិប្ដ

ទេវតា ស្ត្រី. ទេពតា ដែលខ្លួនកប់អាន (មុនស្លាប់)

–អភិប្ដុំក្ប រៀបចំខ្លួននឹងស្លាប់ ។

អភិសាហ បុំ. ពហុ. ឈ្មោះប្រជាជនមួយ ។

អភិបុ មើល អភិគុ ។

អភិប្ទ្រោណ គុ. ដែលមិនមាន ភិប្ទ និងទ្រោណ ។

អភិសារ បុំ. –អភិសារ កិរិយាចូលលុក ។

អភុក្ត គុ. ដែលមិនបរិភោគ ដែលមិនប្រើប្រាស់ ។ –វិគ្ត គុ. អ្នកមិនបានស៊ី ។ – បុរិ គុ. ដែលមិនបានប្រើប្រាស់ពីកាលមុន ។

អភុជិប្បាត្ត គបុំ. –ភាវៈ នៃស្ត្រីមិនមែនជាអ្នកបម្រើ ឬ ជាអ្នកនៅក្រោមបង្គាប់ ។

អភុញ្ជាន គុ អ្នកមិនបរិភោគអាហារ ។

អភូត គុ. –អភូត ដែលមិនពិត ខុស ។ –ទោស គុ. ដែលឥតមានកំហុស ។ –បុរិ គុ.

ដែលមិនមានក្នុងកាលតាំងពីដើម ។

អភូតលស្ប្ឫឞ្ដតា ស្រ្តី. ភាវៈនៃកិរិយាមិនពាល់ដី ។

អភូត ស្រ្តី. – អភូតិ កិរិយាមិនមានភព, ហាយនភាព ។

អភូមិ ស្រ្តី. – អភូមិ ទីឋានមិនមែនជាភូមិ ។ – ជិ គុ. ដែលកើតក្នុងភូមិមិនល្អ ។ – ៩ គុ ដែលមិនឲ្យផលដល់ភូមិ ។

អភូយៈសំនិវ្ឫត្តិ ស្រ្តី. កិរិយាមិនត្រឡប់មកវិញ ។

អភ្ឫត គុ ដែលមិនឲ្យតម្លៃ ។

អភ្ឫត្យាត្មន គុ. ដែលមិនធ្វើខ្លួនជាអ្នកបម្រើ ។

អភោក្ឫ ការក អ្នកមិនក្បត់ ។

អភេទ បុំ. កិរិយាមិនបំបែក ។ គុ. ដែលមិនច្បាស់ ។

អភោគ បុំ. – អភោគ កិរិយាមិនរីករាយ ។

អភោគ្យ គុ. ដែលមិនគប្បីយកគ្នា (ប្តីប្រពន្ធ) ។

អភោជន នបុំ. – អភោជន កិរិយាមិនបរិភោគអាហារ ។

អភោជ្យ គុ. ដែលគប្បីហាមមិនឲ្យបរិភោគ, ដែលមិនគប្បីចិញ្ចឹម ។

អភ្យគ្រ　　គុ. ថ្មី ។ នបុំ. ទីជិតខាង ។

អភ្យង្គ　　បុំ. ពិធីលាបប្រេងប្រសិទ្ធពរ ។ —អញ្ជន នបុំ. ដូចគ្នា ។

អភ្យញ្ជ　　ធាតុ លាបប្រេង ។ —អភ្យក្ត គុ. ដែលលាប ។

អភ្យញ្ជក　　គុ ដែលលាបដែលរីត ។

អភ្យតិក្រម　　ធាតុ ដើរកន្លង ។

អភ្យតិវត្ត　　ធាតុ ប្រព្រឹត្តកន្លង ។

អភ្យតី(តិ)　　ធាតុ កន្លងក្រៃលែង ។

អភ្យធិក　　គុ. —អភ្យធិក ដែលអធិកក្រៃលែង ។

អភ្យនុជ្ញា　　ធាតុ អនុញ្ញាត ព្រមឲ្យ អនុញ្ញាត ។

អភ្យនុជ្ញា　　ស្ត្រី. សេចក្តីអនុញ្ញាត ។

អភ្យនុប្រេគ　　ធាតុ ស្ទួរដំណឹង ។

អភ្យនុមុទ　　ធាតុ យល់ព្រម ។

អភ្យនុយុជ　　ធាតុ សួរ, សួរប្រស្នា ។

អភ្យនុវត្តិ　　ស្ត្រី. កិរិយាស្រឡាញ់ក្រៃលែង ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ-កា ង

ប្រែ-រៀបរៀង

(គ)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងចេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហជាតិ |

— យូរ-មុន —

ជូឡុងឮដូច្នោះ ខឹងណាស់ បំផាយសេះកាន់លំពែងចូលច្បាំងនឹងហានតេក, ហានអេង ឃើញដូច្នោះ ក៏បន្ទ្រុះចូលទៅតទឹងជូឡុងជួសបិតាបាន ៣ ភ្លូង ជូឡុងក៏ចាក់នឹងលំពែងត្រូវហានអេងធ្លាក់ពីលើសេះស្លាប់, ហានគៀវឃើញបងស្លាប់ ខឹងណាស់ បំផាយសេះកាន់ដាវចូលតទឹងជូឡុងយ៉ាងអង់អាច, ហានខេងឃើញបងកម្លាំងតិច ខ្លាចថ្វាះការទឹងជូឡុង ក៏ស៊ុះស៊ុងទៅហៅហានគីជាប្អូន ចូលទៅជួយច្រូតគ្នា ជា ៣ មុំ, ជូឡុងក៏ពុំញញើតកោតខ្លាច លើកលំពែងសស្ទាច ចាក់ត្រូវហានគីធ្លាក់ពីលើសេះ, ទាហានស៊ុះទៅជួយប្រឡះគ្រាហ៍យកខ្លួនហានគី ចូលទៅក្នុងស្រុកបាន, ជូឡុងក៏ដេញទន្ទ្រានតាមទៅ, ហានខេងយកធ្នូបាញ់សំដៅជូឡុង ៣ ព្រួញ, ជូឡុង ក៏យកញញួរលំពែងគ្រវែងចាក់កាត់ធ្លាក់ទៅវិញបាន, ហានខេងខឹងពន់ប្រមាណ បំផាយសេះចូលទៅកាប់ជូឡុង ៗ ក៏លើកធ្នូបាញ់ទៅត្រូវ

កំបៀងហ៊ានខងធ្លាក់ពីលើសេះស្លាប់, ហ៊ានអៀវបំផាយសេះប្រញាប់ចូលទៅត្រង់លើកដាវតម្រង់នឹងកាប់, ដូឡុងគេចក្រឡាប់ឆក់យកដាវ កាវរួចជាប់ទាំងខ្លួនហ៊ានអៀវ, ទាហានស្ទុះខ្សៀវទៅជួយចង់បាន, ដូឡុង ក៏ចរបំ-ពានចូលទៅក្នុងកងទ័ពហ៊ានគេក ៗ ក៏ភ័យតក្កមា បំផាយសេះចូលទៅបន្ទុំក្នុងពួកទាហានហើយថា ដូឡុងនេះ ពុតែគេនិយាយថាមានថ្មីដៃខ្លាំងពូកែណាស់ លុះមកជួបប្រទះ ក៏ឃើញមែនគ្រប់ប្រការ, ហ៊ានគេកនឹករអាខ្លាចក៏លើកទាហាន ត្រឡប់ចូលទៅក្នុងស្រុកវិញ, ដូឡុងក៏បំរោលសេះតាមដេញទៅតែឯង, គេងជីនឹកបារម្ភភ័យ ក៏បំផាយសេះតាមទៅទាំង ២ នាក់ក៏កាប់ត្រូវទាហានហ៊ានគេក ស្លាប់ច្រើនណាស់, ហ៊ានគេក ឃើញដូឡុងដេញជិតនឹងប៉ះមកដល់ខ្លួន ក៏ភ័យរលះរលាំងស្ទុះលោតចុះពីលើសេះ ដោះអាវក្រោះបោះចោលទៅ ហើយទំសំដៅរត់ចូលទ្វារបាន, ទាហានក៏ព្រានបិទជាប់ទៅវិញ, ឯដូឡុងនិងគេងជីនោះម៉ិញ ក៏នាំទាហានត្រឡប់ទៅបន្ទាយឯក្នុងហ៊ងបេងស៊ន, គេងជីក៏និយាយនឹងដូឡុងថា មិនបង់មៀតដែលលោកជាជាតិទាហាន មានអាយុដល់ ៧០ ឆ្នាំ ហើយនៅខ្លាំងពូកែនឹងគេអ្នកឯណាស្មើគ្មាន, ដូឡុងឆ្លើយថ្កានថា មហាឧបកដអាចមើលងាយយើង ថាចាស់ជរា បានជាមិនចង់ឲ្យមកធ្វើការ ក្រែងយើងជរាគ្មានកម្លាំងនឹងច្បាំងពុំបានជ័យជម្នះ បើខ្លោយថ្មោះ នឹងបានសេចក្ដីអាប់យសខ្មាសសត្រូវ, ឯខ្លួនយើងគិតថា ចាស់តែអាយុប៉ុណ្ណោះ, ឯកម្លាំងនឹងថ្មីដៃនោះ

បើឲ្យតស៊ូនឹងក្មេងកម្លោះ ដែលមានវិជ្ជាខ្លាំងពូកែយ៉ាងណា, យើងក៏ឥតញញើតខ្លាចសោះឡើយ, និយាយហើយជូឡុងក៏តែងសេចក្ដីសំបុត្រ ១ ច្បាប់ ឲ្យបម្រើចងនាំខ្លួនហ័នអៀវទៅជូនខុងបេង ៗ

ឯហ័នគេកនោះ លុះចូលទៅដល់ ហៃហួលិម ក៏យំជម្រាបសេចក្ដីឲ្យស្ដាប់គ្រប់ប្រការ, ហៃហួលិមបានស្ដាប់សព្វគ្រប់ ក៏ខឹងណាស់ លើកទាហានចេញពីស្រុកទៅដល់ក្នុងហាងបេងស័ន ក៏ឲ្យបោះទ័ពបញ្ឈប់តាំងបន្ទាយ, ជូឡុងដឹងការ ក៏ជិះសេះកាន់លំពែងចេញមកជាមួយនឹងទាហាន ១.០០០ នាក់ នៅមុខបន្ទាយ ៗ

ហៃហួលិម តែងតួពាក់មួកមាស កាន់ដាវវែងចេញមកបញ្ឈរសេះនៅមុខទាហាន, លុះជូឡុងលើកមកដល់ ហៃហួលិមក៏បរសេះចូលប្រយុទ្ធគ្នា, ហ័នគេកថា ជូឡុងសម្លាប់កូនខ្ញុំបាត់អស់, ខ្ញុំបានសុំចេញទៅសងសឹកជាមុនសិន, ហ័នគេក ក៏បំផាយសេះចេញច្បាំងនឹងជូឡុងបាន ៣ ក្បួន, ជូឡុងលើកលំពែងចាក់ត្រូវហ័នគេកធ្លាក់ពីលើសេះស្លាប់, ហៃហួលិម ក៏ថយទ័ពត្រឡប់ទៅបន្ទាយចម្ងាយពីទីនោះ៨០ សិន (៣.២០០ ម៉ែត្រ), ជូឡុងនិងគេងជី ក៏នាំទាហានដេញតាមទៅសម្លាប់ទាហានហៃហួលិមស្លាប់ជាច្រើន ៗ

ហៃហួលិមនោះ លុះតាំងបន្ទាយមួយមាំមួនហើយ ក៏ប្រឹក្សានឹងទាហានទាំងពួកថា ជូឡុងនេះ យើងគ្រាន់តែឮល្បីដោយសារគេនិយាយ

យូរមកហើយ មិនដែលបានដឹងស្គាល់យល់ប្រទះឥឡូវ, ទើបឃើញមុខច្បាស់ជាមានថ្វីដៃខ្លាំងពូកែមែន នឹងរកនរណាតស៊ូក៏មិនបាន, យើងនឹងរិះគានយ៉ាងម្ដេច ទើបនឹងយកជ័យជម្នះបាន? ទៀប៊ូផាកូនទៀយ៉ុកឆ្លើយថា ដូឡុង ល្អតែថ្វីដៃទេ, ឯគំនិតគិតគូរមិនចេះ, ពេលព្រឹកនេះ សុំឲ្យលោកចាត់ទាហានចេញទៅបង្កប់ទុកនៅសងខាងផ្លូវ រួចសឹមលើកទ័ពធំចេញទៅច្បាំងនឹងដូឡុង ហើយធ្វើជាចាញ់តបញ្ឆោតឲ្យដេញ រួចយើងនឹងបញ្ចេញទាហានឲ្យចោមព័ទ្ធចាប់ខ្លួនដូឡុងឲ្យបាន ។

ហែហូលិមយល់ឃើញត្រូវ ទើបប្រើតាំងហ៊ុនដឹងជីចេកឲ្យនាំទាហានម្នាក់ ៣ មុឺនលើកទៅបង្កប់នៅសងខាងផ្លូវ, លុះវេលាព្រឹក ហែហូលិមក៏ឲ្យទាហានវាយឃ្មោះស្រែកហ៊ោលើកចេញទៅតម្រង់បន្ទាយដូឡុង ។ ឌិងតេងជីឃើញដូច្នោះ ក៏ឡើងសេះ លើកទាហានចេញពីបន្ទាយ, តេងជីឃើញទាហានហែហូលិមធ្វើអាការអង់អាច ក៏គិតសង្ស័យ ទើបស្រដីសួរទៅដូឡុងថា កាលពីម្សិលមិញ ទាហានហែហូលិម ចាញ់ប្រៀបរបស់យើងស្លាប់ជាច្រើនណាស់, ហេតុម្ដេច ថ្ងៃនេះ ក៏នៅមិនខ្លាចរអាថ្វីដៃនៅលើកទាហានជាច្រើនក្រៃមកច្បាំងនឹងយើងទៀត ឬហែហូលិម មានល្បិចនឹងប្រើឧបាយបញ្ឆោតយើងទេដឹង? សុំឲ្យលោករំពឹងគិត ពិនិត្យមើលឲ្យយល់ការសិន, ដូឡុងថា ហែហូលិម នៅក្មេងសេចក្ដី ខ្វិតប្រិះប្រាជ្ញាពុំកាស់, ទឹកដោះនៅមាត់ មិនទាន់ភ្ញាក់ក្លិននៅឡើយផង, កាល

ណាហើយរាំទឹងបេះគិតធ្វើឧបាយកល ដូចសេចក្តីយល់របស់អ្នកថានោះទេ, វេលាថ្ងៃនេះ យើងនឹងយកជ័យជម្នះឲ្យបាន ហើយយើងត្រូវរះអានទ័ពចាប់ហៃហ្វូលិមជាមុន, និយាយហើយ ដូឡុងក៏បរសេះចូលច្បាំងនឹងហៃហ្វូលិម, ឡស៊ុយ ក្រឡេកឃើញ ក៏បរសេះចូលតស៊ូនឹងដូឡុងបាន ៣ ក្បួន ឡស៊ុយធ្វើជាចាញ់ទាញសេះរត់, ដូឡុងនឹងគេងដីក៏ញាក់សេះដេញតាមទៅ, នាយទាហានឯកហៃហ្វូលិម ៨ នាក់ ឃើញដូច្នោះ ក៏បណ្តោយឲ្យហៃហ្វូលិមរត់ទៅមុន ហើយក៏នាំគ្នាព័ទ្ធបោមកេមដូឡុងនិងគេងដីឲ្យនៅជាកណ្តាល រួចហើយនាយទាហានទាំង ៨ នាក់ ក៏ញាក់សេះរត់ទៅទៀត, ដូឡុង និងគេងដី ក៏បំផាយសេះដេញប្រទៀតហួសចូលទៅ, ទទួលឮសម្លេងទាហានរាយឃោះក្នុងព្រៃជ្រៅ លាន់ទាំង ៤ ទិស, គេងដីភ័យណាស់ ត្រឡប់ញាក់សេះនឹងរត់, ដីចេកស្ទុះដេញទាហានព័ទ្ធពីម្ខាងខាងស្តាំដៃ, តាំងហ៊ុស្ទុះដេញទាហានពីព្រៃ នៅខាងឆ្វេងព័ទ្ធដូឡុងនិងគេងដីនៅជាកណ្តាល ហើយកយគ្នាចូលទៅនៅជើងភ្នំខាងទិសឧត្តរ, ដូឡុងឃើញសត្រូវស្ទុះស្រព័ទ្ធជុំវិញ ក៏ដេញតាមផ្លាមិនរាថយមើលទៅខាងក្រោយទិសឯជើងស្តើងទាហានជាងគេ, ដូឡុង ក៏បរសេះបំពារត្រង់ទៅទឹងរកផ្លូវរត់ចេញ, ឯពួកទាហាន ដេញបោមកេមតាមទៅព័ទ្ធជិតចង្កេះភ្នំ, ហៃហ្វូលិមនាំទាហានទៅពួនខាងលើកំពូល ដេញទាហានទៅខ្ទួលឲ្យប្រមៀលដុំថ្មធ្លាក់ចុះមក ដូចគេបាចសាច, ដូឡុង ក៏នៅអង់

អាច ដេញតាមសម្លាប់ទាហានហៃហ្លួលិម តាំងពីព្រលឹម ទាល់ព្រលប់ មិនឈប់សោះ ក៏ទៅកេប្រកគេបដោះចេញទៅមិនរួច, ដូឡុងហបហាត់ ដូចជាទឹងរលេះជើងដៃ ក៏លោតចុះពីលើសេះ វេះចូលទៅអង្គុយអែបនឹង ពើងសិលា, ឯតេងជី ក៏ក្លាត់ព្រាត់បាត់ពីគ្នា មិនដឹងរស់ឬស្លាប់, លុះឃើញ ខែរះស្រអាប់ព្រាងៗ, ពួកសត្រូវដែលព័ទ្ធទាំងសងខាង ក៏ដុតភ្លើងភ្លឺឡើង ទាំង ៤ ទិស ហើយបាញ់ទឹងធ្នូបម្រុះទៅត្រង់ដូឡុង បីដូចគ្រាប់ភ្លៀង, ហើយស្រែកថា ដូឡុង! អ្នកឯងត្រូវចេញមុខមកកេយើង ៗ ទឹងទុកជីវិត, ដូឡុងបានឮដូច្នោះ ក៏ខឹងណាស់ ចាប់លំពែងគ្រវែងលើកឡើង ហើយ ឡើងសេះ បរបង្រ្ទុះទៅតាមទាហានដែលព័ទ្ធទាំង៤ ទិស, ទាហានទាំង នោះ ក៏ប្រឹងសម្រុះប្រចៀតប្រៀតគ្នាចូលទៅ, ដូឡុងអស់សេចក្ដីគិត ក៏ងើប មុខឡើងមើលអាកាស ហើយដកដង្ហើមធំថា យើងធ្វើសឹកសង្រ្គាមរៀង មកតាំងពីកំលោះ លុះចំណាស់ប៉ុណ្ណោះហើយ មិនដែលឡើយទឹងចាញ់ អ្នកឯណា, គ្រានេះ យើងទឹងស្លាប់អសារជាប្រាកដ ៗ

ខណៈនោះ ទទួលខុងបេងឡេតៀវប៉ោ នាំទាហាន ៥.០០០ លើក តាមដូឡុងមកទន្ទាន់គ្នា, តៀវប៉ោឃើញទាហានហៃហ្លួលិមព័ទ្ធដូឡុងនៅ ក្នុងចំណោម ហើយឃើញជីចេកចេញមកស្ទាក់ពីមុខផាប់, តៀវប៉ោក៏បំ ផាយសេះសន្ទាប់ចាប់លំពែងប្រវែង ៣ ព្យាមពីរហត្ថរបស់បិតា ចូលទៅ ចាក់ជីចេកធ្លាក់ពីលើសេះស្លាប់ ហើយគាត់យកក្បាលចងព្យួរទឹងកសេះ

ពុះខ្មាំងហ៊ុំទាហាន ខ្រនាទចូលដល់ដូឡុងកងចំណោមបាន, ដូឡុងឃើញតៀវហ៊ុយចូលទៅដល់ ក៏សែនសល់អំណររកគ្មាប្រៀបពុំបាន, តៀវហ៊ុយក៏ប្រាប់ដូឡុងថា មហាឧបកជយល់ឃើញថា មាមានជកកាពណាស់ ក្រែងប៉ះការទឹងសត្រូវ ទើបតម្រូវប្រើខ្ញុំបាទឲ្យលើកទាហាន ៥.០០០ មកខ្នាន់ជាក្រោយ ហើយដូឡុងនិងតៀវហ៊ុយ ក៏លើកទាហាន ៥.០០០ ចេញមកពីកងចំណោម បានពារខ្រនាទតម្រង់ទៅទិសបស្ចិម ក្រឡេកឃើញកួនហ៊ុនបំផាយសេះសន្ទឹមមកពីចម្ងាយដៃម្ខាងយួរក្បាលមនុស្ស ពុះខ្មាំងចូលមកដល់, កួនហ៊ុនក៏ជម្រាបដូឡុងថា មហាឧបកជប្រើខ្ញុំបាទឲ្យនាំទាហាន ៥.០០១ លើកមកជួយលោកមា, ទទួលតាំងហ៊ុំទាហានហែហួលិមនៅកំពឹកស្ទាក់ពីមុខ, ខ្ញុំបាទក៏បំផាយសេះសម្រុកចូលទៅកាត់ក្បាលបាននាំមកនេះ, ឯមហាឧបកជនោះ លើកទ័ពតាមមកជាក្រោយ ៗ

ដូឡុង ក៏ឆ្លើយបណ្តាយថា ដែលក្មួយតាំងពីរបានលើកមកជួយមាវេលានេះ មាមានអំណរណាស់, បើដូច្នេះ គួរយើងជួយគ្នា ចាប់ខ្លួនហែហួលិមឲ្យបាន ទើបនឹងមានសេចក្តីគាប់ប្រសើរ, តៀវហ៊ុយនិងកួនហ៊ុន បានស្តាប់ ក៏យល់ព្រមគ្នា ទើបមិត្តមាលើកទាហានឡើងទៅលើភ្នំ ដើម្បីនឹងចាប់ហែហួលិម, ដូឡុង ក៏បំផាយសេះចុះទៅបបួលកងទាហានប្រទះនឹងគេងដី ទើបស្ទុះរុញពីកងចំណោមមក, ដូឡុងក៏នាំយកឡើងទៅជាមួយគ្នា ហើយដូឡុង ក៏និយាយនឹងគេងដីថា យើងបានធ្វើសឹក

តាំងពីគ្រាព្រះចៅឡូវពីគង់ព្រះជន្ម, យើងក៏មិនដែលអាប់ចុនថ្វះការនឹងសត្រូវសោះ, គួរឬ? វេលានេះ មកអាប់យសបង់ ប្រៀបនឹងអាហៃហ្វូ-លិមក្មេងទឹកដោះទៅមាត់, នេះ ហាក់ជាបានតៀវប៉ៅ គួនហ៊ុន លើកទាហានមកជួយស្រាត់ដោះពីចំណោមបាន កុំអីយើងនឹងបង់ប្រាណ អសារឥតការ, ឥឡូវតៀវប៉ៅ គួនហ៊ុន គេនៅប្រាថ្នាលើកតាមហៃហ្វូលិមទៅលើក្នុំហើយ, យើងនឹងនៅព្រងើយ មិនទៅជួយឯណាបាន ត្រូវតែគិតអានសងសឹកវិញ កុំឲ្យខ្មាសមុខរ៉ា, នោះជូឡុងនិងតេងជីក៏ម្ពាលើកទាហានឡើងតាមទៅ កន្លងពេលកណ្ដាលយប់ជ្រៅនោះ បញ្ចូលទាហានជាមួយគ្នានឹងតៀវប៉ៅ គួនហ៊ុន រួបបំបែកគ្នាជា ៣ កង ចូងតាមផ្លូវឡើងទៅប្រទះនឹងកងទ័ពហៃហ្វូលិម ក៏ចូលប្រកាប់សម្លាប់គ្នាជាច្របូកច្របល់ ។

ហៃហ្វូលិមក៏ទញ់ទាល់ច្រកផ្លូវនឹងដោះ ចេះតែស្ទុះស្ទាទៅវិញទៅមកជាច្រើនសា ទើបនាំទាហានដែលបានការជាស្និទ្ធ ចំនួន ១០០ បាយនាក់ រត់ប្រញាប់ប្រញាក់ចុះទៅតាមផ្លូវស្រុកលាំភ័ន, ទាហានហៃហ្វូលិមដែលសំខាន់ ក៏បែកខ្ញែកគ្នាទៅដោយខ្លួន ខ្លះវះពួនយកឲ្យរួចតែអាយុជីវិត, គួនហ៊ុននិងតៀវប៉ៅ ក៏ស្រុតមិតលើកទាហានតាមហៃហ្វូលិមទៅ, ហៃហ្វូលិម ក៏រត់កាត់ផ្លូវទៅចូលស្រុកបាន ហើយឲ្យទាហានខ្ពស់បិទទ្វារខ្ជាប់ បំបែកពួកកងទ័ពឲ្យត្រួតត្រាលើបន្ទាយដោយមាំមួន ។

តៀវប៉ៅ គួនហ៊ុន ក៏លើកទាហានបះព័ទ្ធជុំវិញកំពែងស្រុកចំនួន ១០

ថ្ងៃ, ហៃហ្លួលិម នៅសម្ងំមិនចេញច្បាំងសោះ, វេលានោះ មានបម្រើចូលមកប្រាប់ថា មហាឧបរាជ លើកព្យុហទ័ព កដល់ដែនស្រុកនេះហើយ, ឯស្រុកកៃអៀង, អៀងប៉េង និង ចិសៀវតាំង ៣ អនុទ្វីនេះ ចាត់ទាហានឲ្យទៅត្រួតត្រាក្យា ៗ ដូឡុង, គេងជ័, កៀវប៉ៅ និង កួនហ៊ុន ទាំង ៤នាក់ បានដំណឹងដូច្នោះ ក៏នាំគ្នាចេញទៅទទួលគំនាប់ហើយជម្រាបសេចក្ដីថា យើងខ្ញុំបានលើកទាហានមកព័ទ្ធស្រុកនេះទុកជាយូរថ្ងៃហើយ នឹងរកបន្ទោះបន្រ្ទុះចូលទៅពុំបាន ៗ ខុងបេងបានស្ដាប់ ក៏ឡើងជិះសេះគួបបរចូលទៅ មើលឃើញកូមិប៉ានមានទំនងស្រួល ហើយឃើញមានទាហានឡើងរក្សាសើនបន្ទាយមាំមួន ទើបនិយាយនឹងទាហានទាំងពួងថា ស្រុកលាំអ៊ននេះ ជាទីមាំមួនណាស់, បើដូច្នេះ យើងនឹងគិតប្រការម្ដេច ? បើនឹងបង្អង់ទុកយូរថ្ងៃ ក្រែងចូយ៉យនឹងមិនលើកទ័ពកង់ទៅក៏យយកស្រុកហាំនកុងបង់ការ, យើងនឹងមិនខូចអសារទេឬ ? ៗ

គេងជីថា ហៃហ្លួលិមជាសាច់សាលោហិតនឹងចូយ៉យ, បើនឹងចាប់ខ្លួនហៃហ្លួលិមនឹងទាហាន១០០បាន, ចូយ៉យក៏នឹងអស់តម្រិះគិតក្នុងគំនិតតែប៉ុះ ឃើញថា ការយើងដែលធ្វើនោះ នឹងសម្រេចដោយងាយ, ខុងបេង ក៏យល់ឃើញត្រូវ ទើបគិតកលឧបាយឲ្យប្រាប់ទាហានដែលស្និទ្ធ ២ នាក់ ឲ្យបន្លំធ្វើជាទាហានហៃហ្លួលិម កាន់សំបុត្រទៅឲ្យម៉ាជុនហៅហ្វាយស្រុកគៀនស៊ុយ និងស៊ុយលៀង ហៅហ្វាយស្រុកហាំនគេងជា

សេចក្ដីថា ហៃហ្វូលិមឲ្យលើកទាហានមកជួយ, ទាហានទាំងពីរ ក៏លាខុនបេងទៅ ហើយ ខុនបេង ក៏ហៅស៊ុយអៀន និងគួនហ៊ុន គៀវប៉ៅ មកខ្សឹបបង្គាប់ជាសេចក្ដីសម្ងាត់ ឲ្យលើកទាហានតាមទៅ, ខុនបេងនៅជាក្រោយ ឲ្យជញ្ជូនអុសនិងសម្រាម ទៅគរទុកនៅក្បែរកំពែងស្រុក ជាច្រើន ហើយឲ្យយកភ្លើងដុតឆេះឡើង, ពួកអ្នកស្រុកឃើញដូច្នោះ ក៏នាំគ្នាសើចថា ខុនបេង ចប់ប្រាជ្ញាបេះកលឧបាយ អស់សេចក្ដីគិតហើយ បានជាយកភ្លើងមកលាបកំពែងស្រុកយើង ។

ឯស៊ុយលៀង ចៅហ្វាយស្រុកហ័នតេង ដឹងដំណឹងថា ខុនបេង លើកកងទ័ពទៅព័ទ្ធកំពែងស្រុកលាំអ័ន, ហៃហ្វូលិមនៅក្នុងចំណោម, ទើបប្រឹក្សាយល់ព្រមនឹងនាយទាហានទាំងពួងថា ហៃហ្វូលិម ជាសាច់សាលោហិតព្រះចៅប៉ូយ៉យ, យើងនឹងបណ្ដោយនៅស្ងៀម ពុំគួរសោះ, ត្រូវតែលើកទាហានទាំងអស់ទៅជួយការពារស្រុកលាំអ័ន ដើម្បីនឹងរួសរាន់ដោះយកខ្លួនហៃហ្វូលិម បញ្ជូនឡើងទៅស្រុកក្រុង ទើបនឹងរួចទោសខុស, ខណៈនោះ បម្រើចូលទៅជម្រាបថា ហៃហ្វូលិម ឲ្យបម្រើនាំសំបុត្រមកជូន, ស៊ុយលៀង ក៏ឲ្យហៅចូលទៅ, បម្រើក៏ជូនសំបុត្រទៅហើយជម្រាបថា ដ្បិតខុនបេងលើកទ័ពទៅព័ទ្ធស្រុកលាំអ័នជាមាំមួនណាស់, ហៃហ្វូលិម ទើបត្រូវរះប្រើខ្ញុំបាទនាំសំបុត្រមកសុំឲ្យលោកលើកទាហានទៅជួយ ព្រោះឯណោះ ជាទុក្ខព្រួយ ដោយគេទល់ពុំឈ្នះ, សព្វថ្ងៃ បានឲ្យដុតភ្លើងជា

សម្រាស ដើម្បីឲ្យលោកលើកទៅឃើញជាសម្គាល់, ឯការធ្វើមិនឲ្យស-ត្រូវដឹងស្គាល់ ជាយូរថ្ងៃមកហើយ ហេតុម្ដេចឡើយ ក៏លោកមិនលើកទៅជួយ, ទើបប្រើខ្ញុំបាទមកតែខ្លួនមួយដោយប្រថុយវាស្នា, ខ្ញុំបាទក៏ខំកាប់ធ្លារចេញមកបាន ។ ជម្រាបលោក ចៅហ្វាយស្រុកគៀនស៊ុយ ឲ្យលើកទៅជួយផង, បើទៅហើយថា សុំឲ្យគិតតែវាយទ័ពខុងបេងខ្ចប់ប្រសព្វគ្នា ហៃហ្លួលិមនឹងវាយទម្លាយបំពារចេញមកពីក្នុង ចាប់ខុងបេងឲ្យបាន ។

ស៊ុយលៀងបាន ស្ដាប់បម្រើនិយាយ និងមើលតាមសេចក្ដីសំបុត្រ ក៏ចូលចិត្តជាមែនឥតសង្ស័យ, ទើបប្រើបម្រើឲ្យរៀសរើកាន់សំបុត្រនោះទៅឲ្យចៅហ្វាយស្រុកគៀនស៊ុយ, ទទួលបម្រើខុងបេងទៅដល់ម្នាក់ទៀត ក៏ចូលទៅជម្រាបស៊ុយលៀងថា ឥឡូវ ម៉ាដុន ចៅហ្វាយស្រុកគៀនស៊ុយ លើកទ័ពចេញទៅជួយស្រុកលាំអ៊នហើយ, ថា ឲ្យលោកស្រូតលើកតាមទៅឲ្យឆាប់, ស៊ុយលៀង បានស្ដាប់ ក៏ប្រញាប់កេណ្ឌកូនទាហានដែលមានថ្វីដៃលើកចេញចាកស្រុកទៅដល់ទៀបស្រុកលាំអ៊ន ក្រឡេកឃើញពន្លឺភ្លើងជាសម្គាល់ ក៏ខំស្រូតទ័ពទៅ នៅចម្ងាយប្រមាណ ៣០០ សិន (១៦ គីឡូម៉ែត្រ) ក្លួនហ៊ុន ដែលខុងបេងឲ្យទៅចាំស្កាត់នៅទីនោះ ក៏បំ-ផាយសេះដេញទាហានចូលទៅប្រកាប់នឹងចាប់ស៊ុយលៀង ។ ភ័យស្លុតក៏ញាក់សេះរត់ទៅ, ទទួលគៀវប៉ើលើកទាហានស្ទាក់ពីមុខចូលមក កាប់សម្លាប់ទាហាន ស៊ុយលៀងបែកខ្ចាត់ខ្ចាយអស់ ស្លាប់នៅទីនោះ ក៏ច្រើន,

ស៊ិយលៀងនិងទាហានដែលសល់ប្រហែល ១០០ ពាយ ក៏នាំគ្នារត់ខ្ចាត់ខ្ចាយៈទៅស្រុកតាមផ្លូវគាត់, ឯអ៊ុយអៀន ដែលខុងបេងប្រើឲ្យទៅចាំស្កាត់ ក៏លើកទ័ពចូលទៅនៅក្នុងស្រុកហានតេងបាន, លុះឃើញស៊ិយលៀងនិងទាហានទាំងប៉ុន្មានរត់ទៅដល់មុខស្រុក, ក៏ឲ្យយកធ្នូបាញ់បង្រុះបញ្ចេញមក ហើយស្រែកថា យើងឈ្មោះអ៊ុយអៀន ចូលស្រុកបានហើយ ឲ្យប្រញាប់ចូលមកអង្វរលន់តួគំនាប់យើងដោយស្រួលចុះ យើងនឹងទុកជីវិត; ស៊ិយលៀង ឃើញដូច្នោះ ក៏ស្ដុតព្រលឹង ប្រឹងបំផាយសេះនឹងវេះរត់ទៅស្រុកតៀនស៊ិយ ក៏ប្រទះនឹងខុងបេងជិះរទេះតូច ១ កាន់ផ្ចិតពោមសត្វធំ លើកទាហានស្កាត់ផ្លូវចេញមក, ស៊ិយលៀង ក៏បកត្រឡប់សេះរត់គេចទៅម្ខាង, ក្លួនហ៊ុននិងគៀវយ៉ៅ ក៏ព័ទ្ធវាំងចូលមកពីមុខពីក្រោយ, ស៊ិយលៀង ក៏រត់បណ្ដាយវិលវល់ទាល់គំនិតសោះអស់ដៃ លោតចុះពីលើសេះ បោះអាវុធចេញ ចូលទៅគំនាប់ខុងបេង, ខុងបេង ក៏នាំយកខ្លួនស៊ិយលៀងមកបន្ទាយ ហើយសួរអំពីចៅហ្វាយស្រុកលាំអ័ននេះថា តាំងពីហៃហ្វលិមមិនទាន់បានមកនៅ តើនរណាជាចៅហ្វាយស្រុកនៅមុន? ស៊ិយលៀងឆ្លើយថា ចៅហ្វាយស្រុកមុននោះ ឈ្មោះអៀវឡេង ជាក្មួយអៀវហ៊ុ; ឯខ្ញុំបាទនិងអ្នកទាំងពីរនាក់នោះ ក៏ជាមនុស្សត្រូវអាធ្យាស្រ័យគ្នា, ខុងបេងថា យើងចង់ឲ្យអ្នកឯងចូលទៅនិយាយការគិតគ្នានឹងអៀវឡេង ដើម្បីចាប់យកខ្លួនហៃហ្វលិមមកឲ្យយើង ។ នឹងឲ្យបំណាច់រង្វាន់អ្នកឯង

ហើយនឹងតាំងតែងណែងឲ្យអ្នកឯងធ្វើជាធំតទៅ ក្នុងស្រុកលាំអ៊ននេះ, ស៊ុយលៀងក៏ទទួលភាសាខុងបេង ៗ ក៏ថយពលយោធាចេញទៅតាំងបន្ទាយនៅឆ្ងាយពីស្រុកនោះ ២០០ សិន (៨ គីឡូម៉ែត្រ) ។

ស៊ុយលៀង ក៏គំនាប់លាខុងបេង ឡើងសេះចេញទៅដល់ទ្វារស្រុកលាំអ៊ន ហើយហៅអ្នកយាមឲ្យបើកទ្វារ, អៀវឡេង ឃើញហើយ ក៏ម្នីម្នា ដោយត្រេកអរណាស់ រហ័សហៅទាហានឲ្យបើកទ្វារទទួលស៊ុយ-លៀង ៗ ក៏ចូលទៅគំនាប់គ្នាហើយ ស៊ុយលៀងក៏សាស្រាយ និយាយបញ្ចុះបញ្ចូលអៀវឡេង តាមដែលខុងបេងបង្គាប់ ។

អៀវឡេងឆ្លើយថា ព្រះចៅចូយ៉យមានព្រះតេជព្រះគុណនឹងយើងច្រើនណាស់ ដែលនឹងប្រែចិត្តក្បត់តទៅចូលខាងសត្រូវវិញនោះ មិនគួរសោះឡើយ, បើតាមគំនិតខ្ញុំហើយ ត្រូវតែគិតត្រួតកលខុងបេងវិញ ដើម្បីនឹងយកជ័យជម្នះឲ្យបាន, ថាហើយ ក៏នាំស៊ុយលៀងចូលទៅកាន់ហែហួ-លិម នាំពតិមានឲ្យស្តាប់គ្រប់ប្រការ, ហែហួលិមព្រឺតថា ក៏ថា បើដូច្នោះយើងនឹងគិតប្រការម្តេចទៅវិញ ទើបនឹងចាប់ខ្លួនខុងបេងបាន ។

អៀវឡេងថា ខ្ញុំបាទចាំបើកទ្វារទទួលចុះ, បើខុងបេងឃើញចំពោះជាប្រកបដូចសេចក្តីគិតហើយ គង់នឹងលើកចូលមកពុំខាន, យើងនឹងលើកទាហានចោមចាប់ឲ្យបានខ្លួនតែម្តង, ហែហួលិមយល់ឃើញត្រូវ, ស៊ុយ-លៀង ក៏លាចេញទៅឲ្យដំណឹងដល់ខុងបេងឯបន្ទាយ និយាយជម្រាបថា

ខ្ញុំបាទបានចូលទៅគិតគូរគ្នានឹងអៀងឡេង ៗ ទទួលថានឹងចាប់ខ្លួនហៃហូ-លិមជូនលោកឲ្យបាន, តែថាទាហានមានតិច ក្រែងធ្វើការមិនសម្រេចដូចចិត្ត បានជាឲ្យខ្ញុំបាទចូលមកគិតជម្រាបលោកឲ្យជ្រាបថា ពេលយប់នេះនឹងចាំបើកទ្វារទទួលទ័ពខាងលោក ៗ ចូរលោកលើកទ័ពប្រញាប់ចូលទៅក្នុងស្រុកចុះ, ខាងណោះ នឹងជួយព្រួតចាប់ខ្លួនហៃហូលិមឲ្យបាន ។

ខុងបេងបានឮសម្ដីទាំងប៉ុន្នោះ ក៏ក្លែងជាថា ការទាំងនេះ មុខជានឹងសម្រេចសេចក្ដីប្រាថ្នាតាមប្រាជ្ញាអ្នកឯងគិតនោះហើយ, ទើបហៅកួនហ៊ុននិងគៀវប៉ៅចូលទៅខ្សឹបប្រាប់តម្រិះបញ្ចេះជាសម្ងាត់, ហើយចាត់ទាហានឈ្លើយប្រហែល ១០០ បាយ បញ្ចូលគ្នានឹងទាហានពីសាយទៅខ្លះ ប្រគល់ឲ្យកួនហ៊ុននិងគៀវប៉ៅ, លុះដល់ពេលព្រលប់ ក៏បង្គាប់ឲ្យលើកទៅប្រជុំគ្នា, ខុងបេង ក៏ឲ្យហៅស៊ុយលៀងមកផ្ដាំថា អ្នកឯងចូរនាំទាហានអម្បាលនេះចូលទៅមុនចុះ ដើម្បីនឹងឲ្យអៀវឡេងនៅខាងណោះរិះគិតធ្វើការឲ្យមួនមាំ គឺត្រូវនាំទាហានទាំងនេះទៅពួនបង្កប់ឲ្យបាត់ ដល់យាម ២ យប់ស្ងាត់ យើងនឹងលើកទ័ពតាមទៅទៀត, អ្នកឯងចាំធ្ងៀតដុតភ្លើងឲ្យឆេះឡើងជាសញ្ញា ហើយចាំបើកទ្វារទទួលយើងចុះ ។

ស៊ុយលៀងបានឮដូច្នោះ កាលបើមិនព្រមទទួលការ ក៏ខ្លាចខុង-បេងចាប់ពិរុទ្ធបាន ទើបប្រមាណនឹកថា បើកាលណាដល់ពេលកំណត់ហើយ យើងនឹងសម្លាប់ទាហានពួកនេះចេញឲ្យអស់ រួចសឹមបើកទ្វារជា

បន្ទោះឲ្យខុងបេងចូលទៅជាក្រោយ, ស៊ុយលៀងគិតហើយ ក៏គំនាប់លាខុងបេងចេញទៅ, ខុងបេងក៏ប្រើកួនហ៊ុន និងគៀវប៉ៅ ឲ្យតែងខ្លួនបន្លំជាកូនទាហានស្រុកហ៊ានតុង ហើយក៏នាំគ្នាលើកចេញទៅ, ឯអៀវឡេងឈរនៅលើសើនបន្ទាយ ក្រឡេកឃើញស៊ុយលៀងនាំទាហាន ១ ក្រុមចូលមក ក៏គិតសង្ស័យណាស់ ទើបឲ្យទាហានស្ទុះប្រថ្លាស់ចុះទៅទាញស្ពានចងគូចេញ ហើយស្រែកសួរថា ទាហានទាំងអស់នេះ លើកមកពីណា ? ស៊ុយលៀងស្រែកតបថា យើងនាំទាហានស្រុកហ៊ានតុងមកជួយទេតើ ! ហើយក៏យកសំបុត្រចងនឹងចុងព្រួញ បាញ់ចូលទៅ, អៀវឡេង ឃើញសំបុត្រនោះ ក៏យកមកមើល ឃើញសេចក្ដីថា ខុងបេងឲ្យបញ្ចូលទាហានគេផ្សំគ្នា១០០ មកជាមួយ ដើម្បីបញ្ឆុះបញ្ចូលជួយធ្វើការ, ឯខ្លួនខុងបេងនឹងលើកតាមមកជាក្រោយឥឡូវនេះហើយ, អ្នកកុំបីព្រួយចិត្តគិតឲ្យបែកការនេះឡើយ, បើខ្ញុំចូលមកដល់ហើយ គង់នឹងដឹងសេចក្ដីច្បាស់ តាមគំនិតដែលគិត ខ្ញុំនឹងនិយាយឲ្យស្ដាប់ ។

អៀវឡេង បានឃើញសេចក្ដីដូច្នោះ ក៏នាំយកសំបុត្រនោះចូលទៅបង្ហាញ ហែហួលិម ៗ សប្បាយចិត្តណាស់ សម្គាល់ថា ខុងបេងចាញ់តម្រិះខ្លួនដែលប្រើឧបាយកល ទើបបាត់ពលទាហានដែលជាទំនុកទុកចិត្ត ១០០ នាយ ព្រមដោយគ្រឿងសស្ត្រាវុធទាំងឡាយគ្រប់ដៃ ឲ្យទៅពួនបង្កប់ចាំ ហើយបង្គាប់អៀវឡេងឲ្យធ្វើតាមបណ្ដាំថា អ្នកឯងចូរបើកទ្វារ

ស្រុកទទួលស៊ុយលៀនឲ្យលើកចូលមកចុះ, យើងនឹងចាប់ទាហានវាទាំងអម្បាលនោះសម្លាប់ឲ្យអស់ រួចសឹមបើកឲ្យខុនបេងចូលមកទៀត, អៀវឡេងទទួលបង្គាប់ហើយ ក៏ជយប្រញាប់ទៅបើកទ្វារ ហើយស្រែកហៅថា បើទាហានស្រុកហ័នតុង ក៏ឲ្យប្រៀបប្រុងចូលជាប្រញាប់មកចុះ ។

គួនហ៊ិនឮដូច្នោះ ក៏បំផាយសេះស្ទុះចេញទៅមុនស៊ុយលៀង រាងទៅផុតមុខទាហាន ក្រឡេកឃើញអៀវឡេងជិះសេះបញ្ឈរ ក៏បរបំពានត្រង់ចូលទៅផុតទ្វារ យារដាវឡើង កាប់ត្រូវអៀវឡេងធ្លាក់ពីលើសេះស្លាប់. ស៊ុយលៀងឃើញហើយ ក៏ឡប់វិញ្ញាណ ហាក់គ្មានព្រលឹងសោះ បំផាយសេះស្ទុះចេញទៅហួសទ្វារ បំពារទីងចុងស្ពានគូក្រៅ, តៀវប៉ៅក៏ស្រែកសន្ទាប់យ៉ាងខ្លាំងថា នែអាចោរអន្តពាយ ! អាឯងហ៊ានគិតកលឧបាយនឹងបញ្ឆោតមហាឧបកដហើយ ម្ដេចក៏វេះវត់ព័ន្ធទៅឯណា? ក៏យារលំពែងឡើងចាក់ត្រូវស៊ុយលៀងធ្លាក់ពីលើសេះស្លាប់ ។

គួនហ៊ិន ក៏ស្ទុះចូលប្រញាប់ទៅដល់កណ្ដាលស្រុក ត្រលុកដេញកាប់ទាហានទិងអ្នកស្រុកភ្ញាក់ផ្អើលជ្រួលច្របល់ខ្លាំងណាស់ ហើយយកភ្លើងឈូលដុតផ្ទះឆេះឡើងជាសម្គាល់ដែលណាត់គ្នា, ខុនបេងក៏បរពលយោធាចូលស្រុកបានទាំង ៤ ទិសកែវវណែនណាន់ខ្នាន់ខ្នាប់ ។

ហែហ្វូលិម ក៏ភិតភ័យស្ទើរស្លាប់ ប្រញាប់ឡើងសេះទាំងក្លុកក្លាំងពុំដឹងខ្លួន ទំបរស្រូតទៅប្រពាក់ប្រពួនតម្រង់ទៅទិសឯត្បូង ប្រទះលើហ្វូង

កងទ័ពអង់ប៉េងទប់ឃាំងនៅពីមុខ, អង់ប៉េងក៏ស្ទុះគំហុកដេញចូលមក ព័ទ្ធចាប់ខ្លួនហៃហ្វូលិមបាន ហើយខន្ទ្រានស្ទុះទៅចាក់កាប់សម្លាប់រេហ៍ពលហៃហ្វូលិមស្លាប់គរលើគ្នាជាច្រើនណាស់ ។

ឯខុនប៉េងចូលស្រុកបាន ក៏ប្រកាសឃោសនាបណ្ដារាស្ត្រអ្នកស្រុកទាំងអស់គ្នាថា អ្នកទាំងឡាយកល់គ្នា កុំបីភ័យខ្លាចអ្វីឡើយ, វេលានេះហើយ មហាឧបរាជនឹងគ្រប់គ្រងថែរក្សា បីដូចបិតាមាតាព្យាបាលបុត្រ ដើម្បីឲ្យបានសេចក្ដីសុខតទៅ, លុះវេលាព្រឹកឡើង អង់ប៉េង ក៏ចងនាំខ្លួនហៃហ្វូលិមទៅជូន ខុនប៉េង ។ បង្គាប់ឲ្យយកខ្លួនហៃហ្វូលិមទៅឃុំទុកក្នុងរោង, វេលានោះគេងជី ក៏សួរខុនប៉េងថា ស៊ុយលៀងវ៉ាគិតកលឧបាយដោយអាថ៌កំបាំងណាស់ ហេតុម្ដេច បានជាមហាឧបរាជជ្រាបដឹងដល់ ? ខុនប៉េងឆ្លើយថា យើងដឹងយោបល់ជាស៊ុយលៀងល្អៀងចិត្ត មិនមែនជាគំនិតវ៉ាត្រង់ ប្រុងនឹងធ្វើរាជការជាមួយនឹងយើងដោយសុចរិតទេ បានជាយើងគិតក្លែងប្រើវ៉ាឲ្យចូលមកក្នុងស្រុក ប្រាថ្នានឹងឲ្យហៃហ្វូលិមធោតទុកគិតត្រួតកលដល់យើង, យើងត្រូវត្រួតកលដល់វ៉ា ប្រាថ្នាយកជ័យជម្នះតវ៉ាចុងដៃឲ្យបាន, ពួកនាយទាហានទាំងអស់បានស្ដាប់ ក៏នាំគ្នាឱនគំនាប់ក្រាបសិរសា សរសើរថា មហាឧបរាជមានតម្រិះប្រាជ្ញាវិសេសក្រៃពេកណាស់ នឹងរកនរណាមកផ្ទឹមប៉ះក៏ពុំបាន ។

ខុនប៉េងនិយាយការថា វេលានេះ ស្រុកលាំអ័ន យើងក៏ដិះជាប់បាន

ស្រេចហើយ នៅឡើយតែទាហានដែលយើងប្រើកាន់សំបុត្រទៅស្រុកគៀនស៊ុយនោះ ម្ដេចក៏មិនឃើញត្រឡប់មកសោះ តើនឹងជាគ្រោះថ្នាក់យ៉ាងណាទៅដឹងហើយ ? គួរហើយនឹងធ្វើសំបុត្រទៅសួរ ឬលើកកងទ័ពទៅវាយយកស្រុកគៀនស៊ុយតែម្ដងទៅចុះ, ថាតែប៉ុណ្ណោះ ក៏ចាត់ឲ្យឡៅតាយនៅរក្សាស្រុកលាំអ័ន, ចាត់អ៊ុយអៀនជាមេកងកំណាន់ទ័ពស្រួចរួចក៏លើកចេញទៅ, ខុងបេង ក៏លើកតាមទៅជាក្រោយដោយលំដាប់ ។

ចប់ទី ៧១ ។

# អំពីសត្វចិញ្ចឹម

## លក្ខណៈ ក្រយៅគោ - ក្របក - អណ្តាត - ធ្មេញ - អំពីជម្ងឺសា

និង

## រឿងព្រេងទាក់ទងនឹងសត្វគោ

សហជីវិន **ចាប-រិត** គ្រូបង្រៀននៅសាលាបឹងខ្យាង

*ស្រុកកណ្តាលស្ទឹង (កណ្តាល) រៀបរៀង*

## អំពីសត្វចិញ្ចឹម

*នៅក្នុងប្រទេសខ្មែរ មានសត្វចិញ្ចឹមច្រើនប្រភេទណាស់ មិនអាចពណ៌នាឲ្យសព្វគ្រប់បាន ក្នុងទីនេះ នឹងលើកយកតែសត្វគោមកនិយាយដូចតទៅ ៖*

*គោជាសត្វពាហនៈ គេចិញ្ចឹមសម្រាប់យកសាច់ និងដឹកនាំកសិការ ឬកិច្ចការរស់ជាដើម អ្នកស្រុកចិញ្ចឹមគោ·ឈ្មោល·ញី គេរើសលក្ខណៈដូចតទៅនេះ ៖*

*១– មេគោ គេរើសមេគោណា មានសម្បុកពោះ (ពោះធ្លាក់) ក្បាលទ្វើម ចាស់ៗថាគ្រោយកូន ។*

*២– គោឈ្មោល (បុ) គេរើសធ្ងន់ៗ, មាឌធំ, ខ្ពស់, ពោះបីប៉ោះ នោះជាពូជកូនគាត់ឬក៏ជាបុរធម្មតា ។*

លុះបានកូនមក កូននោះ មាឌុកកាត់ទៅបាខ្លះ ទៅមេខ្លះ ។ មេគោមានផ្ទៃពោះ (ដើម) មានចំនួន៩-១០ខែ កាលបើដិតគ្រប់ខែហើយ ម្ចាស់គោនេមិនថ្នាក់ថ្នមវាទេ គេប្រើដឹកនាំឬបំពុល ឲ្យវានឿយហត់ ដើម្បីឲ្យវាលុនពោះ ឆាយនឹងកើតកូន ។

អំពីគោចិញ្ចឹមខ្លួនឯងក្តី ទើបនឹងទិញមកប៉ុក្តី ៖ ត្រូវមានលក្ខណៈ សម្បុរក្រយៅ-ស្នែង-មាឌ-ដូចតទៅនេះ ៖

១–ពាក្យស្លោកថា ក្រយៅបីស្នែង ចូលព្រៃផ្តើង ប្រពន្ធផិត ។

២–ក្រយៅចំស្នែង របស់ចូលឯង ធ្លាក់អឹមនឹងរក ។

## អំពីក្រយៅ

១– កន្ទុយសកន្ទង ក្រៅខ្មៅ "ហៅកាយខ្មាត់" (អាក្រក់) ។

២– កន្ទុយខ្មៅកន្ទង សក្រៅ "ហៅស្រោមនាង" (ល្អ)

៣– ទុលអង្គត ។

៤– ហិតសំពុយ ។

៥– ឆាក់លញ (តាំង៣នេះ) លោកថា អាក្រក់ ។

៦– ចោលពោរ : ក្រយៅ លើគល់កន្ទុយ (អាក្រក់) ។

៧– ទ្រនំទន្លួប : ក្រយៅកណ្តាលខ្នង (ល្អ) ។

៨– ក្រយៅក្រឡាច់ : (នៅលើស្មាធំ) (អាក្រក់) ។

៩– កំពូលប្រាសាទ : (នៅលើបូកធំ) (ល្អ) ។

១០– ក្អែនព្រះ ក្រយៅ នៅមុខផ្ទះក្រោន អមសងខាង ចង ក្រោមផ្ទុះពុំបាន ។ បើមានតែមួយហៅថា "បត់ផ្ទុំ" តៅវិញ (ល្អ) ។

១១– អកចាប់ : ក្រយៅអមស្មាសងខាង (អាក្រក់) ។ តែបើ មានម្ខាងទេហៅថា "នាងផ្អែក" (ល្អ) ។

១២– ស្រីទឹម : ក្រយៅចន្លោះក្អែក (ល្អ) ។

១៣– គមឃ្លាង : ក្រយៅអមកសងខាង ។

១ – រងទឹម ឬ ក្របួចកន្ទុះ : ក្រយៅនៅលើក ។

១៥– ឈ្មាន់ឡើង : ក្រយៅឃ្លៀកសងខាង ។

១៦– អមសំពៅ : ក្រយៅពោះតាំងសងខាង ។

១៧– សៀតថ្កា : ក្រយៅគល់ត្រចៀកសងខាង ។

១៨– កំងទុក : ក្រយៅគល់កន្ទុយសងខាង ។

១៩– ក្រយៅកំណើត : ក្រយៅកណ្ដាលក្បាល ។

២០– ហិតសំអុយ : ក្រយៅចុងច្រមុះ (មិនល្អ) ។

២១ ក្រយៅបង្រុះ : ក្រយៅកណ្ដាលខ្នង ចំលិន ។

២២– បង្ហូតប៉ោល : លើខ្នងគ្មានក្រយៅ ។

២៣– ដណ្ដើរកែវ : ក្រយៅជើងមុខ ក្រោមជង្គង់ពីខាងក្រោយ (ល្អ)

២៤- ធាក់លាញ : ក្រយៅជើងក្រោយក្រោមជន្ទង់ពីខាងក្រោយ (មិនល្អ) ។

២៥- រងលាមក : ក្រយៅក្រោមក្ដិតអាចម៍ (មិនល្អ) ។

២៦- រំសាយសក់ : ក្រយៅក្រោយប្រទូលក្បាល ។

លក្ខណៈក្រយៅ ដូចពោលមកខាងលើនេះ មានល្អ មានអាក្រក់ នឹងមិនល្អ មិនអាក្រក់ (មធ្យម) ចំពោះក្រយៅណាល្អ នឹងអាក្រក់មានដាក់សេចក្ដីជាសម្គាល់ហើយ ។ ឯមិនល្អមិនអាក្រក់ (មធ្យម) គ្មានដាក់សេចក្ដីជាអ្វីទេ ។

អំពីសម្បុរបោរមិនហ៊ានល្បួ : គោណាសម្បុរខ្មៅក្ដី ចំប៉ាក្ដី ក្រហមក្ដី ហើយមានពពាល ដូចដំនីរ-ព័ទ្ធខ្នង-លោង-ត្រគាក-ក-មុខ-ពព្រឹកពព្រាក់ គោបែបនេះ ចោរមិនហ៊ានល្បួទេ បើចោរណាហ៊ានល្បួ ចោរនោះត្រូវអស់លក្ខណ៍ ។

អំពីស្នែង : ត្រូវរើសស្នែងប្រក់ទាត គឺស្នែងទាំងពីរ ឈរ-រង្វង់ចុង- ចូរកុំយកស្នែងកែក គឺស្នែងមួយចង្អុលដី. ស្នែងម្ខាងចង្អុលទៅលើ ។ ស្នែងបែបនេះ ចាស់ៗលោកថា គោខូច គាប សមនឹងភាសិតបុរាណថា : «គោស្នែងកែក មនុស្សស្រពៀងភ្នែក កុំយកខ្លួនបៀត» (ចរៃជ្រ) ។ បើមនុស្សណាមុខវែង ដូចមុខគោ ក៏គេថា ខូច-គាប-ដែរ ដូចភាសិតថា "រមនុស្សមុខគោ កក្កុកក្រក សម្ដេីស្អកៗ ភ្ជូត

វកវី" ពាក្យស្លោកមួយទៀតថា "ពុតសិស្សគ្រូបី ពុតស្រីប្តីលែង ពុតគោជ្រលែង ពុតខ្មែរបន់ម្ចាស់" ។

ពន្យល់: ពាក្យជ្រលែង គឺម្ចាស់បង្ហាត់ បង្ហឹកមិនបាន លែងចោល ។

អំពីគោទៀងក ឬ គោខ្មៅ : បុរាណច្រើនយកជាដង្វាយគ្រូរៀនមន្ត-អាគម ផ្សេង ៗ ឬក៏មានឈឺធ្ងន់ៗ បន់ថ្វាយខ្មោចឬអ្នកតា គេច្រើនយកគោខ្មៅឬគោទៀងកទៅថ្វាយ ។ សឹងជាប់ជាទំនៀមថា "ក័យថ្វាយគោ សេះជើងស ថ្វាយមាន់" ។

## លក្ខណៈ ក្រចក អណ្តាត ធ្មេញ :

បើកាលណាធ្នូក្រចកជើងមួយក្តី ពពាលកជើងមួយក្តី ចាស់ៗថា "ចង្រៃ" ។ "បើធ្នូក្រចកជើងទាំង ៤ ក្តី ឬពពាលកជើងទាំង ៤ ក្តី មិនជាអ្វីទេ" ។

អណ្តាត : មុននឹងទិញគោ អ្នកទិញគេចាប់មាត់គោហែកមើលអណ្តាត បើឃើញពណ៌សឬពណ៌ក្រហម លោកថាអណ្តាតពាំភ្លើង "ចង្រៃ" ។

អំពីធ្មេញ: ត្រូវពិនិត្យមើលធ្មេញទៀត បើឃើញធ្មេញមុខមាន ៨ គេចាត់ថាគោនោះមានលក្ខណៈត្រឹមត្រូវ ។ បើឃើញធ្មេញ ៧ ចុះមក ឬក៏ធ្មេញ ៩ ឡើងទៅលើ លោកចាត់ថាគោនោះគ្មានលក្ខណៈត្រឹមត្រូវ (ចង្រៃ) ។

អំពីបង្ហាត់ឱ្យស្តាប់ភាសាមនុស្សនឹងពង្រាប.–

គោទើបនឹងទិញមកថ្មីក្តី គោកូនក្រោល បង្គោលស្នឹងក្តី ត្រូវប្រកបដោយលក្ខណៈ ក្រយៅសម្បុរ-ស្នែង-ភ្នេញ-អណ្តាត ដូចពោលរួចមកហើយ ៗ ទើបបង្ហាត់វាឲ្យចេះស្តាប់-ស្គាល់-ដូចពាក្យ "ប្ហូ" ឈប់ "ប្ហឹ" ទៅ ៗ ឲ្យស្គាល់ស្តាំ-ឆ្វេង-ដើរតន្ទង-ដើរសា ៗ "ជិតៗ" មកជិតម្ចាស់ ៗ រីលៗ ឲ្យគោត្រឡប់ទៅខ្វាង ដែលខ្លួនមិនចង់ឲ្យទៅៗ "ដើរ ៗ ! !" ឲ្យលើកជើង ៗ

ជាពិសេសគឺឲ្យវាស្គាល់ចាំឈ្មោះវាដូចជាគេហៅថា៖ អាពាល-អា-ត្នោតអាចម្យ៉ា-អាពពករសាត់ អាក្រឡាញ់ ។ល។ ជាដើម បន្ទាប់មកគេយកគោនោះទៅពង្រាបឲ្យចេះអូសរនាស់-ទង្គ័ល-រទេះ ឲ្យស្គាល់ថាឆ្វេងស្តាំ-ម្ចាស់ញាក់ខ្សែខាងនេះ ត្រូវមកខាងនេះ ៗ ឲ្យស្គាល់តន្ទង-ដើរសាបត់-បែនពិតប្រាកដទើបបង្ហាត់ទឹមឲ្យថ្មើក សាំលែងផ្អើលលែងបោល-លែងលុតក្រាប ឬគៀចជេក ៗល ៗ

ម្យ៉ាងទៀត គោបង្ហាត់មិនបាន ចេះតែលុតក្រាបឬជេក អ្នកបង្ហាត់គេស្គាល់ក្រយៅខ្វប គេយកជន្លួញដាក់ចំក្រយៅខ្វប គោក៏ស្ទុះឡើងដើរជម្ពា ៗ

ម្យ៉ាងទៀត គោណាប៊ិនទាញខ្សែ-កន្ទុះ ដាច់ញឹកញាប់ ចាស់ៗថាមកពីមានក្រយៅមួយ ហៅថា "ហាំតហាំភុយ" ស្ថិតនៅចុងប្រមុះ

បានជាគោប៉ិនទាញណាស់ ។

អ្នកប្រាជ្ញ . បានតែងកាព្យមួយឈ្មោះ " គាព័ទ្ធស្នឹង " ។ ប្រៀប ទៅនឹងគោដែលគេបង់នៅនឹងស្នឹងមួយវិលចុះ-ឡើង ប្រទាក់ទាក់ខ្សែនៅ តែកន្លែងមួយ ។ ចាស់ៗប្រដៅក្មេងឲ្យចេះគិតគូរ ធ្វើអំពើណា ដែលមានប្រយោជន៍ ដុំកំភួន-កុំធ្វើការឥតប្រយោជន៍ លោកប្រៀបទៅនឹងគោថា "រទេះបាក់មិនគិត ទៅគិតឯគោលួចដាំង ។

បញ្ជាក់: " គោលួចដាំង " គឺគោបញ្ចេញអង្គជាតិ ។

អំពីកន្លែងចងគោ.— គេធ្វើក្រោលឃ្នង សង់ជាពេង នៅក្បែរផ្ទះឬវាលឆ្ងាយពីផ្ទះក៏មាន ទីកន្លែងនៅ ត្រូវសំអាតជានិច្ច កុំឲ្យមានអាចម៍ឬទឹកនោម ។

អំពីការថែទាំឱ្យស៊ីស្មៅ.— ការឲ្យស៊ីស្មៅត្រូវឲ្យឆ្អែតស្កប់ស្កល់ជានិច្ច ទើបគោមានកម្លាំងធ្វើការ ចៀសវាងតែស្មៅខ្ចី ត្រកួននិងបណ្ដាលទៅពកគរួស (ចុះសាច់) ។

របៀបឱ្យស៊ីគ្មានទោស.— គឺស្មៅ ៤ ភាគ ស្លឹកឈើផ្សេងៗ ១ ភាគ ចំបើង១ភាគ គោនឹងធាប់ធំធាត់ហើយគ្មានជម្ងឺផង ។

អំពីការថែទាំមុននឹងឈឺ ; ១— ម្ចាស់ត្រូវថែទាំជម្ងឺផ្សេងៗ ។ ២— ការពារឲ្យធាប់ធំធាត់ឲ្យជ្រុះរោមចាស់-ដុះរោមថ្មីឡើងវិញ ។

ថ្នាំឃកមកការពារនោះគឺ ១ ទឹកនោមមនុស្ស ២— វល្លិបណ្ដូល

ពេជ្រ ៣- ផ្លែក្រូចសើច ៤- ល័ក្តស្រម៉ ៥- ចំណាំងស្បែង យក មកពុះ-ចិញ្ច្រាំ ត្រាំនៅក្នុងក្រឡ សម្រាប់នោមដាក់រាល់ៗថ្ងៃ ។

ពិធីប្រែក : គេយកឫស្សីប្រុំនកដៃប្រវែង ១ គក់ មានប្រហោង ក្នុងផងមកកាប់បញ្ចូតចិតចៀរឲ្យស្អាត រួចចាក់ទឹកនោមទៅក្នុងបំពង់ បន្ទាប់មកគេចាប់គន្ទុះគោផ្ងើយទៅលើ រួចសិកបំពង់តាមមាត់ ទឹកនោមក៏ហូរចូលទៅក្នុងពោះគោទៅ ការប្រែកនេះ ត្រូវធ្វើរាល់ព្រឹក-ល្ងាច ឥតកំណត់ពេលឈប់ឡើយ លុះត្រាតែគោធាត់ស្រួលខ្លួន ហើយ ទើបឈប់ ។

អំពីគោកើតដំបៅ : បើគោកើតដំបៅនៅត្រង់សាច់ណាមួយ ត្រូវ ការពារកុំឲ្យដង្កូវរុយពង កម្រទឹងមើលជាណាស់ ។

បើបានជាដង្កូវរុយពង ដាក់ហួសទៅហើយ ត្រូវយកថ្នាំទម្លាក់ ដង្កូវសិនសឹមមើលជាខាងក្រោយ ថ្នាំទម្លាក់ដង្កូវនោះគឺយកសាចម៉ខៀវ ក៏បាន យកទឹកថ្នាំជក់ទៅចាក់បំលើពីមុខដំបៅក៏បាន ។

ពិធីផ្សះដំបៅ : យកទឹកសម្ងួប ឬ ផ្សម មកចាក់ចំមុខដំបៅ ៤- ៥ដង មុខដំបៅនឹងសះជាពុំខាន ។ បើមិនសះទេត្រូវយកដើមធ្នៃ ស្រែងមកចិតចំណិតតូចៗ ដុតយកផ្សែងបង្ហុយតាមបំពង់ឫស្សីវែង ប្រវែង២-៣ហត្ថ ដាក់ឲ្យចំមុខដំបៅក៏បាន ដំបៅនេះត្រូវបង្ហុយព្រឹក ល្ងាចរៀងរាល់ថ្ងៃ ដំបៅមុខជានឹងសះពុំខាន ។

**សូមបញ្ជាក់ថា:** *មុននឹងបង្ហុយផ្សែង សូមយកសំបកគរណ្ដាល ឬទទឹងសំបកស្វាយព្រៃ មកដាំឲ្យពុះ ទុកឲ្យត្រជាក់ឧណ្ហៗ យកទឹកនេះទៅលាងមុខដំបៅឲ្យស្អាត ដើម្បីឲ្យអស់ក្តួល-ខ្ទុះ-អេល ទើបបង្ហុយផ្សែងជាខាងក្រោយ ។ ធម្មតាគោ តែមានដំបៅបេះតែលិទ្ធ ឬត្រដុះមុខដំបៅនឹងគល់ឈើ លុះរលួយអស់ ដូច្នេះត្រូវចងឬស្សី ឧទាហរណ៍ បើដំបៅខាងឆ្វេង ចងឬស្សីពីខាងស្ដាំប្រវែងខ្លួនវា ដើម្បីកុំឲ្យវាលិទ្ធបាន គឺចុងឬស្សីម្ខាងភ្ជាប់នឹងកន្ទុះ ចុងម្ខាងចងភ្ជាប់នឹងពោះ ។*

*ម្យ៉ាងទៀត គោច្រើនគិល ឡេមឡាអបន្តិចក្នុងពេលមានដំបៅ សមនឹងពាក្យស្លោកបុរាណថា "គោដំបៅខ្នង ក្អែកហើរលង រំសាយ-កន្ទុយ" ។*

**អំពីថ្លោះឬគ្រេច:** *បើគោថ្លោះឬគ្រេច ត្រូវយកប្រផេញញី-ឈ្នោល ១ ត្រលែងវែក ១ ពងមាន់ ១, ដីដំបូក ១, មកបុកលាយគ្នា រួចយកបន្ទោះឬស្សីតូចៗ វែងជាព្រលប្រវែងតែត្រង់កន្លែងឈឺ រួចយកកំណាត់ដាក់ថ្នាំពីលើ យកទៅរុំភ្ជាប់នឹងជើងថ្លោះ ទើបគេយកព្រួលរុំព័ទ្ធពីលើថ្នាំតទៅទៀត រឹតរុំត្រូវប្រយ័ត្នកុំឲ្យត្រូវទឹក ហើយត្រូវរុំអស់រយៈ ២-៣ ថ្ងៃ ទើបស្រាយម្ដង ។*

**អំពីជម្ងឺសា:** *បើគោឈឺ ច្រើនឈឺពោះម្យ៉ាងហៅថា "សា" បើមនុស្ស វិញគេហៅថា "ខ្យល់" ។*

ជម្ងឺសាគោ មានច្រើនយ៉ាងណាស់គឺ: សាទឹក សាភ្លើង ។ល។

សាទឹក : ចាប់ឈឺធ្វើឲ្យស្រប់លែងស៊ីស្មៅ ហើយពោះ ។ល។

សាភ្លើង : ធ្វើឲ្យប្រកាច់ក្តៅឥន្ទះអន្ទង ធាក់-ជល់-វ៉ៃមនុស្ស-ពកអាចម៍-សំកុក... ។ល។

ពិធីការពារ : កាលបើដឹងថា កើតជម្ងឺសាហើយ ម្ចាស់គោត្រូវទៅអញ្ជើញគ្រូស្តោះសាឲ្យមកពិនិត្យ ទីងស្តោះផ្លុំ ដោយពិធីសូត្រគាថាដូច្នេះ : "ឧមៈប្រសិទ្ធិស្វស្តី អញ្ជើញជីមានពារពិលាយាត្រា ព្រះបារមីស្ងួរ អ្នកបន្ទួលប្រើអញស្តោះសាទឹក-សាភ្លើង សាចំបើង សាហើម សាហាល់ សាប៉ុក សាទល់ សាអង្គុយ សាម្សូលខ្ទួន ទើបគ្រូប្រើអញស្តោះពីដើមក្របក គ្របក្នែក ចង្កែកដើមដោះ បង្ហោះ ទងស្លួត កុំបីពាំងរែត កុំបីពីងរួត លើព្រះមន្តគ្រូអញ ឧមៈសិទ្ធិស្វាហាៈ បណោះចេញទៅ" ។

គាថាបោសគំពេលគោ : "ទិទិ ពុទ្ធោ សុហាពុទ្ធោ (៣ចប់) (ពីរឿងជម្ងឺសាទីងបាលីស្តោះ សាបោសគំពេលគោ បានដឹងពីព្រះភិក្ខុឈឹម វត្តវិហារបំទមាស) ។

អំពីជំនឿផ្សេងៗ ដែលជាប់ទាក់ទងនឹងសត្វគោ : ចាស់ៗជំនាន់ដើម មានជំនឿថា គោឈឺក្តាត់ផ្សេងៗ មកពីខុសទីងប្រេញគង្វាល (ព្រោះនៅផ្ទះមួយៗ ពុំទៃមានច្រេញគង្វាលនៅចាំថែរក្សាគោជានិច្ច

កាល ១- ថែរក្សាកុំឲ្យមានជម្ងឺ ២- ថែរក្សាកុំឲ្យចោរលួច ។

ព្រោះហេតុនោះហើយ បានជាគេឃើញមានធ្វើប្រមអំពីឫស្សីវែងល្មមសម្រាប់ទ្រស្លាធ៌ដូង ១ បំពង់ទឹក ១ រំពាត់ ១ ដោតធូប ២-៣សរសៃ បាយសម្ងំចំណីខ្ចប់ជាកញ្ចប់តូចៗ ដាក់លើស្លាធ៌ដូងនោះ (ប៉ុន្តែគ្មានស្លាធម៌ទេ) សម្រាប់លើកថ្វាយដល់ម្រេញគង្វាលរៀងរាល់ថ្ងៃសីលទីងពេញបូណ៌មី ។ល។ បើបានធ្វើដូច្នេះហើយ សត្វទាំងឡាយមុខតែបានសេចក្តីសុខ-ចម្រើនគ្រប់ៗគ្នា ។ បើថែជាមិនបានធ្វើដូចពោលមកខាងលើទេ សត្វទាំងឡាយនៅក្នុងផ្ទះ ច្រើនឈឺ-ងាប់គ្រោះថ្នាក់-ជោរះ-ធ្លាយជាមិនខាន ។

អ្នកជឿពិតប្រាកដ ព្រមទាំងធ្វើរណ្តាប់រណ្តាបូជា ម្រេញគង្វាលដូចនិយាយរួចមកហើយរមែងឃើញភ្នែកស្រស់ ។ ដូចតាម្នាក់ឈ្មោះពៅ អាយុ ៨០ ឆ្នាំ នៅភូមិអំពៅព្រៃ គាត់ជាអ្នកចិញ្ចឹមគោឈ្មោល-ញីមួយហ្វូងធំ គាត់សង់រោងមួយទទឹង ៧ម. បណ្តោយ ១០ម. ប្រក់ស្លឹកសម្រាប់ធ្វើជាក្រោលគោ ពល់ៗថ្ងៃសីល ទីងថ្ងៃពេញបូណ៌មី គាត់រៀបចំប្រម-ស្លាធ៌ដូង-ទំ-ចំណី ថ្វាយដល់ម្រេញគង្វាល ដើម្បីឲ្យជួយថែរក្សាគោគាត់ ។

ថ្ងៃមួយនៅវេលាយប់ស្ងាត់ គាត់ដេកមួយស្របក់ នៅលើខ្ទមមួយក្បែរក្រោលគោ លុះភ្ញាក់ឡើងគាត់ខ្ញុំមាត់ បៀកស្លាបរិភោគ ស្រាប់តែ

ពេលភ្ញែកទៅ ឃើញមនុស្សម្នាក់ មាឌធំខ្មៅ-ខ្ពស់-សក់ក្រញាញ់ ខុសពីមនុស្សធម្មតា មានស្ពាយបាយសំណុំ ទឹក ១ បំពង់ រំពាត់ ១ ដើរក្បែរក្រោលគោ ៗក៏ផ្អើលឈូឆរនៅក្នុងក្រោល មួយសន្ទុះមកទៀតមនុស្សក៏ស្រាប់តែបាត់នោះ ឹង មិនដឹងជាទៅទីណា ។ មួយសន្ទុះមកទៀត តាពៅដើរមើលសម្រាស់ឬស្សីព័ទ្ធជុំវិញរោងគោ និងទ្វារច្រកចេញចូល ពុំឃើញរបើកបន្តិចសោះ ។

ក្នុងរឿងនេះ តាពៅនឹកឆ្ងល់ក្នុងចិត្តណាស់ របងក្តី ច្រកចេញចូលក្តី គ្មានរបើក-មនុស្សចូលមកនោះ មាឌធំ ខ្ពស់-ខ្មៅ ប្លែកពីធម្មតាម្ល៉ោះហើយគាត់សម្រេចចិត្តថា “ច្បាស់ជាម្រេញគង្វាលហើយ” ។

បន្ទាប់មកទៀត តាពៅយកធូប ៣ សរសៃ អុជបន់ស្រន់អង្វរម្រេញគង្វាល ច្រើនប្រការណាស់ ។ តាំងពីថ្ងៃនោះមក តាពៅប្រគល់កាយថ្វាយខ្លួនលើ “ម្រេញគង្វាល” ឥតរាករេ គាត់ចាប់ធ្វើស្លាធរជូនខ្លួ ១ ប្រម១ រំពាត់១ បំពង់ទឹក១ យ៉ាងថ្មី ៗ សម្រាប់បូជាម្រេញគង្វាលម្តងទៀត ។ តាំងពីពេលនោះមក តាពៅលែងព្រួយនឹងជម្ងឺនឹងចោរលួចគោឡើយ ។

មួយទៀត ចាស់ ៗ ថា បើនៅពេលកំពុងភ្ជួររាស់ក្នុងស្រែ គោនោះមានគ្រោះថ្នាក់ ដូចជាប្រកាច់ ហើមពោះ ថ្ងោះ គ្រេច ៗ ល ។ ដែលខ្មែរយើងហៅថា “សា” គេនិយមជឿថា កម្ចាស់ស្រែ

មិនបានរៀបចំធ្វើប្រេម សែនក្បាលមាន់ ចំពោះព្រះភូមិដែលនៅថែរក្សាស្រែនោះ ។

មួយទៀត បើឃើញប្រផ្នូលសត្វក្អែកមួយ វត់ធ្លាប ៗ ចូលទឹកចុះឡើង គេនិយមជឿថា ព្រះភូមិវត់ចូលទឹក ប៉ុន្តែ ពុំឲ្យមានគ្រោះថ្នាក់អ្វីដល់អ្នកស្រុកទេ ។

របៀបលេងភ្នាល់បរគោលឿនៈ- ក្នុងសម័យ៨០ ឆ្នាំកន្លងមកហើយ ព្រះភិក្ខុ នាមយ៉ែម នៅវត្តវិហារបិទមាស បានមានពុទ្ធដីកាថា កាលលោកនៅកម្លោះ លោកជាជើងឯកខាងបរគោលឿន ទោះនៅទីស្រុកណា ក៏មានអ្នកបរគោលឿនសឹងតែគ្រប់កន្លែង ក្នុងពេលលេងម្តងៗត្រូវដាក់ប្រាក់ភប់ពាន់រៀលក្នុងប័ក្ខម្ខាងៗ ។

ឯរបៀបភ្នាល់គោនោះ ត្រូវបរភ្នាល់ដោយទឹមរទេះសាឡី បរនាស់ក៏មាន ។ រទេះ-នាស់ទាំងនោះត្រូវតុបតែងដោយរំយោលក្បូ ជាតំរុំ អង្កាំ-ចង្ក្រងចងនៅចុងបន្ទោល ចង្កំស្រោបតាមដង ។

តុបតែងគោដោយមានជាតិក្រហមប៉ាំនមុខ -ស្រោបស្នែង-អង្កាំជាក់តាមហាមជាតិ ចង្ក្រងចង កកន្ទុះប្រទៀវ-ខែ្ស ធ្វើសុទ្ធតែវេញអំបោះម្តៃ ។

ពិធីរើសគោយកទៅភ្នាល់ :- គេរើសជើងមុខ ជើងក្រោយ កងវែង ស្រាវ កន្ទុំង-មាំ -ជើងខាងមុខឈរឡើង កុំឲ្យរមក្រោម គឺថាឲ្យរត់ស្មើគ្នាងពីស្មាលើចុះរៀងមក គោលឬវត់មិនសូវហត់ ដងខ្លួនយក

កន្សួល កុំឲ្យពោះធំ "ធ្ងន់ពោះ" បោលមិនលឿន ។

មុននឹងបប្រណាំងមួយថ្ងៃ គេត្រូវរកស្មៅឲ្យវាស៊ីយ៉ាងស្កប់ស្កល់ ហើយឲ្យគ្រូមកកន្លក់ប្រសិទ្ធី ដោយរៀបចំសែនព្រេន មានពៃ បាយសី លើកកសី បង់ផ្លង់ទឹក សូត្រលាស់ទឹកដៅលើគោបម្រុងនិងទៅក្ពាល់នោះ ។

លុះដល់ពេលបប្រណាំង គូប្រណាំងទាំងសងខាងសុទ្ធតែមានគ្រូ ចាំបង់ផ្លង់ទឹកដូចៗគ្នា អ្នកបក្ខម្ខាងមិនអាចមកពាល់'ឬ កាន់ខ្សែគោអ្នកម្ខាងបានឡើយ គេខ្លាចធ្វើមន្ត ខ្លាចដាក់ថ្នាំ ខ្លាចសណ្ដំ គោគេឲ្យចាញ់ ។

រីឯអ្នកបរត្រូវរើសរកអ្នកជំនាញខាងបរ និងត្រូវស្លៀកពាក់តាមទំនៀម " គឺស្លៀកសំពត់អន្ទូញចង្កៀន កន្ទ្រីញញាត់ទៅខាងលើត្រឹមជង្គង់ បញ្ចេញជើងខោខ្លីទ្រនាប់មកខាងក្រៅ ពាក់អាវបំពង់ ស ហោប៉ៅ ក្តោងធំ ជួតក្បាល កាន់ជន្ទ្រញចង្កូមួយ ធ្វើឫកពាជាអ្នកសង្ហាអង់អាច ។

បន្ទាប់មកគេប្រមូលគ្នា ទាំងពីរខាងមកកំណត់ទីកន្លែង ដែលជាដើមទី និងចុងទីដែលត្រូវបរ ដោយអ្នកអង់អាចម្នាក់បានឡើងប្រកាសប្រាប់ទីកន្លែងនិងដោតតម្រុយនៅខាងមុខ ។

« បើ គោណាតែបោលចាញ់គោម្ខាង ត្រូវសន្មត់ថាចាញ់ » ។

# រឿងព្រេងដែលជាប់ទាក់ទងនឹងសត្វគោ[១]

ចំនៀមខ្មែរយើងចាស់ៗបានតំណាលថា មានមាណពម្នាក់បានរៀបអាពាហ៍ពិពាហ៍នឹងស្រីម្នាក់ តែមាណពនោះគ្មានកូនមួយទាល់តែសោះ ថ្ងៃមួយបាននាំភរិយាទៅបន់សុំកូននៅនឹងលោកតាដើមជ្រៃ ។ លុះអង្វរយូរមក ប្រពន្ធមាណពក៏មានគភ៌៧ខែ នាងនឹកក្តុកចង់បរិភោគផ្លែស្វាយខ្ចីអត់ទ្រាំពុំបាន ចេះតែទៅអង្វរករប្ដីញឹកញាប់ម្ដងជាពីរដង ប្ដីមិនព្រមរកផ្លែស្វាយឲ្យទាល់តែសោះ ដោយមាណពជាប្ដីបានចាំបណ្ដាំហោរ កាលដែលនាំគ្នាទៅបន់សុំកូនថា "បើនាងជាប្រពន្ធមានគភ៌ពេលណា ត្រូវមានគ្រោះថ្នាក់ដល់ជីវិតនឹងផ្លែស្វាយខ្ចីពុំខាន"

ពេលមួយជាឱកាសដ៏ស្ងាត់ មាណពទៅព្រៃបាត់ទៅ នាងដើរលេងក្បែរផ្ទះ ងៀងមើលឆ្វេង-ស្ដាំ ឃើញផ្លែស្វាយខ្ចីចំនួន ១ ឬ ២ ប៉ុណ្ណោះ នាងរកចំពក់ឈើកាន់បេះពុំបាន ក៏ដាច់ចិត្តឡើងបេះផ្លែស្វាយ ។ លុះឡើងបានបន្តិចក៏ស្រាប់តែរបូតជើង-ដៃធ្លាក់មកដី ពេលនោះនាងដួលសន្លប់បាត់ស្មារតី (ស្លាប់ក្នុងខណៈនោះទៅ) កូននៅក្នុងផ្ទៃក៏ប្រសូតចេញមក ។ កូនច្បងជាសត្វគោ កូនប្អូនជាមនុស្ស ។

មាណពជាឪពុក បានចិញ្ចឹមកូនគោនិងកូនមនុស្សដោយដើររកសុំទឹកដោះអ្នកស្រុកឲ្យកូនបៅ ប៉ុន្តែអ្នកស្រុកមិនព្រមឲ្យទាល់តែសោះ ។ ចេះតែនាំគ្នាដេញចេញមិនឲ្យចូលស្រុកភូមិខ្លាចចង្រៃ ។

១ រឿងព្រះគោព្រះកែវដែលអ្នកនិពន្ធសរសេរតែងនេះ គឺសរសេរតាមពាក្យអ្នកស្រុក ។

កុមារច្បង មានរូបជាគោឲ្យឈ្មោះ ព្រះគោ កុមារប្អូនមានជាតិជាមនុស្សឲ្យឈ្មោះថា "ព្រះកែវ" ពេលណាព្រះកែវស្រេកទឹកដោះ ព្រះគោក្អួតទឹកពីក្នុងពោះឲ្យព្រះកែវបៅផ្អែតស្កប់ស្កល់ ។

ថ្ងៃមួយ ពួកអ្នកស្រុកនាំគ្នាដេញតាមព្រះគោ ដើម្បីសម្លាប់យកសាច់បរិភោគ ខ្វះនាំគ្នាដេរថា "អាសត្វចង្រៃ" លុះពួកអ្នកស្រុកមកជិតដល់ហើយ ព្រះគោប្រាប់ព្រះកែវឲ្យតោងខ្លួនកន្ទុយឲ្យជាប់ រួចក៏ហោះផ្លោះរំលងក្បាលអ្នកស្រុកផ្ដោះត្រង់ទៅលើអាកាស ។

រីឯមាណពជាឪពុក មកពីព្រៃវិញរកកូនពុំឃើញ ក៏ដើរស្រែកដង្ហោយហៅកូនគ្រប់ចន្លោះភូមិ-ព្រៃព្រឹក្សា ដោយសេចក្ដីអាល័យខ្លោចផ្សាចិត្តកូន ក៏ដួលដេកស្លាប់ក្នុងព្រៃទៅ ។

ស្ទះទុកត្រឹមនេះ និយាយពីព្រះគោ-ព្រះកែវ ដែលហោះទៅជាមួយគ្នា ក៏បបួលបង-ប្អូនចុះសំចតនៅកន្លែងមួយ ជិតស្រះស្រង់នៃព្រះចៅប្រទេសខ្មែរ ។ លុះនៅយូរឆ្នាំបានសេចក្ដីសុខសាន្ត នៅទីនោះមក ព្រះកែវជាប្អូនក៏កាន់តែមានវ័យធំឡើង ពេញកម្លោះ ។

ថ្ងៃមួយ ព្រះរាជបុត្រី ៧ ព្រះអង្គនៃព្រះចៅខ្មែរ បានចេញទៅស្រង់ទឹកស្រះ នោះព្រះកែវក៏ចុះទៅលេងទឹកស្រះជាមួយព្រះរាជបុត្រីនោះដែរ ។ ព្រះកែវនិងនាងទៅ បានចិត្តស្នេហានឹងគ្នា ប្រឡូកប្រឡែងញោចគ្នាទៅវិញ-នៅមកយ៉ាងស្និទ្ធស្នាល ។

រឿងនេះបានទ្រង់ជ្រាបដល់ព្រះចៅជាបិតា ព្រះអង្គទ្រង់ព្រះពិរោធយ៉ាងខ្លាំង ហើយឲ្យចាប់នាងពៅនិងព្រះកែវ យកទៅបំបរបង់ឲ្យទៅនៅស្រុកបច្ចន្តគ្រាម ។

ថ្ងៃមួយព្រះចៅក្រុងសៀម ផ្ញើសារមកព្រះចៅស្រុកខ្មែរថា ព្រះអង្គមានបំណងចង់លេងភ្នាល់ទូទៅ ។

ពេលនោះព្រះចៅស្រុកខ្មែរ មានសេចក្ដីបារម្ភក្នុងព្រះទ័យ មិនដឹងជាបាននរណាជួយទំនុកបម្រុងក្នុងរឿងនេះ ព្រះអគ្គមហេសីទូលព្រះរាជាថា "សូមទ្រង់ព្រះមេត្តាប្រោស នៅក្នុងរឿងនេះចាំទូលព្រះបង្គំជាខ្ញុំទៅស្នើការនិងព្រះកែវនិងនាងពៅសិន ក្រែងលោគេជួយកើត" ។ លុះគិតរួចហើយព្រះអគ្គមហេសី ក៏ទៅកាន់សំណាក់ព្រះកែវនិងនាងពៅដោយរួសរាន់ ហើយក៏និយាយរឿងរ៉ាវប្រាប់នាងពៅដោយសព្វគ្រប់ ។ នាងពៅនិងព្រះកែវ សុខចិត្តទទួលភារៈនោះនៅលើខ្លួន ខណៈនោះព្រះកែវទៅនិយាយនិងព្រះគោជាបងឲ្យជួយកិច្ចការដ៏ធ្ងន់នេះ ព្រះគោក៏ព្រមទទួល លុះដល់ពេលណាត់គ្នាថានឹងភ្នាល់ ព្រះគោ-ព្រះកែវនិងនាងពៅ នាំគ្នាចេញពីស្រុកបច្ចន្តគ្រាម មកកាន់រាជធានីនៃព្រះវរបិតា-មាតា ។

កាលបើព្រះគោ-ព្រះកែវ មកដល់ហើយ ក៏ផ្ញើសារទៅថ្វាយស្ដេចក្រុងសៀមថា ឲ្យយាងមកភ្នាល់គ្នាតាមពេលកំណត់ ។ ស្ដេចក្រុងសៀមក៏លើកពលសេនា ហើយនឹងយកមាន់ព្រៃមួយមកផង ។

លុះមកដល់ហើយ គឺរៀបចំប្រជល់មាន់ ព្រះគោក៏ក្លែងខ្លួនធ្វើជាមាន់ ជល់តនឹងមាន់ស្តេចក្រុងសៀម ប៉ុន្តែមាន់ស្តេចសៀមត្រូវបរាជ័យ ។

-លើកទី២ ប្រជល់ដំរី ដំរីព្រះគោមានជ័យជម្នះទៀត ។

-លើកទី៣ ប្រជល់គោ ស្តេចសៀមឈឺចិត្តណាស់កេឧបាយកលធ្វើជាគោយន្ត ដើម្បីប្រជល់នឹងព្រះគោដែលមានឫទ្ធិអំណាច ឲ្យវាបាក់បបខូចខ្ទាចវិនាសហិនហោច ដើម្បីនឹងបាយកមាស-ពេជ-ត្បូង-គម្រោពីក្នុងពោះព្រះគោ ជញ្ជូនយកទៅស្រុកសៀមអស់រលីង ។

រឿងដែលនាំមកដោយសង្ខេបនេះ សឲ្យឃើញថានៅស្រុកខ្មែរយើងមានពូជគោពូកែស័ក្តិសិទ្ធិណាស់ដែរ ។

## “រឿងព្រេងអំពីសត្វគោ - មាន់ - អណ្តើក - ពស់ និង សត្វរាជសីហ[១]”

មានសេចក្តីដំណាលថា មានមេក្អែកសមួយកាច់សំបុកពងនៅលើដើមគោងកាងក្បែរមាត់សមុទ្រ ពេលមួយមានខ្យល់ព្យុះបក់បោកយ៉ាងខ្លាំង ធ្លាក់សំបុកក្អែកនិងពង ៥ ទៅក្នុងទឹក អណ្តែតទៅទើរនៅនឹងកោះមួយ កោះនោះមានតានិងយាយពីរនាក់ប្តីប្រពន្ធគ្មានកូន ក៏រើសយកពងទាំង ៥នោះទៅក្រងទុក លុះដល់កំណត់ថ្ងៃខែពងទាំង ៥ ក៏ញាស់

១- រឿងក្អែកពង ៥ នេះខ្ញុំបាទបានពីលោកភិក្ខុ ហុន-ទឹម វត្តវិហារបទមាស លោកនិយាយប្រាប់សព្វគ្រប់ ។

ចេញមកជាសត្វទីទៃពីគ្នា ពងទី ១ ញាស់ចេញមកជាសត្វ " មាន់ " ពងទី ២ ញាស់ជាពស់ ពងទី ៣ ញាស់ជាអណ្តើក ពងទី ៤ ញាស់ជាសត្វគោ ពងទី ៥ ញាស់ជាសត្វសិង្ហ ។

សត្វទាំង ៥ នៅជាមួយនឹងយាយ-តា រៀងរហូតដល់មានវ័យធំរៀងៗខ្លួន បានសាកសួររកម្តាយឪពុករៀងខ្លួន តានិងយាយក៏បានប្រាប់តាមដំណើររឿងហេតុគ្រប់ ។ សត្វទាំង ៥ បានស្តាប់តា-យាយដោយសព្វគ្រប់ទៅ ក៏មានសេចក្តីអៀនខ្មាស់នឹងជាតិកំណើតរបស់ខ្លួន ក៏លាតា-យាយស្វែងរៀនវិជ្ជាចំណេះ លុះត្រាតែបានសម្រេចដូចបំណងហើយលះបង់ភេទរបស់ខ្លួន ចេញស្វែងទៅបួសរៀងៗខ្លួន ។

សត្វមាន់បានត្រាស់ជាព្រះពុទ្ធ មាននាមថា " ព្រះ កកុសសន្ធោ " ។ សត្វពស់បានត្រាស់ជាព្រះពុទ្ធមាននាមថា " ព្រះ កោនាគមនោ " ។ សត្វអណ្តើកបានត្រាស់ជាព្រះពុទ្ធមាននាមថា " ព្រះ កស្សបោ " ។ សត្វគោបានត្រាស់ជាព្រះពុទ្ធ មាននាមថា " ព្រះ គោតមោ " ។ សត្វសិង្ហៈបានត្រាស់ជាព្រះពុទ្ធមាននាមថា " ព្រះ សិ អារ្យមេត្រី " ។ ដោយយកនាមកំណើតដំបូងដែលខ្លួនកើតនៅជាមួយនឹងតា-យាយរៀងៗខ្លួនមកដាក់ថា " ព្រះពុទ្ធនាមមាន់-គោ ។ល។ ហើយនិងចាំបណ្តាំយាយតា មុននឹងសត្វទាំងនោះលាចេញទៅថា " ចូរចៅទាំងអស់កុំភ្លេចកំណើតខ្លួនឡើយ "

ព្រោះហេតុនោះហើយបានជាព្រះពុទ្ធទាំង ៤ ព្រះអង្គនេះឧប្បត្តិឡើងក្នុងលោក ត្រូវយកនាមសត្វកំណើតមកដាក់និងពាក្យបូសត្វទាំងនោះនៅពីក្រោមបល្ល័ង្កផង ។

## អំពីសត្វដែលមានប្រយោជន៍ដល់ផ្ទះសម្បែង

ដូចជាសត្វសេក-សារិកាកែវ... កាលណាម្ចាស់បង្ហាត់ឲ្យចេះនិយាយស្ដី-ឲ្យស្គាល់មនុស្សនៅក្នុងផ្ទះ និងមនុស្សនៅក្រៅផ្ទះ ពេលណាម្ចាស់មិននៅ មានមនុស្សចំឡែកចូល-សារិកាកែវនិងសេកទាំងនោះវាស្រែកឡូឡាហៅម្ចាស់ក្នុងនាទីជាសត្វការពារផ្ទះ ។

អំពីសត្វឆ្កែនិងស្វា : សត្វទាំងពីរនេះ ជាសត្វការពារផ្ទះដែរ បើយប់ឬថ្ងៃ មានមនុស្សចំឡែកចូល ឆ្កែនេះវាព្រូសឡូឡា ម្ចាស់ក៏ភ្ញាក់ដឹងខ្លួនដោយសារនេះវា ។ ជួនកាល គេបង្ហាត់ពូជឆ្កែមាឌធំ-ពូជកាច-ម្ចាស់ក៏បានបង្ហាត់ឲ្យចេះសព្វគ្រប់ទាំងទៀត ។ ពេលណាមានមនុស្សចំឡែកចូល-ឆ្កែទាំងនោះវាខាំតែម្ដង សមនឹងពាក្យស្លោកថា " ឆ្កែជាឲ្យបាយតែ ដេកនៅដណ្ដាំងខ្ទមធន "  ។

ជឿងសត្វចាំផ្ទះ មានទំនាមជឿងព្រេងមួយសម្ដែងថា មានជីតាម្នាក់ចិញ្ចឹមស្វាមួយឲ្យនៅចាំផ្ទះ ពេលមួយនាងកណ្ដៀតក្អមទៅដងទឹកនៅឯអណ្ដូង ហើយផ្ដេកកូនខ្ចីឲ្យនៅក្នុងអង្រឹង ទុកស្វាឲ្យនៅចាំផ្ទះ ។

ខណៈនោះមានពស់សាហាវមួយលូនចូលមក បម្រុងនឹងខាំកូនខ្ចី នៅក្នុងអង្រឹង ស្កាក៏ខាំពស់កៃវី ទាល់តែពស់ងាប់ស្អុកនៅទីនោះទៅ ស្កាដឹងថាពស់ងាប់ហើយ ក៏រត់ទៅប្រាប់ម្ចាស់ឯអណ្តូងទឹក ដោយមានឈាមពស់ប្រឡាក់ជាប់មាត់ផង-ម្ចាស់ កាលបើឃើញសត្វស្ការត់ទៅដល់ (មិនបានទពិចារណា) នឹកស្មានថា ស្កាខាំកូនរបស់ខ្លួន ក៏ចាប់ជើងស្កាបោកនិងដើមឈើស្លាប់ក្នុងខណៈនោះទៅ នាងពីតាកណ្តៀតក្អមមកដល់ផ្ទះឃើញពស់ងាប់នៅក្បែរអង្រឹងកូន ក៏នឹកតូចចិត្តស្តាយក្រោយថា "អញសម្លាប់ស្កាខុសហើយ" ។ រឿងពស់និងស្កា មានជាប់ពៀរនឹងគ្នារហូតមកដល់សព្វថ្ងៃនេះ កាលបើស្កាឃើញពស់វាដេញខាំពស់ទាល់តែងាប់ពុំខានឡើយ ។

<u>សត្វដែលយកមកធ្វើជាពិធី និង មង្គលផ្សេង ៗ</u> : សត្វដែលយកមកធ្វើពិធីផ្សេង ៗ ដូចជាគោ-ឆ្មា ត្រី-មាន់-តីង្គក់-លក្ខុំប្រឡង់ដែលមានកូនរស់នៅខាងក្នុង ។ល។ ក្នុងទីនេះមិនបានយកឆ្មា-ត្រីសមកនិយាយទេ លើកយកតែសត្វតីង្គក់-មាន់ លក្ខស្រម៉មកនិយាយដូចតទៅ :

១- សត្វគោគេ យកមកធ្វើជាពិធីផ្សងមើលផលដំណាំ មើលទឹកក្នុងមួយឆ្នាំ ៗ ថាមានតិចឬច្រើន ៗ ដោយគេរៀបចំ តុ ស្លា-ស្រូវ-ពោត សណ្តែក ។ល។ ហើយគេលែងគោឲ្យស៊ីវត្ថុទាំងនោះបើគោស៊ីវត្ថុ

---

រឿងពស់ និង ស្កា ពិតស្រង់ពីសៀវភៅគតិលោក ។

ទំនាយថា ក្នុងឆ្នាំនោះមានភ្លៀងឬរាំង សំបូណ៌ផលស្រូវ ឬខ្សត់ ។ល។

២- សត្វមាន់និងគីង្គក់ គេយកមកធ្វើជាមង្គលមួយហៅថា "ស្រោចខ្ទរ" កាលបើកូនខ្ចីមានជម្ងឺដំកាត់ផ្សេង ៗ ដូចជាគ្រុនរងា-កម-រមាស់ កុតកញ្ជ្រិល ។ល។ គ្រូតម្រូវត្រូវគ្រង់ស្រោចខ្ទរ យាយតា-ម៉ែ-ឪ ក៏រៀបចំធ្វើកខ្ទរជាពីរថ្នាក់ លើ ក្រោមទិញដាំដើមចេកមហាត្រកាលមួយដើម មេមាន់ខ្មៅ ១, គីង្គក់ ១, សំពត់សារឆ្វេង-ស្តាំ ក្រាស់-កញ្ចក់ ប្រេង ម្សៅ ទឹកអប់ ឆត្រ ១ បាយសម្ល បង្អែម (ឆ្វេង-ស្តាំ) ស្លាធម គ្រប់ជើងសរសរពេទ និងស្លាធមនៅលើថាស បានបាយ-សម្លបួន ។ កុជ ទៀន-ធូប-រៀបគ្រៀបត្រានៅមុខកខ្ទរ ។

ដោយមានតា-យាយជាញាតិមិត្រ ធ្លាប់ធ្វើពិធីនេះ ចាប់កុជធូបទៀន អង្ករមួយក្តាប់ ចាប់សំបូងសង្រ្រួងថា "នុះនុ! តេជៈ ថ្ងៃនេះជាថ្ងៃមានឫក្សពេលល្អ សូមអញ្ជើញអស់លោកព្រះខ្ទរ មកទទួលសេពសោយនូវក្រយាបូជា មានសំពត់សារសាវស្បៃ ប្រេង ម្សៅ ក្រាស់ កញ្ចក់ បង្អែមចំអាប រៀបភ្ញុ ថាស ឆ្វេង-ស្តាំ សព្វគ្រប់តាមចំណាំប្រពៃណីពីបុរាណ កាលបើបានសេពសោយរួចហើយ សូមឲ្យដកពិសពែងស្នែងកម្ម ចេញពីអង្គឲ្យជាសះស្បើយស្លើយឆ្ងាយខ្លួនប្រាណ និងឲ្យកូនចាបនេះស្រេកទឹកស្រេកចំណី ចាប់តាំងពីពេលនេះតទៅ ហក៏ ១-២-៣-៤-៥-៦ ៧ ៨ ទៅ (បាចអង្ករមួយចឹប) ជាបីដង ឲ្យទៅជាប់នឹងមេមាន់

ខ្មៅទីងគីង្គក់នេះចុះ ។

រួចហើយក៏ចាប់បាយ-សម្ល ខ្វះ ។ ដាក់ទៅក្នុងកន្ទោង ១ ប្រេងមេ្យ ទឹកអប់ ចាក់បន្តិច ។ យកទៅលាបលទ ដើមចេក គីង្គក់ មាន់ និង ក្បូនចាបឈើផងដែរ ហើយឧបកិច្ចបញ្ចុះអង្គរម្តងទៀតថា សូមឲ្យ ជម្ងឺក្បូនចាបនេះទៅជាប់នឹងមាន់ គីង្គក់ ដើមចេក ឯណោះចុះ ១-២-៣ ៤-៥-៦-៧ ចេ ទៅ (៣ ដង)

បន្ទាប់មកយាយ-តា ចាប់វេញអំបោះវែ្សជា៣ធ្នុង គឺមានពណ៌ស-ក្រហម និងខ្មៅ ដោយមានចងលុយសេន លុយក្បាល ខ្សែបៀ ស្រកាពង្រូល ក្រចកខ្លា ក្រចកខ្លែងស្រាក់ ចំរុះគ្នា រួចយកមកចងក ក្បូនចាបឈើនោះ ដើម្បីការពារកុំឲ្យទារកភ័យភ្ញាក់យំឡូឡា ក្នុងពេលយប់ ការពារស្គន្ធ-ប៉ា បន្ទាច ។ល។

ពិធីស្រោចខ្វះនេះមានកំណត់ ៣ ថ្ងៃ ក្នុងមួយថ្ងៃស្រោចបីដង គឺព្រឹក ថ្ងៃត្រង់ ល្ងាច ។ បញ្ចុះគ្រាប់សអង្ករត្រូវធ្វើរៀងរាល់ពេលដែល យកទារកទៅស្រោចទឹកនៅឯកន្ទ្វ ។ (ឯរៀបរណ្ដាប់រណ្ដាកស្ដុការ ផ្សេង ៗ ដូចថ្ងៃដំបូងគ្មានទេ) មានតែស្រោចទឹកនិងបញ្ចុះអង្ករប៉ុណ្ណោះ ចំពោះពេលជាបន្ទាប់បន្ទមក ។

---

រឿងពិធីស្រោចខ្វះនេះ ខ្ញុំបាទបានដឹងពីលោកយាយ " សាង " អាយុ ៧៧ ឆ្នាំ ដែលត្រូវជា ម្ដាយបង្កើតរបស់ខ្ញុំបាទ

៣ - ល័ក្តស្រម៉ ជុំក្រឡង់ : គេយកមកធ្វើជាមង្គលមួយក្នុងពេលឡើងផ្ទះថ្មី ដោយអ្នកមុខអ្នកការចាស់ទុំយកល័ក្តស្រម៉នេះទៅបញ្ចុះក្នុងរន្ធសសរគ្រង់ល្អងចន្ទព្រោះគេយល់ថា ល័ក្តជុំក្រឡង់ជានិមិត្តរូបនៃគូស្រករថ្មីឲ្យចេះស្រឡាញ់គ្នា រួបរួមគ្នាមិនឈ្លោះទាស់ទែងគ្នា ដូចជាល័ក្តជុំក្រឡង់នឹងឲ្យស្រីមេផ្ទះ ចេះរក្សាគំនិតមារយាទឲ្យគង់វង្សដូចល័ក្តជុំក្រឡង់នោះទើបក៏គេយកល័ក្តមកធ្វើជាមង្គលមួយហៅថាជុំពិលា ជាវិធានស្នាអាចារ្យធ្វើធ្មេញកូនប្រុស - ស្រី រួចយកល័ក្តមកលាបជើងធ្មេញ ដើម្បីឲ្យធ្មេញជាប់យូរ អ្នកក្មេងលេងក្នុងបុកល័ក្តទាក់មេព្រៃក្នុងពេលធ្វើធ្មេញលាបធ្មេញនោះដែរ ។

អំពីសត្វនិងអាទិទេព : មានសត្វខ្លះគេគោរពបូជាដូចជាអាទិទេពដែរ " គឺសត្វដំរី " ។ សត្វដំរីនេះមានរឿងនិទានដូចតទៅ ៖

ព្រះសិទ្ធិសួស្តីនិងប្រសិទ្ធិសោមជាបងប្អូនបង្កើត ត្រូវជាព្រះរាជបុត្រនៃព្រះឥស្សូរ ។

លុះព្រះសិទ្ធិសួស្តី មានវ័យធំឡើង ក៏ថ្វាយបង្គំលាព្រះបិតាទៅរៀនសិល្បវិជ្ជាការ នៅឯក្រុងរោម: ។ បណ្តាសិស្សដែលទៅនៅរៀន

---

រឿងល័ក្តប្រជុំក្រឡង់ បានដឹងពីលោកអាចារ្យតាម " ត្រកូល "
ជាអាចារ្យកាន់ពិលាការនៅភូមិត្រា

ទាំងប៉ុន្មាន មានតែព្រះសិទ្ធិសួស្តីមួយទេ ដែលល្បីឈ្មោះថា ជាអ្នកឈ្លាសវៃ ចេះដឹងជាងសិស្សទាំងពួង អាចារ្យទិសាបាមោក្ខព្រាហ្មណ៍ក៏មានសេចក្តីស្រឡាញ់រាប់អានព្រះសិទ្ធិសួស្តីខ្លាំងណាស់ ។ ដំណឹងនេះឮដល់ព្រះចៅក្រុងពេម ព្រះចៅក្រុងពេម មានព្រះរាជបុត្រីមួយព្រះអង្គ មានរូបឆោមលោមពណ៌ស្រស់បស់ ជាបុត្រីសំណប់ទោលរបស់ព្រះអង្គ។

ពេលខាងក្រោយមក ព្រះចៅសព្វព្រះទ័យ ចង់ផ្សំផ្គុំបុត្រីរបស់ព្រះអង្គជាមួយនឹងព្រះសិទ្ធិសួស្តីឲ្យជា គូ-ស្វាមីភរិយា ។

ថ្ងៃក្រោយមកព្រះចៅត្រាស់បញ្ជាហៅព្រះសិទ្ធិសួស្តី ឲ្យចូលគាល់ព្រះអង្គ ។ព្រះសិទ្ធិសួស្តីក៏ចូលទៅគាល់តាមព្រះរាជបញ្ជា ។ ព្រះចៅក៏មានព្រះបន្ទូលសំណេះសំណាលជាមួយនឹងព្រះសិទ្ធិសួស្តី ដោយសព្វគ្រប់ ហើយមានបន្ទូលទៀតថា ខ្ញុំចង់ឲ្យបុត្រីសំណប់ខ្ញុំ ទៅជាគូស្រករបស់អ្នក តើអ្នកថាដូចម្តេច ? លុះព្រះសិទ្ធិសួស្តី ឮព្រះចៅមានបន្ទូលដូច្នោះហើយ "ទទួលក៏មិនថា ទេក៏មិនថា" ធ្វើអាការៈហាក់ដូចជាភ្លឹក-ភ្លឹង ទ្រមឹងស្ងៀម ។

លុះដល់ពេលត្រឡប់ពីព្រះចៅមកវិញ បានចំនួន២-៣ថ្ងៃ ព្រះសិទ្ធិសួស្តីរំពឹងគិតក្នុងចិត្តថា បើអាត្មាអញត្រាំនៅទីនេះយូរទៅ មុខជាជាប់ដៃនឹងព្រះរាជបុត្រី ព្រះចៅអង្គនេះពុំខាន ដូច្នេះអាត្មាអញត្រូវ

លបតែពីនគរនេះ ឆ្ពោះទៅនគរកំណើតខ្លួនវិញ ។ គិតស្រេចហើយក៏រៀបចំប្រដាប់ប្រដា សម្លៀកបំពាក់ លបតែចេញទៅនៅពេលយ៉ាងស្ងាត់ ។ ដំណឹងនេះក៏ជ្រួតជ្រាបដល់ព្រះចៅក្រុងរោម ព្រះអង្គទ្រង់ព្រះពិរោធយ៉ាងខ្លាំង ហើយព្រះអង្គទ្រង់បញ្ជាគ្រឿងយន្ត (ម៉ាស៊ីនកាត់) តាមកាត់កព្រះសិទ្ធិសួស្តី ទាន់នៅឯកណ្តាលផ្លូវព្រៃ យន្តកាត់ក៏ក្បាលយកទៅឯក្រុងរោម ផងខ្លួននៅដេកស្តូកស្តឹងក្នុងដងផ្លូវព្រៃ ។

និយាយអំពីព្រះសិទ្ធិសោមជាប្អូន លុះបានដំណឹងថា ព្រះសិទ្ធិសួស្តីជាបងផ្តាំឲ្យមកចាំទទួល នៅនាពាក់កណ្តាលផ្លូវ រៀបដំណើរមកចាំ ទទួលតាមពាក្យបណ្តាំ ។

លុះនៅយូរ ៗ ទៅ បាត់មិនឃើញសោះ ក៏ដើររកមើល-ឆ្វេង-ស្តាំ ស្រាប់តែឃើញមនុស្សដួលដេកស្លាប់នៅក្បែរព្រៃ (ឃើញតែដងខ្លួនឥតក្បាល) ព្រះសិទ្ធិសោម ពិនិត្យទោចមើលចុះ ឡើង ឃើញសុទ្ធតែមន្ត-អាគម-អូមអាម មានមន្តប្រស់មនុស្សឲ្យរស់ជាដើម (សាក់នៅជាប់នឹងដងខ្លួន) ។

ព្រះសិទ្ធិសោមចាប់រៀនអាគមប្រស់មនុស្សរួចរាល់ លុះចេះសព្វគ្រប់ហើយ ក៏តាំងប្រសិទ្ធិប្រស់មនុស្សនោះឲ្យរស់ឡើងបាន តែមុននឹងប្រស់ដើររកក្បាលមនុស្សស្លាប់ពុំបាន ឃើញមានតែក្បាលដំរីមួយស្លាប់

ទៅទីនោះ ក៏កាត់ក្បាលដំរីមកតភ្ជាប់នឹងដងខ្លួន រួចសូត្រមន្តអាគមប្រស់ដងខ្លួនឡើងហើយ ក៏និយាយរឿងរ៉ាវ ដំណើរទំនងប្រាប់ប្អូនដោយសព្វគ្រប់ ។

ប្អូនក៏និយាយអង្វរករបង ឲ្យចូលទៅនៅស្រុកវិញ តែបងមិនព្រមទាល់តែសោះ ដោយមានសេចក្ដីអៀនខ្មាស់អ្នកស្រុក (ខ្លួនខុសគេ) (ក្បាលដំរី ខ្លួនជាមនុស្ស) ព្រះសិទ្ធិសួស្ដីសុខចិត្តភៀសខ្លួនទៅនៅក្នុងព្រៃ ។ ព្រះសិទ្ធិគោរមបានរៀនមន្តអាគម និងបម្រើព្រះសិទ្ធិ-សួស្ដីសព្វគ្រប់ រួចវិលត្រឡប់ចូលនគរវិញ ។

រីឯមន្តអាគម និងធ្វើរូបសួងព្រះសិទ្ធិសួស្ដីក៏ សឹងមានជាប់ជាតំណ-វង្សរហូតមកដល់សព្វថ្ងៃនេះ ។

ព្រោះហេតុនោះ ទើបគ្រូមន្តអាគមទាំងឡាយ មុននឹងសូត្រ-សែកស្ដោះ ផ្លុំមើលជម្ងឺទាំងពួង ត្រូវលើកគុណគ្រូជាដំបូងថា: ឩ:មៈ ព្រះសិទ្ធិសួស្ដីអញ្ជះហើយ ។ល។ ពាក្យថា ឩ:មៈ គឺរលឹកដល់គ្រូទាំងបី គឺព្រះព្រហ្ម ព្រះឥសូរ ព្រះនាកយណ៍ ។

ដំរីគេគោរពដូចជាអាទិទេព ដោយសារតែក្បាលដំរីទៅភ្ជាប់នឹងដងខ្លួនមនុស្ស ដែលមានមហិទ្ធិឫទ្ធិអស្ចារ្យប៉ុណ្ណោះទេ ។ ពាក្យថា ដំរីមួយបុះ "គឺដំរី៨" ។ លោកមួយខ្ទង់ "គឺលោក ៨ អង្គ" ។

ពាក្យខាងលើនេះ មានប្រើក្នុងសម័យបុរាណ ឧទាហរណ៍ : ព្រះករុណាទ្រង់បញ្ជាសេវកាមាត្យថា "ចូរអ្នកទៅនាំដំរី២ បុះឬ៣បុះ ដើម្បីប្រទក្សិណព្រះបរមរាជវាំង៣ជុំ" ។ "ឬក៏អ្នកឯងចូលទៅនិមន្តលោកមួយទទួងមកគាន់នៅក្នុងព្រះរាជដំណាក់ ។"

"រឿងព្រះសិទ្ធិសួស្តិ៍-ខ្ញុំបាទបានរៀនពីលោកអាចារ្យ ខោ គា អាយុ ៧ ឆ្នាំ

នៅភូមិអំពៅព្រៃ

ឯពាក្យថា "បុះ នឹង ទទួង" ខ្ញុំបាទបានឃើញក្នុងសាស្ត្របុរាណ ។

# រឿង

# គ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ

របស់លោក រ៉ាប៊ិន្ទ្រ ណាត តាហ្គ័រ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ៣៦

– មិនស្រួលខ្លួនឬការមាណា ? ( នាងសិលាជាសួរនាងនៅពេលដែលនាងដើរចូលមក )

– ខ្ញុំឥតមានឈឺអ្វីទេបង ! កាលណាទើបលោកមាត្រឡប់មកវិញបង ?

– មិនមុនមួយអាទិត្យទេ យ៉ាងឆាប់អូន មកញ៉ាំបាយឲ្យឆាប់ទៅ ទឹងអាលទៅគេងពីព្រលប់ អូនអស់កម្លាំងហើយ ធ្វើការតាល់ល្ងាចយ៉ាងនេះ ។

ពេលអាសន្នយ៉ាងនេះ ការសង្គ្រោះរបស់នាងមានតែប្រាប់រឿងអាថ៌កំបាំងរបស់នាងឲ្យនាងសិលាជាដឹងឲ្យអស់ថា រមេស្ហដែលអ្នកទាំងអស់គ្នាយល់ថាជាប្តីនាងនោះ គឺគ្មានត្រូវជាអ្វីនឹងនាងទាល់តែសោះ ប៉ុន្តែ នាងរកហាមាត់ប្រាប់គេមិនកើត ! នាងចូលទៅសម្ងំក្នុងបន្ទប់ដើម្បីនឹងអានសំបុត្រនោះឡើងវិញ ។

កូនសំបុត្រនោះ គ្មាននិយាយអ្វីអំពីនាងហាមណាលិនីបន្តិចសោះ កាមាលាគ្រាន់តែយល់ថា ស្រីនោះជាគូដណ្ដឹងរបស់កមេស្ហ ដែលត្រូវផាច់ទៅវិញដោយសារតែខ្លួននាង ។ នាងកាមាលាដឹងម្យ៉ាងទៀតថា កមេស្ហស្រឡាញ់នាងនោះណាស់ ប៉ុន្តែ ការដែលគេសុខចិត្តទទួលនាងនេះ គឺដោយសារតែគេខំទ្រាំទៅទេ ព្រោះថា ធ្វើម្ដេចបើកសនាបង់គេផ្ដាច់នឹងនាងនេះទៅហើយ គេស៊ូខាំមាត់ទ្រាំលែងទៅជួបស្រីដែលជាទីស្រឡាញ់ពិតប្រាកដរបស់គេ ។

លុះមើលសំបុត្រចប់ហើយ នាងកាមាលាទំនឹកអំពីឧប្បត្តិហេតុដែលចេះតែផុសឡើងជាបន្តបន្ទាប់គ្នា នៅពេលដែលនាងនៅជាមួយនឹងកមេស្ហតាំងពីបានជួបគ្នានៅលើធ្នេរខ្សាច់ រហូតដល់មកនៅគ្រាស៊ីបូរីនេះ ។

ឥឡូវនេះរឿងអ្វី ៗ តាំងប៉ុន្មាន ដែលបិតនៅក្នុងភាពងងឹត ក៏លេចច្បាស់ថែងឡើង ហាក់ដូចជានៅក្នុងរង្វង់ស្លៀព្រះទិនករ គឺថាតាំងពីយូរយារណាស់មកហើយ ដែលកមេស្ហគេដឹងច្បាស់ថាខ្លួននាងនេះមិនមែនជាប្រពន្ធគេទេ ប៉ុន្តែគេមិនដឹងជាធ្វើម្ដេចនឹងលោសនាងចោលបាន ម៉្លោះហើយ គេចេះតែបៀមទុកទៅ ឯចំណែកខ្លួននាងវិញ ក៏ចេះតែប្រុងប្រៀបខ្លួនទទួលគេជាប្ដីតាំងពីនឹកស្មានមិនដល់ គ្មានខ្មាសគ្មានអៀនអ្វីបន្តិចសោះ គិតឃើញដូចេះថែមតាំងរឿងអ្វីផ្សេង ៗ ជាមួយនឹងកមេស្ហទៀតក៏ចេះតែផុសបន្តបន្ទាប់គ្នា ធ្វើឲ្យនាងកាមាលាអៀនអន់ខ្មាសមិនចង់រស់នៅលើ

ផែនដីទៀតសោះ ។ ពុទ្ធោអើយ នាងត្រូវអាម៉ាស់មុខអស់មួយជីវិត ! តើនឹងបានអ្វីយកមកលាងឲ្យជ្រះនូវរឿងកខ្វក់ទាំងនេះបាន ? . . . ។

នាងបើកទ្វារបន្ទប់ដើរចេញទៅកន្លែងសួនច្បារ ពន្លឺនៃសិសិររដូវ មានចំហាយត្រជាក់ស្រេប នៅទាំងនាយបន្តិចទៀត ដើមស្វាយជំទង់ ៗ ធ្វើឲ្យមានភាពងងឹតដោយដុំៗក្នុងរឿងលំបាកវេទនារបស់នាង នាងប្រមើលមើលទៅគ្មានឃើញច្រកណា ដែលនាងអាចប្រៀតខ្លួនចេញរួចសោះ ។ ល្វើយទាំងកម្លាំងចិត្ត ល្វើយទាំងកម្លាំងកាយ ខង កាមាលាផ្តួលខ្លួនក្រាបទៅលើស្មៅ បីដូចជារូបបដិមាដែលគេប្រានរំលំ ទៅស្ទុកស្ទឹងហាក់ដូចជាគ្មានវិញ្ញាណ នាងយំក៏មិនចេញ ថ្ងូរក៏មិនឮ ពុទ្ធោអើយ ! មិនដឹងជានាឡិកាដើរហួសទៅប៉ុន្មានម៉ោងទេ ដែលនាងទៅស្ទុកស្ទឹងយ៉ាងនេះ ប៉ុន្តែ អាកាសត្រជាក់ជ្រាបរហូតដល់ឆ្អឹងខ្នងនាងរងា ភ្ញាក់ខ្លួនឡើង ពន្លឺព្រះច័ន្ទរះឡើងផាត់ភាពងងឹតស្ទើរតែរលីងផង នាងក្រោកឡើងដើរសន្សឹម ៗ ចូលទៅកាន់បន្ទប់វិញ ។

នៅពេលដែលនាងបើកភ្នែកស្អែកឡើង នាងឃើញនាងសិលាមកឈរនៅក្បែរខ្លួននាងស្រេចទៅហើយ នាងនឹកអៀននឹងគេងលក់ជ្រុលពេលថ្ងៃ ក៏ចំស្ទុះក្រោកម្តង ។

—កុំអាលក្រោកអី អូនគេងមិនទាន់ឆ្អែតទេ មើលភ្នែកអូននៅខ្មៅជាំនៅឡើយ អូនច្បាស់ជាមានការអផ្សុកចិត្តហើយ អូនប្រាប់បង

ផងមើល៍ ?

គ្រាន់តែឮពាក្យនាងសិលានិយាយដូច្នេះ ទឹកភ្នែកនាងកាមាលាហូរព្រោកមួយរំពេច នាងស្រវាឱបនាងសិលា ហើយយំខ្សុកខ្សួលយ៉ាងយូរ ៗ បន្តិចមក នាងដោះដៃចេញអំពីនាងសិលា ជូតទឹកភ្នែកហើយធ្វើជាសើចយ៉ាងខ្លាំង ប៉ុន្តែនាងសិលាយល់ដជ្រៅទុក្ខនាងកាមាលា បំភាន់នាងម្តេចបាន ៗ

— នែកាមាលា អូនមិនធ្លាប់ធ្វើបំភាន់បងទេ បងមិនដែលឃើញមនុស្សណាមានខន្តីដូចអូនសោះ ប៉ុន្តែអូនកុំស្មានថា បងមិនដឹងថា ព្រួយរឿងអ្វីនោះខុសទេ ៗ តាំងពីកមេស្វាចេញទៅ គេមិនដែលសរសេរសំបុត្រអ្វីមួយមកអូនសោះ ហេតុនេះហើយបានជាអូនព្រួយណាស់ ទោះជាអូននៅធ្វើបុកស្នាយ៉ាងណា ក៏បងយល់ដែរ ៗ អូនត្រូវដឹងថា គេរវល់ការច្រើនណាស់ បានជាគ្មានពេលសរសេរសំបុត្រមកអូនមិនបាន ម្យ៉ាងទៀត តែ ២ ថ្ងៃទៀត គេនឹងត្រឡប់មកវិញហើយ អូនព្រួយធ្វើអ្វី ? អើចុះក្មេងអីក៏ឆោតម៉្លេះ យំអស់ទឹកភ្នែកសន្ទឹកឥតប្រយោជន៍ ឈប់គិតរឿងផ្តេសផ្តាសនោះទៅ ញញឹមដាក់បងមួយឲ្យយ៉ាងស្រស់មកមើល៍ ម៉េចមិនភាន់ព្រមបាត់ខឹងនឹងកមេស្វាទេឬ ? . . . ៗ

នាព្រឹកនោះ នាងសិលាប្រញាប់សរសេរសំបុត្រមួយទៅឪពុក

នាងក្លាម ៖

លោកឪពុក នាងកាមាលាស្រឡូតស្រស់ខ្លាំងពេកណាស់ ដោយភមេស្ហមិនព្រមសរសេរសំបុត្រមួយទៅនាងសោះ យើងគួរគិតថា បើប្រសិនជារូបយើងវិញតើយ៉ាងណា បើយកគ្នាទៅចោលក្នុងចំណោមមនុស្សដែលជាអ្នកដទៃទាំងអស់ ហើយទៅបាត់គ្មានឲ្យដំណឹងបន្តិចសោះយ៉ាងនេះ សុំពុកប្រាប់ភមេស្ហថាបើគិតការអ្វី គិតឲ្យឆាប់ៗ ទៅទីងគាលត្រឡប់ទៅផ្ទះ កុំឲ្យនាងទន្ទឹងខ្លាំងពេក ម្យ៉ាងទៀតពុកជួយគិតមើលមើល៍ មានអ្នកខ្លះគេរវល់ជាងភមេស្ហនេះទៅទៀត ក៏គេឆ្លៀតសរសេរសំបុត្រទៅប្រពន្ធគេកើត ចុះរវល់យើងនេះអីក៏ជាងគេម្ល៉េះ ?

លុះឪពុកនាងសិលាទទួលបានសំបុត្រ គាត់ទៅជួបភមេស្ហ ហើយក៏បាននិយាយបន្ទោសអ្នកជាច្រើន អំពីរឿងដើរចោលប្រពន្ធមិនឲ្យដំណឹង ៗ

ប៉ុន្តែបើនិយាយឲ្យសុចរិតទៅវិញនោះ គឺថាភមេស្ហគ្មានភ្លេចនាងកាមាលាមួយនាទីណាសោះទេ ប៉ុន្តែ បញ្ហានាងកាមាលានឹងអ្នក ភស្មុគ្រស្មាញពេក ភយមិនបែកសោះ បានជាគ្នាលេចទុកទៅ ៗ

ការដែលនាងសិលានិយាយថា នាងកាមាលាពិបាកចិត្តខ្លាំងណាស់ ព្រោះបាត់ភមេស្ហសូន្យ គឺជាការពិតណាស់ ប៉ុន្តែភមេស្ហនៅតែកករែក ហាក់ដូចជាមនុស្សម្នាក់ដើរមកដល់ផ្លូវបំបែក ហើយមិនដឹងជាណានៈទៅ

ផ្លូវណា ឲ្យបានជួបនឹងសេចក្ដីសុខ ៗ តែម្ដងនេះ គេលែងកកែចិត្តទៀតហើយ គេប្ដេជ្ញាក្នុងចិត្តគេថា ត្រូវតែធ្វើដូចម្ដេចឲ្យនាងកាមាលាបានទទួលសុភមង្គល ៗ ជាព្រហ្មលិខិតមិនគ្រាន់តែបានបងជីវិតនាងនិងជីវិតអ្នកភ្ជាប់គ្នាទៅហើយទេ ថែមទាំងបងបេះដូងអ្នកភ្ជាប់នឹងបេះដូងនាងកាមាលាផង ៗ កាមេស្ហសម្រេចចិត្តដូច្នេះហើយ ក៏ទាញដងប៉ាក-កាយកសរសេរសំបុត្រមួយដោយផ្ចិតផ្ចង់ទៅនាងកាមាលា :

“កាមាលាជាទីស្រឡាញ់ !

សូមប្អូន កុំទុកពាក្យខាងលើនេះ ជាវចនាបទ សម្រាប់ប្រារព្ធប្រើក្នុងសំបុត្រធម្មតាឲ្យសោះ ព្រោះថា បើអូនមិនមែនជាថ្លើមប្រមាត់របស់បងទេ បងក៏មិនយកពាក្យនេះមកប្រើចំពោះអូនដែរ ៗ បើប្រសិនជាអូនពុំជឿ ឬពាក្យដែលបងសរសេរនេះមានពាក្យណាត្គាំត្គង ធ្វើឲ្យអូនអាក់ចិត្តដោយបងគ្មានចេតនា សុំឲ្យពាក្យដែលបងសរសេរចេញពីដួងចិត្តដ៏ស្មោះរបស់បងនេះ ក៏ចាត់ទុកក្ដីសង្ស័យនឹងហើយក្លាយទៅជាសំពត់រុំស្រោចមុខរបួសដែលបងបានធ្វើឲ្យអូនឈឺចាប់ទៅវិញ ដូចសេចក្ដីបងប្រាថ្នា ៗ

“ឡូវនេះ តើយើងនៅចំលាក់លៀមដល់ណាទៀត ?

អាកប្បកិរិយាបងចំពោះអូនតាំងពីមុនមក បានធ្វើឲ្យអូនពិបាកចិត្តជាច្រើន បងក៏ដឹងដែរ តែបើអូននៅតែប្រកាន់ខឹងនឹងបងតទៅទៀត បងនឹង

អានបានវែកញែក ឲ្យឃើញ នូវចិត្តដ៏បរិសុទ្ធរបស់បងចំពោះអូនហើយ ។ ក្នុងខណៈនេះ បងគ្មានពាក្យអ្វីជម្រាបអូន ក្រៅអំពីនិយាយដដែលថា: អូនជាទីស្នេហាបំផុតរបស់បងប៉ុណ្ណោះទេ ហើយនឹងថា បងគ្មានស្រឡាញ់ស្រីឯណាក្រៅឲ្យស្មើនឹងរូបអូនឡើយ ពិតមែនហើយតែការដែលបងនិយាយតាំងប៉ុន្មានឆ្នាំនេះ មិនអាចជាការដោះសាខ្លួនលម្អនឹងអំពើឆ្គាំឆ្គងយ៉ាងច្រើន ដែលបងបានធ្វើចំពោះអូនតាំង ពីនោះមកទេ ប៉ុន្តែបងចាន់តែពាក្យប៉ុណ្ណោះ ដើម្បីនឹងបញ្ចេញជាដំបូងជូនអូន ។ ដូច្នេះកាមាណាអូន កាលដែលបងហ៊ានបញ្ចេញពាក្យហៅអូនថា "អូនជាទីស្រឡាញ់"នេះ គឺបងមានបំណងនឹងដាក់ក្រុងាស់ដក់ទឹក ឲ្យស្រូបយកអតីតកាលដ៏ល្អក់ឲ្យអស់ចេញ ហើយដាក់ថ្នាំគ្រឿងស្អិតឲ្យមាំសម្រាប់ស្នេហារវាងយើងទាំងពីរនាអនាគតដ៏វែង ។

សូមអូនជឿជាក់ថា បងនឹកតែរូបអូនមួយជានិច្ច គ្មានភ្លេចមួយវេលាណាទេ គឺរូបអូននេះហើយ ដែលជាស្នេហាចំណូលចិត្តនៃបង បើអូនសុខចិត្តឲ្យបងបង្ហាញក៏ស្កាត់ឲ្យជាក់ច្បាស់ អនាគតយើងនឹងបានភ្លឺស្វាង ហើយប្រកបដោយសុភមង្គលផង តែបងចង់ដឹងតទៅទៀតថា តើអូនមានចិត្តស្រឡាញ់ បងដែរឬទេ ? បញ្ហាស្នេហាចោទហើយ បងមានសង្ឃឹមថា ថ្ងៃណាមួយបងនឹងបានទទួលចម្លើយស្របតាមបំណងរបស់បងមិនខានឡើយ ។ យើងមិនបានបំពានគ្នាដោយពាក្យសំដីមែន

តែយើងបានទុកជូនវិញ្ញាណយើង ឲ្យប្រាស្រ័យទាក់ទងគ្នាជាយូរមក ហើយ ការដែលធ្វើឲ្យបងហ៊ានពោលច្បាស់យ៉ាងនេះ គឺមកពីបងស្រឡាញ់អូនពិត្រ ។

បងមិនហ៊ានលើកខ្លួនបងថា ជាបុរសមួយរូបគួរជាទីស្នេហារបស់អូនទេ តែបងនឹកថា ការដែលបងស្រឡាញ់អូនដល់កម្រិតនេះ មិនសមបើនឹងឥតអំពើសោះ ។

សំបុត្រដែលបងសរសេរនេះ មើលឲ្យសព្វៗទៅហាក់ដូចជាគេសរសេរសៀវភៅរឿងយ៉ាងផ្តួតផ្តង់ ហេតុនេះហើយបានជាបងនឹកអៀនបង់តែហែកចោល ប៉ុន្តែបើមិនសរសេរដូច្នេះទេ តើសរសេរអ្វីទៅវិញ ដើម្បីនឹងបញ្ចេញមនោសញ្ចេតនារបស់បងកើត កំប៉ុន្តែទោះជាយ៉ាងណាក៏ដោយសំបុត្រទី ១ ដូច្នេះមិនអាចនឹងថ្លែងឲ្យអស់ការរបស់អ្នកសរសេរបានទេ ។ កាលណាចិត្តអូនទទួលមូលនឹងបងហើយនោះ ទើបបងអាចសរសេរការសំខាន់ៗទៀតបាន គឺថាទាល់តែទ្វារបន្ទប់ទាំងឡាយបើកចំហរអស់ហើយ ទើបខ្យល់អាកាសបក់ចេញចូលបានដោយសេរី កាមា-លាអូន រូបបងក៏ប្រៀបបាននឹងខ្យល់នោះដែរ តើកាលណាទៅអូន ! បងនឹងបានយល់នៃទ្វារបេះដូងអូនបើកចំហរចាំរូបបង ? . . . ។ យូរពេលបន្តិចទៅទៀតហើយមើលទៅ . . . ។

បន្ទំពេកក៏នាំឲ្យខូចការដែរ ស្អែកនេះបងនឹងត្រឡប់ទៅភ្នាស៊ី

បូរីញ ហើយបងសុំឲ្យអូននៅរង់ចាំបងនៅឯផ្ទះយើងកុំខាន ៗ តាំងពីយូរណាស់មកហើយដែលយើងទាំង ២ រូបគ្មានផ្ទះសម្បែងនឹងគេ បងនឹងទ្រាំនៅជួលផ្ទះគេទៅទៀតមិនបានឡើយ ឥឡូវនេះបងសង្ឃឹមថាទោះជាយ៉ាងណាក៏បងមានផ្ទះមួយនៅនឹងគេដែរ ហើយមានរូបអូនជាទីស្នេហានៅគ្រប់គ្រងផ្ទះនោះផង ៗ នៅពេលដែលបងទៅដល់ផ្ទះ បងរីករាយណាស់នឹងបានទទួលកែវភ្នែកអូនទាំងគូរ ប្រកបដោយសេចក្ដីសុខក្សេមក្សាន្ត ៗ

អូននឹកឃើញទេ នៅពេលមួយដែលយើងទាំង ២ នាក់ គេងជិតគ្នានៅលើផ្ទុកខ្សាច់នាឆ្នេរទន្លេគង្គា ដែលមានតែផ្ទៃមេឃជាដំបូល សូម្បីតែស្រមោលដំបូលផ្ទះមួយក៏គ្មាន មនុស្សម្នាក់ក៏គ្មាននៅក្បែរយើង .. តែបងនឹកដល់រឿងនេះកាលណាឡើង ហាក់ដូចជាបងបានយល់សប្ដិតែម្ដងនេះ បងនឹងទទួលកែវភ្នែកអូន នៅពេលពេញស្មានៃទិវានៅក្នុងរដូវផ្ញាំងបួន ដែលបងអាចចាប់កាន់នូវវត្ថុធាតុបានដោយផ្ទាល់ដៃស្រស់ៗ បងនឹងយល់ក៏ក្រដឹប្រិមប្រិយរបស់អូននៅរង់ចាំបងនៅមាត់ទ្វារ ៗ អូនកាមាលា បងជាស្វាមីយាយចកមួយរូប ដែលចូលទៅសុំទានស្នេហានៅមាត់ទ្វារនៃបេះដូងរបស់អូន សុំអូនកុំបណ្ដេញបងឲ្យថយចេញទៅទាំងដៃទទេ ព្រលឹងបង ?

កាមស្ហដែលស្មោះចំពោះអូន ៗ

# វគ្គទី ៣៧

ស្អែកឡើង ដោយឃើញមុខនាងកាមាលាបេះតែស្រងូតស្រងាត់ នាងសិលាក៏សួរ :

– មិនទៅផ្ទះឯបឹងកាឡូទេឬ ? ហើយបើបងឲ្យរបស់អូនឯងមួយ អូនឯងឲ្យអីបងវិញ ?

– ខ្ញុំឥតទៅទេ ព្រោះឥតមានការអ្វីធ្វើ ហើយម្យ៉ាងទៀតខ្ញុំគ្មានរបស់អ្វីជូនបងវិញទេ ។

– ឥតមានឥវ៉ែនឬ ?

– ព្រោះអូនបានឲ្យអ្វីៗទៅគេដទៃអស់ហើយ ។

– ចុះម៉េចអ៊ីចឹង ?

នាងសិលានិយាយបណ្ដើរ ទាញសំបុត្រមួយចេញពីក្នុងអាវមកបណ្ដើរ នាងកាមាលាក្រឡេកឃើញសំបុត្រឡើងទឹកមុខសស្លាំង រួចងាកមុខចេញផាំង នាងសិលាតាប់ផាប់ ។

– នែកុំក្រអឺតដល់ណាទៀត ធ្វើឫកអ្វីក៏ធ្វើម្ល៉េះ ? បើថាចង់កន្ទ្រាក់សំបុត្រពីដៃបងក៏កន្ទ្រាក់ទៅ ប៉ុន្តែនិយាយសុំបងឲ្យស្រួលមក បានបងឲ្យបងចង់ដឹងថាគេបុកខែងរបស់ ទៅបានយូរប៉ុន្មានពេលទៅទៀត ?

នៅពេលនោះ នាងអ៊ូមីដើរចូលមកក្នុងបន្ទប់ កាន់ខ្សែអ្លួសប្រអប់សាប៊ូមួយចូលមកផង ហើយស្រែកហៅនាងកាមាលាថា : មីង ! មីង !

នាងស្ទុះទៅលើកកុមារីបីឡើង ហើយថើបញីញក់ នាងអ៊ូមីរបូតខ្សែចង ប្រអប់សាប៊ូពីដៃ ១ ធាក់ដៃ ១ ធាក់ជើងដើម្បីឲ្យរួចអំពីដៃនាងកាមាលា តែនាងកាមាលាមិនលែងសោះ នាងឱបកុមារីដើរចូលរហូតទៅបន្ទប់មួយទៀតរួចទើបលួងលោមរកុំឲ្យយំ ។

នាងសិលាដើរចូលទៅតាមបន្ទាន់ៗគ្នា :

— ណ្ហើយ! កាមាលា បងសុំតាញអ្នកឯងហើយកុំបាច់ធ្វើថែមឥ តែ! យកសំបុត្រអ្នកឯងទៅ បងឈប់និយាយលេងទៀតហើយ ថាហើយនាងបោះសំបុត្រទៅលើគ្រែ ហើយក៏លើកកូនពរចេញទៅ ។

នាងកាមាលាចាប់សំបុត្រនោះមក មើលចុះមើលឡើងមួយសន្ទុះ ទើបដាច់ចិត្តហែក ។ នាងទើបនឹងមើលបាន ៣-៤ បន្ទាត់ក៏ស្រាប់តែខឹងឡើងមុខក្រហម ហើយក្រវាត់សំបុត្រចោល តែមិនយូរប៉ុន្មានទេនាងទៅរើសសំបុត្រនោះមកវិញ ហើយមើលតាលតែចប់សេចក្តី ។

យើងពិបាកនឹងយល់ណាស់ថា តើនាងកាមាលាយល់ចិត្តរបស់ក-មេស្ហុមិនយល់ ប៉ុន្តែនាងហាក់ដូចជាខ្ពើមសំបុត្រ ដែលនាងកាន់នៅដៃ ការដែលកមេស្ហសរសេរមកសុំនាង ធ្វើជាមេផ្ទះនៅពេលនេះ ហាក់ដូចជាសរសេរមកជេរប្រមាថនាង ព្រោះខ្លួនដឹងប្រាកដ ហើយថានាងជាប្រពន្ធបុរសម្នាក់ដទៃទៀតទេ ឯចំណែកនាងវិញកាលដែលនាងមានចិត្តត្រេកអរនឹងបានដំបូលមួយ ជ្រកតែ ២ នាក់នឹងកមេស្ហ នៅគ្រាសុំបីនេះ

កំនាងមិនបានដឹងថា កមេស្ហនេះមិនមែនជាប្ដីនាងដែរ នាងស្មានតែគេនេះហើយដែលជាប្ដី ដែលម្ដាយមីងបានរៀបការឲ្យនាង ។

នាងនឹកថា កមេស្ហដែលសរសេរមកសុំនាងធ្វើជាប្រពន្ធនេះ មិនគឺអ្វីក្រៅអំពីការគាណិតគាសួរ នាងដែលជាស្រីកំព្រាប៉ុណ្ណោះ ។ នាងនឹកស្ដាយនឹងអំពើ ដែលនាងបានធ្វើចំពោះកមេស្ហ ដោយការភ័ន្តច្រឡំ នាងនឹកខ្មាសគៀនមួយជីវិត ទោះជាតាំងពីតូចមកនាងមិនដែលបានធ្វើអ្វីខុសក៏ដោយ ។

ម៉្យាងទៀតផ្ទះដែលនាងច៉ង់ប្រាថ្នាមកយូរហើយនោះ ឥឡូវនេះទៅជារូបចម្លែកមួយ គួរឲ្យខ្លាចប៉ុន្តែនាងមិនដឹងជាគេចទៅទីណា ឲ្យផុតអំពីកណ្ដាប់ដៃវាសោះ . . .

សម្លេងអ៊ុយមេស្ហក្អកខេះៗ ទាញអារម្មណ៍នាងកាមាលា ដែលកំពុងតែអណ្ដែតតាំងខ្លោចផ្សារ តែនាងមិនងាកមុខមកសោះ អ៊ុយមេស្ហចាំយូរពេក ក៏ប្រថុយហៅនាង នាងដើរមក អ៊ុយមេស្ហនិយាយ:

– ម៉ែ ស៊ីខូប៉ាប៊ីបានទៅជួលពួកល្ខោនមកលេងកំដរការកូនស្រីគាត់ ។

– ហ្នឹងហើយអ៊ុយមេស្ហ ឯងទៅមើលល្ខោននឹងគេចុះណ៎ា ។

សប្បាយចិត្តណាស់ អ៊ុយមេស្ហត្រឡប់ ក្រោយកីនមួយរំពេច តែនាងកាមាលាហៅមកវិញ :

— នែ ! ទៅមើលល្ខោន យកលុយទៅផងទៅ ឃើញនាងកាមាលាឲ្យលុយវ៉ា ក្មេងនោះទឹកឆ្ងល់ ព្រោះល្ខោនលេងឲ្យមើលជាសាធារណៈទេតើ មានទិញសំបុត្រចូលឯណា ?

- ម៉ែ ! តើលុយនេះសម្រាប់ទិញអ្វី ?

— ទេ ! យកទៅ ក្រែងត្រូវការ . . . . រួចបើងស្លៀកពាក់បែបទឹង អ្នកផងគេថាយ៉ាងម៉េចទៅ ?

ប៉ុន្តែអ៊ុយមេស្ហមិនដែលរវល់នឹក អំពីរឿងសម្លៀកបំពាក់វាម្តងណាឡើយ លុះនាងកាមាលារំឭកអំពីរឿងខោអាវ វាគ្រាន់តែញញឹមធ្វើវាហី . . . ។ នាងកាមាលាបោះក្រមាមួយមានផ្កាធំៗ ឲ្យអ៊ុយមេស្ហរុំខ្លួន ព្រោះក្រមានេះស្រីក៏ប្រើបាន ប្រុសក៏ប្រើបាន អ៊ុយមេស្ហពេញចិត្តណាស់ ស្ទុះទៅឱបជើងនាងកាមាលា ដើម្បីសម្តែងអំណររបស់ខ្លួនហើយរត់ចេញទៅ ។

អ៊ុយមេស្តចេញផុតទៅ នាងកាមាលានឹកសង្វេគ បន្សូរទឹកភ្នែកតែម្នាក់ឯង ពេលនោះនាងសិលាចូលទៅដល់ ។

- កាមាលា កូនឲ្យសំបុត្របង់ះមើលផងបានឬទេ ?

( នាងហ៊ានសួរដូច្នេះ ព្រោះនាងធ្លាប់ទុកចិត្តនាងណាស់ នាងមិនដែលមានអាថ៌កំបាំងអ្វីរវាងគ្នាឡើយ ) ។

នាងកាមាលាចង្អុលប្រាប់ . . .

— ន្ទុ! សំបុត្រអ្នកបង ខ្ញុំគ្រាត់ពេលនៅនោះ អ្នកបងមើលចុះ

នាងសិលាមើលបណ្ដើរ ទឹកកង់ចិត្តបណ្ដើរ ។

(ចុះនាងកាមាលាខឹងអ្វីក៏យូរម្ល៉េះ? មួយទៀត សេចក្ដីក្នុងសំបុត្រនេះសុទ្ធតែពាក្យផ្អែមដូចជាមនុស្សទើបនឹងស្រឡាញ់គ្នាដំបូង ? ប៉ុន្តែបើប្ដីសរសេរមកប្រពន្ធខ្លួនបែបនេះ ដូចជាគួរឱ្យចង់សើចណាស់ នាងមិនឆ្ងល់ក៏សួរទៅនាងកាមាលា) ។

— អូនកាមាលា ប្ដីអូនធ្លាប់សរសេរប្រលោមលោកឬ ?

(គ្រាន់តែឮពាក្យថាប្ដី នាងភ្ញាក់ព្រើត)

— ចាស! ខ្ញុំមិនបានដឹងដែរ អ្នកបង ។

ចុះអូនឯងរៀបទៅផ្ទះដែលអូនរៀបចំឥឡូវនេះឬ ?

— នាងកាមាលា មិនឆ្លើយទេ គ្រាន់តែងក់ក្បាល ។

ប៉ុន្តែនាងសិលាជាអ្នកនិយាយច្រើន ក៏ចេះតែនិយាយថែមទៀត?

— បងចង់ទៅនៅលេងជាមួយអូនមួយថ្ងៃ តែខ្លាចមានគេអញ្ជើញទៅភាពាហ៍ពិពាហ៍ខានមិនបាន មិនអីទេ ចាំបងឱ្យម្ដាយបងទៅតាមអូន?

— ចុះអ្នកបងចាំឱ្យអ្នកមីងវិលទឹងខ្ញុំធ្វើអ្វី នៅផ្ទះឯនោះ គ្មានអ្នកបម្រើទេឬ ?

នៅពេលនោះ នាងអូមើរើសបានខ្សែដៃមួយ ក៏តាំងតែគូរពាំសង្វៀដែលនៅជិតដៃនាង ហើយនិយាយខ្ទាំងៗ ដូចជាក្មេងរៀនអក្សរដំបូង ។

នាងសិលាធុញនឹងកូនរពឹសពេក ទៅយកខ្មៅដៃចេញ នាងអ៊ូមីខឹងណាស់ ស្រែកយំអស់ទំហឹង នាងកាមាលាស្ទុះទៅលួង លើកកុមារីពរឡើង យកទៅដាក់ឲ្យអង្គុយលើគ្រែ ហើយដោះកងមាស ១ គូពាក់ឲ្យនាង ។ កុមារីសប្បាយចិត្តណាស់ សើចទាំងទឹកភ្នែករហាម ហើយលើកដៃបង្ហាញម្តាយ ។ នាងសិលាស្ទុះទៅដោះកងពីដៃកូន យកមកឲ្យនាងកាមាលាវិញ ហើយបន្ទោសនាងថា :

—នែ! ប្រយ័ត្នបាត់ណា កុំបណ្តោយឲ្យក្មេងលេងរបៀបនេះ ។

—ខ្ញុំឲ្យទៅវាទេតើ (នាងនិយាយបណ្តើរលួងកុមារីដែលស្រែកយំស្ទើរបែកក្រដាសត្រចៀកបណ្តើរ)

—ទេខ្ញុំ មិនយកវិញទេ អ្នកបងកាត់កងទៅ អ្នកបងអាចធ្វើជាកងកក៏បាន ។

—យី! កាមាលា បងមិនដែលឃើញអ្នកណាដូចអូនសោះ បងសុំអរគុណអូន ។

—អ្នកបង! ខ្ញុំសុំលាអ្នកបងហើយ ថ្ងៃនេះខ្ញុំបានរស់នៅជាមួយអ្នកបង ប្រកបដោយសេចក្តីសុខសប្បាយគ្រប់យ៉ាង ។

(ថាតែប៉ុណ្ណោះ ទឹកភ្នែកហូរច្រោក ធ្វើឲ្យនាងរួលដើមកនិយាយមិនរួច នាងសិលាក៏ទប់ទឹកភ្នែកមិនបានដូចគ្នា) ។

—អូនកុំរៀននិយាយលា ដូចជាគេទៅលែងមកវិញយ៉ាងនេះ ខ្ញុំមិន

ជឿថាៈ យើងទាំងអស់គ្នា ធ្វើឲ្យអូនបានសប្បាយគ្រប់យ៉ាងដូចពាក្យអូនថា ទេ ប៉ុន្តែឥឡូវនេះ អូនត្រូវចូលទៅនៅក្នុងផ្ទះរបស់អូន អ្វី ៗ ទាំងប៉ុន្មាន កំត្រូវតែស្រួលជាងនៅផ្ទះបងហើយ ចាំយើងនាំគ្នាទៅលេងនឹងអូនញយ ៗ តែបន្តិចមុខជាអូនធុញថា "ពុទ្ធោអីយ គេមិនទៅផ្ទះគេវិញទេ ឬយ៉ាងម៉េច ?" មិនអីទេអូនស្អែកព្រឹក យ៉ាងយូរថ្ងៃត្រង់បងទៅដល់ផ្ទះអូនហើយ ។

នាងកាមាណាស្តាប់ហើយ កំនៅស្ងៀម ។

លុះនាងកាមាណាទៅដល់ផ្ទះថ្មី អ៊ុយមេស្ហនៅអង្គុយចាំនាងស្រេចទៅហើយ ។

- ឯងនៅទីនេះនៅឡើយទេ ? ក្រែងទៅមើលល្ខោនឬ ?

- ខ្ញុំទៅមើលទៅហើយ តែលុះខ្ញុំដឹងថាម៉ែមកផ្ទះនេះ . . . . . .

- ទៅ ! ទៅ កុំព្រួយរឿងម៉ែអី មានបោយគេនៅបម្រើហើយ ប្រញាប់ទៅ តិចគេលេងល្ខោនបោល . . . . .

លុះអ៊ុយមេស្ហរៀបដើរចេញទៅ នាងផ្តាំថា:

- ហ្ន ! អ៊ុយមេស្ហ បើលោកមាឯងត្រឡប់មកវិញ ឯង . . . .

(នាងមិនដឹងជាគិតចង់ផ្តាំថាដូចម្តេច អ៊ុយមេស្ហក៏បង្អង់ចាំស្តាប់ចំហារមាត់ជូន ៗ )

- លោកមាជាមិត្តល្អមួយរបស់ឯងណា៎ បើឯងមានការអ្វី និយាយ

ប្រាប់គាត់ទៅ បើឯងស្រឡាញ់ម៉ែ គាត់ច្បាស់ជានឹងជួយដោះទុក្ខឯងមិនខាន ហ្ន៎! ចូរឯងកុំភ្លេចប្រាប់គាត់ថា ម៉ែស្រឡាញ់គាត់ណាស់ ព្ទុះទេ !

— ខ្ញុំមិនភ្លេចទេម៉ែ ! ថាតែប៉ុណ្ណោះអ៊ុយមេស្ហួបផ្តិលកែងរត់វឹងគ្មានបានយកចិត្តពិចារណាអំពីសម្តីនាងកាមាលាផ្តែផ្តាំនោះសោះ ។

ពេលរសៀលនាងកាមាលាហៅអ្នកបំរើមកប្រាប់ :

— នែ ! ខ្ញុំទៅងូតទឹកឯកំពង់ ឯងមិនបាច់ទៅតាមខ្ញុំទេ មើលតែផ្ទះឲ្យត្រឹមត្រូវទៅ ។

ថាហើយនាងហុចប្រាក់មួយរៀលទៅឲ្យ អ្នកបម្រើ រួចចុះដើរតម្រង់ទៅកំពង់ទឹក . . . ។

(នៅមានត)

# ប្រវត្តិគ្រូឡើងរោង ហៅ គ្រូភ្លេង
## នៅកំពង់ចាម

---

តាមពត៌មានដែលសមាជិកប្រចាំខេត្តកំពង់ចាមឈ្មោះ ច៉ាយ-ជេងគួ បានឲ្យដំណឹងមកក្រុមជំនុំទំនៀមទម្លាប់ខ្មែរថា នៅថ្ងៃ ១៤ រោច ខែភទ្របទ ឆ្នាំរកា ត្រូវនឹងថ្ងៃទី ១១ ខែតុលា ឆ្នាំ ១៩៦៩ នេះ នៅផ្ទះគ្រូ ជ៉ុយ ហៅគ្រូភ្លេង មានធ្វើពិធីឡើងរោងមួយយ៉ាងធំ ៗ សមាជិកក្រុមទំនៀមទម្លាប់បាននាំគ្នាទៅយកការណ៍ដល់ទីកន្លែង ដូចមានសេចក្ដីរាយការណ៍ខាងក្រោម :

ក្រុមទំនៀមទម្លាប់បានទៅដល់ក្រុងកំពង់ចាម តាំងតែពីល្ងាចថ្ងៃព្រហស្បតិ៍ទី ៩ ខែតុលា ១៩៦៩ ។ លុះព្រលឹមថ្ងៃទី ១០ តុលា យើងខ្ញុំបានទៅដល់ផ្ទះលោក ចាយ - ហាម នៅកំពង់ចាមក្រុង ។

លោក ចាយ-ហាម មានកូន ៥ នាក់ កូនទី ១ ប្រុស កូនទី២ កើតមកភ្លោះ ប្រុសមួយស្រីមួយ នៅរស់ទាំង ២ នាក់ កូនប្រុសភ្លោះនោះឪពុកឲ្យឈ្មោះ ចាយ - គិមហុង ហៅ " ជ៉ុយ " សព្វថ្ងៃមានអាយុ ២៨ ឆ្នាំ ។ បងប្អូន ៤ នាក់ទៀតរបស់ ជ៉ុយ មានផ្ទះសម្បែង ហើយបែកទីលំនៅតែសព្វខ្លួន ។ ជ៉ុយ នេះបានរៀននៅសាលាបឋមសិក្សា រួចមធ្យមសិក្សា ដល់ថ្នាក់ទី ១ តែឆ្នាំនេះ ត្រូវឈប់ដោយមានការមមាញឹក

ទីពឹងសង្គ្រោះអ្នកផង ដែលចេះតែមករកទាំងថ្ងៃទាំងយប់ ។

ដោយឃើញគ្រូ ជ៉ុយ មានវ័យក្មេងហើយចេះរៀបណ្តាប់គ្រឿងបូជា គ្រឿងសំណែន តាមប្រពៃណីបុរាណសមរម្យពេក យើងទើបឆ្ងល់ ក៏សួរថា ៖

—លោកគ្រូ លោកគ្រូម្តេចមិនគិតរៀនសូត្រនឹងគេ បានជាមកធ្វើគ្រូស្តោះព្រួសនេះទៅវិញ ហើយលោកគ្រូចេះរៀបចំតាមប្រពៃណីបុរាណនេះពីអ្នកណា ? លោកចាប់ធ្វើគ្រូតាំងពីអាយុប៉ុន្មាន ?

គ្រូ ជ៉ុយ ងាកមើលមុខឪពុក ដែលអង្គុយនៅក្បែរបង្អួច រួចក៏ធ្វើសញ្ញាឲ្យយើងខ្ញុំដើរតាមគាត់ទៅក្រោយ ទៅក្បែរអាសនៈព្រះពុទ្ធរូប រៀបកន្លែងឲ្យយើងខ្ញុំអង្គុយស្រួលបួលហើយ ក៏ចាប់ផ្តើមនិយាយ នៅពេលនោះ ពួកសិស្សគណរបស់គាត់កំពុងតែមូរបាយសី ធ្វើជម ធ្វើផ្កាកំពីស្លឹកត្នោត អ្នកខ្លះចំអិនបាយកៀវ អ្នកខ្លះវេញខ្សែចង្កេះ ។ល។ គ្រូជ៉ុយបង្គាប់ការឲ្យគេធ្វើបណ្តើរ និយាយរឿងប្រាប់យើងខ្ញុំបណ្តើរ ។

" កាលខ្ញុំបាទទើបនឹងបានអាយុ ១១ ឆ្នាំ ខ្ញុំបាទចេះតែឈឺ ទៅរៀនសូត្រស្ទើរមិនកើត តែដោយឪពុកខ្ញុំបាទគាត់បង្ខំពេកក៏ចេះតែទៅ ។ ថ្ងៃមួយ ខ្ញុំបាទឈឺនោះខ្លាំងមែនទែន ឈឺយូរទាល់តែជ្រុះសក់ក្បាលនៅរ៉ុយ ៗ ឪពុកម្តាយនឹងបងប្អូនខ្ញុំបាទទាំងអស់ចាញ់ចំណោះរង់ចាំតែពេលស្លាប់ ព្រោះខ្ញុំបាទដាច់អាហារច្រើនថ្ងៃហើយ ។ នៅពេលដែលខ្ញុំបាទ

៖ហៅបាយខ្លាំងពេកនោះ ស្រាប់តែចេញខ្យល់ពីត្រចៀកវិញ ក៏និមិត្តឃើញ



តាចាស់ម្នាក់ផុះពុកចង្កាវែង ដូចរូបខាងលើនេះឯង ស្លៀកសពាក់ស ជួតក្បាលជាតីក្រហម ជិះទូកកំប៉ុតក្បាលមក មានយាយចាស់ម្នាក់ ស្លៀកសពាក់សដូចគ្នា អង្គុយពីក្រោយមកដល់ចំពោះមុខខ្ញុំបាទ ស្រាប់តែយកប្រាក់មកសំពងក្បាលខ្ញុំបាទ ៣ ដង ហើយនិយាយចង្អុលមុខខ្ញុំបាទ ថា «ឯងមានទំនាយត្រូវធ្វើគ្រូសង្គ្រោះគេឯង ត្រូវទទួល តែមិនទទួល

យើងយករូបឯងឥឡូវ ម្យ៉ាងទៀត គេហាត់យើងឲ្យទៅមើលកន្លែងដទៃទៀតហើយ យើងឈប់ថែរក្សាកំណប់ព្រេងរបស់ឯងទៀតហើយ ឯងត្រូវទៅយកមកថែរក្សាខ្លួនឯងចុះ» ឮដូច្នោះ ខ្ញុំបាទសួរថា៖ លោកជាអ្វី បើឲ្យខ្ញុំទៅយក ធ្វើម្ដេចខ្ញុំនឹងដឹងកន្លែង ?

– យើងជាអ្នកសច្ចំ ឯកំណប់របស់ឯងនោះ នៅក្នុងបាលីចាស់ កាលណាឯងទៅយកត្រូវទៅពេលថ្ងៃលិច យកចបតូចមួយទៅផង ឯងត្រូវទៅតែម្នាក់ឯង កុំយកអ្នកណាទៅជាមួយឲ្យសោះ កុំភ័យគ្មានអ្នកណាធ្វើអ្វីឯងទេ តែកាលណាឯងទៅដល់ ឯងស្គាល់កន្លែងរបស់ឯងតែម្ដង ឯងត្រឡប់ទៅរកម៉ែ-ឪឯងវិញចុះ ផឹកតែទឹកត្រាំផ្កាម្លិះទៅជាហើយ» ថាតែប៉ុណ្ណោះ លោកតានោះក៏អន្តរធានទៅ ខ្ញុំបាទដឹងស្មារតីឡើង ឃើញបងប្អូនយំរហាមគ្រប់គ្នា គេស្មានថាខ្ញុំបាទអស់បានជាមនុស្សម្នាទៀតហើយ ព្រោះសន្លប់បាត់មាត់បាត់ក ៣ ថ្ងៃ ៣ យប់ តែខ្លួននៅក្ដៅ ទើបគេមិនទាន់ហ៊ានយកទៅណាមកណា ចេះតែនាំគ្នាចាំមើល ៗ លុះខ្ញុំបាទដឹងខ្លួនឡើង ខ្ញុំបាទនិយាយប្រាប់ ម្ដាយខ្ញុំបាទព្រមទាំងគ្រួសារ គេក៏នាំគ្នាធ្វើពិធីបន់ស្រន់ ព្រមព្រៀងឲ្យខ្ញុំបាទធ្វើត្រូវចុះ ឲ្យតែជាសះស្បើយបានព្រលឹងសម្បុរមកវិញ ៗ

ចាប់តាំងពីពេលនោះមក ខ្ញុំបាទចេះតែទទួលទានទឹកផ្កាម្លិះគ្មានថ្នាំសង្កូវអ្វីក្រៅសោះ តែទទួលទានបួស។ កាលណាក៏ចេះតែមានកម្លាំង

បីដូចបានអាហារពេញពោះ ខ្ញុំបាទក៏ចេះតែបានរើប ៗ ឡើង លុះគ្រាបានដើរ អន្ទុយ ដូចធម្មតា ៗ ប៉ុន្តែយប់ណាក៏ដូចយប់ណា តែកាលណាខ្ញុំបាទទទួលទានដំណេក ចេះតែឃើញយាយចាស់-តាចាស់ដដែលនោះ មកពន្យល់ឲ្យខ្ញុំបាទឲ្យធ្វើគ្រូសង្គ្រោះគេ និងប្រើខ្ញុំបាទ ឲ្យទៅយកកំណប់ព្រេង ៗ

កន្លងប្រហែលជាមួយខែក្រោយអំពីថ្ងៃដែលសន្លប់នោះមក ខ្ញុំបាទដឹងក្នុងខ្លួនថាខ្ញុំជាមែនទែន ៗ ថ្ងៃមួយនៅពេលថ្ងៃលិច ខ្ញុំបាទកាន់ចបមួយតូច ដើរតម្រង់ទៅភ្នំបាលីបាស់ តាមការណ៍ដែលអ្នកសប្តិ៍បានមកប្រាប់សព្វគ្រប់ ៗ ទៅដល់កន្លែងមួយនោះ គ្រាន់តែក្រឡេកឃើញភ្លាម ហាក់ដូចជាប្រាកដក្នុងចិត្តថា "នេះហើយ ដែលជាកន្លែងកំណប់ព្រេង" ទឹកតែប៉ុណ្ណោះ ក៏តាំងជីកមួយរំពេច ជីកបានជម្រៅប្រមាណជាមួយចំអាមប៉ុណ្ណោះ ប៉ះលើគម្របពាងមួយត្រសូវផែះ ! បើកទាំងអាចម៍ល័ក្តដែលគេផ្សារភ្ជាប់គម្របទៅនឹងពាង ខ្ញុំយកចបគាស់គម្របចេញ មើលទៅក្នុងពាងឃើញដាវវែងៗពីររុំដោយអំបោះនៅតាំងពីដងដល់ចុងផ្លែ តែឥតមានច្រេះទេ ដាវនោះដាក់បញ្ឈរក្នុងពាង ដែលមានស្នាមដូចពាងខ្ទះលើយើងសព្វថ្ងៃ ៗ មានគីក៏ទមួយបង្ហើចទៀត វេចនឹងសំពត់ហូលមួយយ៉ាងចាស់ លុះខ្ញុំបាទលូកដៃទៅពាល់ ហូលនោះផុយជ្រុះជាធូលីមួយរំពេច ៗ

នៅក្នុងបង្វេចសំពត់ហូលនោះ មានក្រាំងបុរាណធ្វើអំពីក្រដាស

ផប់ក្បាល ក្បួនស៊ីកតែវែងៗប្រាំក្បាល តម្រាស៊ីកតែខ្លីប្រាំក្បាល មាន ខ្លួបជាក់ប្រេងល្វ-មានផ្តិលសម្រិទ្ធមួយ រូប បដិមាជាច្រើនអង្គធ្វើអំពីសម្រិទ្ធ ទៀបធ្វើអំពីខាត់ ។ល។ ខ្ញុំរើអីវ៉ាន់ទាំងអស់ចេញពីក្នុងពាង រូប យកក្រមារេបស្តាយយកមកផ្ទះវិញ ។



ថ្ងៃបន្ទាប់មក ខ្ញុំបាទយកក្រាំងនិងគម្រាផ្សេងៗនោះមកមើល អក្សររលប់ៗ មើលបានខ្លះមិនបានខ្លះ ស្រាប់តែដូចជាមានអ្វីមកគ្របខ្ញុំបាទ ហើយខ្ញុំបាទដូចជាមើលទៅចេះតែយល់ ចេះតែភ្លឺ. . . ។ ខ្ញុំបាទក៏ចំ

ចេះធ្មញបាលីស្តោះស្ទូនក្នុងក្មេងខ្លះឲ្យចាំ តាមពាក្យដែលអ្នកសប្តិ៍បង្គាប់ ។

ថ្ងៃមួយ មានក្មេងម្នាក់នៅជិតផ្ទះខ្ញុំបាទឈឺ ខ្ញុំបាទនឹកចង់ល្បងមន្ត អាគមខ្ញុំបាទមើល ក៏ស្តុំខ្ទនល ស្តោះក្មេងនោះសាកមើល ស្តោះរួចមិនបានប៉ុន្មានក៏ជា ឮកែសក្តិសិទ្ធិមែន ! ពល់វេលា តែកាលណាខ្ញុំបាទពាល់គ្រង់ណា អ្នកសប្តិ៍មកប្រាប់ខ្ញុំបាទភ្លាម ថែមទាំងបង្គាប់ឲ្យខ្ញុំបាទធ្វើគ្រឿងសក្ការៈផ្សេង ៗ ដែលអស់លោកចូល ហើយសូខ្ញុំបាទនេះ ធ្វើមុខផ្សេង ៗនៃខ្មោច ដែលត្រូវចូលមកស្ថិតលើរូបខ្ញុំបាទ មានមុខឥសីផ្សេង ៗ មុខព្រះបាទទសមុខ មកុដព្រះឥន្ទ្រាស់ក្រពុំឈូក .. ។ល។ ទិងសម្លៀកបំពាក់តាមតួខ្មោច ដែលចូលមកសណ្ឋិតនោះ ប៉ុន្តែខ្ញុំបាទពុំទាន់មានប្រាក់កាសទិញផ្គរ គ្រប់ប្រដាប់ទេ លុះតាយចសប្រទ៍ឲ្យអ្នកស្រុក អ្នកភូមិជិតខាង បានប្រាក់កាសមក ក៏ខំសន្សំជួលជាងខាងសាលាវិចិត្រសិល្បៈ ធ្វើមុខម្តងមួយ ម្តងមួយ ព្រោះមុខមួយថ្លៃដល់ទៅមួយពាន់ប្រាំរយរៀល ។

ក្រោយមកទៀត លោកចាយ បា ម បាននិយាយប្រាប់យើងខ្ញុំថា « មានចិនអ្នកកេសម្នាក់នៅចំការលើ ខាងខេត្តកំពង់ចាមនេះដែរ គាត់ជាអ្នកមានទ្រព្យសម្បត្តិ ថ្ងៃមួយក្នុងពេលយប់ចោរចាប់ខ្លួនគាត់យកទៅ ហើយបង្គាប់ឲ្យយកប្រាក់ទៅលោះជាច្រើនម៉ឺនរៀល ។ ប្រពន្ធគាត់ភ័យណាស់ ណាមួយរកប្រាក់លោះប្តីមិនបាន ណាមួយខ្លាចចោរសម្លាប់ប្តី ក៏រត់ទៅ

រកគ្រូជ៉ុយឲ្យជួយ ត្បិតគាត់ទាល់គំនិតអស់ផ្លូវសៀម ។ គ្រូជ៉ុយក៏ប្រាប់ឲ្យរៀបរណ្តាប់ថ្វាយគ្រូគាត់ ហើយគាត់ប្រាប់ថា “មិនអីទេ ចាំយើងជួយអ៊ីឯង យើងឲ្យប្តីអ៊ីរត់រួចមកវិញ” ។ ប៉ុន្មានថ្ងៃក្រោយមក ចិននោះក៏បានមកដល់ផ្ទះវិញ សួរទៅថាលួចរត់មកមែន ទើបចេះតែមានអ្នកជឿចូលទៅពឹងពាក់កាន់តែច្រើនឡើង ច្រើនឡើង ឯចិនដែលចោរចាប់នេះនៅរស់សព្វថ្ងៃ គ្រូ ជ៉ុយ បានប្រាប់ឈ្មោះសព្វគ្រប់ដែរ តែយើងខ្ញុំមិនបានចាំ ។

សព្វថ្ងៃនេះ នៅផ្ទះគ្រូជ៉ុយ មានធ្វើពិធីសៀនគ្រូរាល់ថ្ងៃសីល តែថ្ងៃ ១៥ កើតនិងថ្ងៃខែដាច់ ធ្វើធំជាងថ្ងៃសីលធម្មតា ហើយបើប្រសិនជាថ្ងៃសីល នោះត្រូវលើថ្ងៃសៅរ៍ ក៏ត្រូវរៀបធំដែរ ។

អ្នកស្រី ពេជ សល់

ទីស្ដីការរដ្ឋមន្ត្រី
ក្រសួងធម្មការ
លេខ ២១ កធ

ព្រះរាជាណាចក្រកម្ពុជា

# សារាចរ

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
ទទួលបន្ទុកក្រសួងធម្មការ និង សាសនសិក្សាធិការ
ជម្រាបមកសហជីវិនប្រតិភូរាជរដ្ឋាភិបាល ប្រចាំក្រុងកែប
បូកគោ និង ខេត្តកណ្ដាល
ជម្រាមកសហជីវិន អភិបាលក្រុង-អភិបាលខេត្ត-អនុខេត្ត
ក្នុងព្រះរាជាណាចក្រ

កម្មវត្ថុ : ព្រះសង្ឃដីកាសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកគណៈមហានិកាយលេខ ៥៤ គ-កសម ចុះថ្ងៃទី ២៩ តុលា ១៩៦៩ ស្ដីអំពីការប្រតិបត្តិឲ្យត្រឹមត្រូវតាមគន្លងធម៌វិន័យនិងឲ្យមានសាមគ្គីធម៌ ។

យោង : តាមបុគ្គលឃ្លាយក្រសួងធម្មការលេខ ១០៦២.កធ. ចុះថ្ងៃទី ៨-១១-៦៩ ។

ដ្បិតមានព្រះសង្ឃដីកា សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកគណៈមហានិកាយដូចមានចែងក្នុងកម្មវត្ថុខាងលើ ដែល

ប្រគេនចំពោះព្រះសង្ឃជាព្រះរាជាគណៈ ឋានានុក្រម មេគណ អនុគណ ចៅអធិការ មេក្រុម មេកុដិ មួយអន្លើដោយភិក្ខុសង្ឃសាមណេរទាំងអស់ គ្រប់វត្តនៃគណៈមហានិកាយ សូមប្រតិបត្តិឲ្យបានត្រឹមត្រូវតាមគន្លងព្រះធម្មវិន័យនៃព្រះសម្ពុទ្ធបរមគ្រូ និង សូមឲ្យមានសាមគ្គីធម៌រវាងគ្នានិងគ្នា ដូចបានជូនដំណឹងតាមលិខិតដែលយោងខាងលើ ។

សេចក្តីនេះ សុំសហជីវិន ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង-ខេត្ត អភិបាលក្រុង អភិបាលខេត្ត-អភិបាលអនុខេត្ត ប្រគេនព្រះសង្ឃដីកានេះ ទៅព្រះរាជាគណៈ មេគណ អនុគណ និង ចៅអធិការ វត្តគណៈ មហានិកាយ សុំឲ្យប្រតិបត្តិតាមសេចក្តីរំលឹកដាស់តឿនក្នុងព្រះសង្ឃដីកានេះ ហើយសុំឲ្យសហជីវិនរួបរួមជាមួយព្រះមេគណ ដើម្បីថែរក្សានូវសាមគ្គីធម៌ នៅគ្រប់វត្ត ជាប្រយោជន៍សេចក្តីសុខ ចំរើន ថ្កុំថ្កើងរុងរឿង ក្នុងព្រះពុទ្ធសាសនា និង ប្រទេសជាតិយើងតទៅ ។

ភ្ជាប់មកជាមួយនេះព្រះសង្ឃដីកាលេខ ៨៤ ត-កសម ចុះថ្ងៃទី ២៩ តុលា ១៩៦៩ ចំនួន . . . . . ច្បាប់ ។

ភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ១៩៦៩

ទី-ឡូង

# ព្រះសង្ឃដីកា

សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក គណៈមហានិកាយ

*ប្រគេនដំណឹងមកសម្តេច ព្រះរាជាគណៈ ឋានានុក្រម មេគណ អនុគណ ចៅអធិការ និងព្រះរាជាគណៈ ឋានានុក្រម មេក្រុម និង មេកុដិ គ្រប់វត្ត នៃគណៈមហានិកាយ ក្នុងក្រុង ខេត្ត និងអនុខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។*

*ដ្បិតបន្ទាប់ពីការសោយព្រះទិវង្គត នៃសម្តេចព្រះមហាសុមេធាធិបតី* **ជ. ណ.** ព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ *សម្តេចព្រះ-* **នរោត្តម - សីហនុ** *ព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ និងជាព្រះអគ្គពុទ្ធ-សាសនូបត្ថម្ភក៍ បានទ្រង់សព្វព្រះរាជហឫទ័យ តែងតាំងខ្ញុំជា* សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក គណៈមហានិកាយ *ដោយព្រះរាជក្រឹត្យលេខ ២៩.ររ. ចុះថ្ងៃទី ២៧ កញ្ញា ១៩៦៩ ដើម្បីគ្រប់គ្រងគណៈសង្ឃ ក្នុងគណៈមហានិកាយ ស្នងអង្គសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ដែលទ្រង់សោយព្រះទិវង្គត ។*

*ក្នុងឋានៈខ្ញុំជាព្រះសង្ឃនាយក ខ្ញុំសូមគោរពចំពោះសម្តេច និងសម្តែងនូវមនោសញ្ចេតនាប្រកបដោយសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រចំពោះ ព្រះរាជាគណៈ ឋានានុក្រម មេគណ អនុគណ ចៅអធិការ មេក្រុម*

មេកុដិ មួយអន្ទើដោយភិក្ខុសង្ឃ សាមណេរទាំងអស់ គ្រប់វត្តនៃគណៈ មហានិកាយ ហើយខ្ញុំសូមឆ្លៀតឱកាសនេះ ផ្ញើព្រះសង្ឃដីកាសន្ទេសមួយ ដើម្បីរំលឹកចំពោះភិក្ខុសង្ឃទាំងអស់ នៃគណៈមហានិកាយ ដូចតទៅ :

១— សូមឲ្យភិក្ខុសង្ឃគ្រប់វត្ត មានការយល់ឃើញត្រឹមត្រូវតាម គន្លងព្រះធម៌វិន័យនៃព្រះសម្ពុទ្ធបរមសាស្តា មានការព្រមព្រៀងគ្នា មានការស្រឡាញ់រាប់អានគ្នាជាសហធម្មិកយ៉ាងជិតស្និទ្ធ ហើយប្រតិបត្តិកុំឲ្យខុសឃ្លាងឃ្លៀងឃ្លាតចាកព្រះពុទ្ធវចនៈឡើយ ព្រោះថាបព្វជិតមួយរូប ៗ មិនគួរប្រកាន់អស្មិមានះ បង្កជម្លោះឈ្លោះទាស់ទែងរវាងបព្វ-ជិតផងគ្នា និងរវាងពុទ្ធបរិស័ទជាគ្រហស្ថនោះទេ ។ បព្វជិតគ្រប់រូបគួរតែមានសទ្ធាចិត្តប្រកបដោយខន្តី ចេះអត់ធន់ ចេះទប់ចិត្ត មានគំនិតមិនអធ្យាស្រ័យចេះអត់ឱន ចំពោះបព្វជិតផងគ្នា និងចំពោះគ្រហស្ថ ដែលជាទាយកទាយិកាទូទៅផង ។ បព្វជិតគ្រប់រូប មានឈ្មោះថា សមណៈសក្យបុត្តិយ៍ ជាអ្នកស្ងប់រម្ងាប់ និងជាអ្នករំលត់នូវហឹង្សាគ្រប់ប្រការ មិនគួរបណ្តោយចិត្តអាក្នាឲ្យក្តៅក្រោធ រហូតដល់បណ្តាលទៅជាមានរឿងអធិករណ៍ នាំឲ្យសៅហ្មងដល់ព្រះពុទ្ធសាសនាឡើយ ។ ព្រះសម្ពុទ្ធបរម-សាស្តារបស់យើង បានសម្តែងចំពោះភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ឲ្យមានសាមគ្គីព្រមព្រៀងគ្នា ហើយឲ្យប្រតិបត្តិតាមព្រះធម្មវិន័យ ដែលជាឫសគល់នៃព្រះពុទ្ធសាសនា ។ ព្រះអង្គបានរំលឹកដាស់តឿនភិក្ខុសង្ឃ

មិនឲ្យបង្កអធិករណ៍ណាមួយឡើយ សមដូចព្រះពុទ្ធដីកាក្នុងគម្ពីរមហាវគ្គ ត្រង់កោសម្ពិកខន្ធកៈ ដែលដកស្រង់គោល ១ ខ្លះមកបង្ហាញជាក់ស្តែងថា "ម្នាលភិក្ខុទាំងឡាយ ចូរអ្នកព្រមព្រៀងគ្នា ចងគ្នាជាបាច់ ៗ ចូរអ្នកកុំបង្កហេតុ ឲ្យកើតទៅជារឿងទាស់ទែងខ្វែងគំនិតគ្នា កុំឈ្លោះគ្នាឡើយ ព្រោះអ្នកពលគ្នា សុទ្ធតែបួសរៀនតាមធម៌វិន័យរបស់តថាគត ។ ការខ្វែងគំនិតគ្នា និងការបង្កអធិករណ៍មិនចេះឈប់ឈរនេះ ជាមន្ទិលសៅហ្មងដ៏អាក្រក់ អាចធ្វើឲ្យសាសនាតថាគត វិនាសសាបសូន្យបាន ហើយជាហេតុឲ្យមានសេចក្តីទុក្ខផង" ។

ម្យ៉ាងទៀត សូមឲ្យភិក្ខុសង្ឃចេះគិតពិចារណា កុំប្រកាន់យកខុសជាត្រូវ ដោយគាំងថាខ្លួនធ្លាប់ប្រតិបត្តិមកយូរហើយនោះឡើយ ដូចមានសេចក្តីមួយវគ្គ ក្នុងព្រះរាជសុន្ទរកថា នៃសម្តេចព្រះប្រមុខរដ្ឋ នៅឱកាសពិធីថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ ចំពោះសម្តេចព្រះសង្ឃរាជថាក់ទី ១ថា "អ្នកខ្លះនិយាយខុសទាំងស្រុងថា នៅក្នុងសាសនាយើង មានធម៌ថ្មី ធម៌ចាស់ ។ តាមការពិត យើងពុំមានធម៌ពីរទេ ។ ដែលនិយាយថា ធម៌ថ្មីនោះ គឺការដែលចំសម្រិតសម្រាំងព្រះសាសនាឲ្យផុតអំពីជំនឿខុស អំពីការយល់ហួសហេតុផល និងអំពីទម្លាប់ខុស គឺពុំមែនធ្វើឲ្យព្រះពុទ្ធសាសនាទៅជាបែបថ្មីទេ ។ ការពិត គឺធ្វើឲ្យព្រះសាសនា ត្រឡប់ទៅរកប្រកតដើមដ៏ត្រឹមត្រូវល្អវិញ តែប៉ុណ្ណោះ" ។

២- សូមឲ្យភិក្ខុសង្ឃ ក្នុងគណៈមហានិកាយទាំងអស់ តាំងចិត្តសម្រិតសម្រាំងឲ្យមានសាមគ្គីធម៌រវាងគ្នានិងគ្នា ធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រិះរកមធ្យោបាយ ដើម្បីកម្ចាត់នូវអធិករណ៍គ្រប់បែបយ៉ាងទាំងអស់ ដែលនឹងកើតមានក្នុងអនាគតកាល ។ រីឯអធិករណ៍ទាំងឡាយដែលបានកើតមានរួចហើយមកទល់នឹងពេលនេះ សូមឲ្យភិក្ខុសង្ឃបំភ្លេចបំបាត់ចោលត្រឹមនេះទៅចុះ ហើយបែរមុខឆ្ពោះទៅរកសេចក្ដីប្រតិបត្តិដ៏ត្រឹមត្រូវតាមព្រះធម្មវិន័យ នៃព្រះសម្ពុទ្ធបរមគ្រូរបស់យើងឡើងវិញ ។ សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ជាអម្ចាស់ កាលព្រះអង្គគង់ព្រះជន្មាយុនៅឡើយ ព្រះអង្គមានបំណងនឹងកម្ចាត់រឿងអធិករណ៍ផ្សេង ៗ ក្នុងព្រះពុទ្ធសាសនាឲ្យអស់រលីង ប៉ុន្តែទ្រង់មានព្រះកាយពលខ្សោយពេក ដោយជរាធម៌ ទ្រង់ក៏ពុំអាចសម្រេចការនេះ ឲ្យសម្រេចតាមព្រះរាជហឫទ័យបាន ហើយទ្រង់ក៏សោយព្រះទិវង្គតទៅ ។

ដូច្នេះ សូមឲ្យភិក្ខុសង្ឃគ្រប់វត្ត ប្រតិបត្តិដោយត្រឹមត្រូវតាមគន្លងព្រះធម៌វិន័យ កុំបីធ្វេសប្រហែសឲ្យសោះ ។ ប្រសិនបើវត្តណា ដែលមានអធិករណ៍មកយូរហើយក្ដី កំពុងមានអធិករណ៍នឹងគ្នាសព្វថ្ងៃនេះក្ដី ហើយអធិករណ៍នោះពុំទាន់ស្ងប់ស្ងាប់ សូមភិក្ខុសង្ឃនៅវត្តនោះ ព្រមទាំងពុទ្ធបរិស័ទជើងវត្តនោះ តាំងចិត្តជាថ្មី បញ្ចប់អធិករណ៍នោះឲ្យបានសម្រេចដោយជោគជ័យ ដើម្បីជាកិច្ចតបស្នងព្រះមហាករុណាធិគុណ នៃព្រះ-

សម្តេចជាម្ចាស់ ដែលកាលព្រះអង្គទ្រង់គង់ធរមាននៅឡើយ ព្រះអង្គតែងប្រទាននូវព្រះបរមពុទ្ធោវាទ ចំពោះភិក្ខុសង្ឃជាកូនចៅព្រះអង្គ កុំឲ្យមានរឿងអធិករណ៍រវាងគ្នានិងគ្នា ព្រោះថា រឿងអធិករណ៍ ជាហេតុនាំឲ្យមានទុក្ខ និងជាហេតុនាំឲ្យវិនាស ។ ព្រះអង្គទ្រង់ប្រដៅភិក្ខុសង្ឃឲ្យមានសាមគ្គីធម៌រវាងគ្នានិងគ្នាតរៀងទៅ ព្រោះសាមគ្គីធម៌ជាហេតុនាំឲ្យមានសុខសាន្ត ។ ជាពិសេសទៅទៀត ការបញ្ចប់អធិករណ៍នេះ ទុកជាកិច្ចតបស្នងព្រះឧបការគុណ នៃសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ដែលទ្រង់ទើបនឹងសោយព្រះទិវង្គតនេះផង ព្រោះកាលសម្តេចគង់ព្រះជន្មនៅឡើយ ទ្រង់តែងបំពេញកិច្ចការជាប្រយោជន៍ដល់ភិក្ខុសង្ឃ កុំឲ្យកើតវិវាទរវាងគ្នានិងគ្នា រហូតដល់ពេលសោយព្រះទិវង្គត ។

ខ្ញុំមានសង្ឃឹមយ៉ាងមាំថា សម្តេចព្រះរាជាគណៈ ឋានានុក្រមគ្រប់តំណែង ជាពិសេស ភិក្ខុសង្ឃទាំងអស់ ក្នុងគណៈមហានិកាយ មុខជានឹងប្រតិបត្តិតាមព្រះសង្ឃដីកានេះ ហើយនឹងមានសាមគ្គីរវាងគ្នានិងគ្នាប្រតិបត្តិតាមព្រះធម៌វិន័យ ឧបត្ថម្ភព្រះពុទ្ធសាសនា ឲ្យបានរុងរឿងស្ថិតស្ថេរចីរកាលតរៀងទៅ ។

ចំណែកពុទ្ធបរិស័ទជាគ្រហស្ថទាំងឡាយ ក៏គប្បីតាំងចិត្តគោរពប្រតិបត្តិតាមព្រះពុទ្ធឱវាទឲ្យបានត្រឹមត្រូវ ហើយគប្បីតាំងចិត្តឲ្យមានសាមគ្គីធម៌ ជាមួយនឹងភិក្ខុសង្ឃផងដែរ ។ លុះតែពុទ្ធបរិស័ទទាំងបព្វជិត ទាំង

គ្រហស្ថ រួបរួមគ្នាធ្វើយ៉ាងនេះ ទើបព្រះពុទ្ធសាសនាក្នុងប្រទេសយើងនឹង
មានដំណើរទៅកាន់វឌ្ឍនភាពយ៉ាងបរិបូណ៌ ។

ធ្វើនៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ នៅថ្ងៃពុធ ៣ រោច ខែអស្សុជ
ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនឹងថ្ងៃទី ២៩ ខែតុលា គ.ស. ១៩៦៩

សម្ដេចព្រះមហាសុមេធាធិបតី
ព្រះសង្ឃនាយក គណៈមហានិកាយ
ហួត-តាត (វជិរប្បញ្ញោ)

បានឃើញហើយ
យល់ព្រម
រដ្ឋលេខាធិការក្រសួងធម្មការ
**ឌី-ទូច**
ឧត្តមមន្ត្រី



# បុគ្គលិកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ
# ចូលក្រាបបង្គំគាល់ព្រះបរមសពនៃសម្ដេចព្រះសង្ឃរាជ
# ជោតញាណោ ជួន-ណាត

ថ្ងៃអង្គារទី ៣ ខែធ្នូ គ.ស. ១៩៦៩ វេលាម៉ោង ៩ ព្រឹក បុគ្គលិកទាំងអស់ នៃវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យទាំងព្រះសង្ឃទាំងគ្រហស្ថក្រោមព្រះអធិបតីភាពនៃសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ ក្នុងព្រះឋានៈជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក និងក្រោមការណែនាំនៃសហជីវិន លាង ហាប់អាន នាយកនៃវិជ្ជាស្ថាននេះ បានជួបជុំគ្នានិមន្តព្រះសង្ឃ ធ្វើទក្ខិណានុប្បទាន និងចម្រើនព្រះសត្តប្បករណាភិធម្ម បង្សុកូលព្រះបរមសពនៃសម្ដេចព្រះសង្ឃរាជ ជោតញាណោ ជួន-ណាត ដែលព្រះអង្គទ្រង់មានព្រះគុណូបការដ៏ធំធេងចំពោះវិជ្ជាស្ថានពុទ្ធ-សាសនបណ្ឌិត្យតាំងពីគ្រឹះស្ថាននេះកកើតឡើង រហូតដល់ពេលសព្វថ្ងៃ ។ បើគេរំឭកឡើងវិញនូវប្រវត្តិរបស់ពុទ្ធសាសនបណ្ឌិត្យ ក៏គេពុំអាចបំភ្លេចព្រះបរមនាមនៃសម្ដេចព្រះសង្ឃរាជអង្គនេះបានឡើយ ព្រោះបំណងធំនៃវិជ្ជាស្ថាននេះឯង គឺការស្រាវជ្រាវរកក្បួនច្បាប់ទាំងផ្នែកវប្បធម៌ខ្មែរ និងផ្នែកពុទ្ធសាសនា ដើម្បីយកមករក្សាទុកផង និងពិនិត្យផ្ទៀងផ្ទាត់សម្រាប់បោះពុម្ពផ្សាយផង ៗ មិនតែប៉ុណ្ណោះ ទីនេះ ជាទីផ្សាយនូវធម៌វិន័យ

តាមមធ្យោបាយបោះពុម្ពជាសៀវភៅ ឬការបង្ហាត់បង្រៀនផ្ទាល់ ៗ ខ្លួនផង ។ ការងារទាំងនេះហើយ ដែលព្រះបរមសពសម្តេចព្រះសង្ឃរាជ កាលទ្រង់គង់ព្រះជន្មាយុនៅឡើយ ព្រះអង្គបានបំពេញយ៉ាងសកម្មបំផុត ជាមួយសហធម្មិករបស់ព្រះអង្គ ៤ រូបទៀត គឺព្រះសពព្រះឧត្តមមុនីអ៊ុម-ស៊ូ, ព្រះសពព្រះវិមលធម្មថោង, ព្រះសពសម្តេចព្រះធម្មលិខិត ល្វី-ឯម និងសម្តេចព្រះសង្ឃនាយកគណៈមហានិកាយសព្វថ្ងៃនេះ ។

ក្រោយដែលបានជួបជុំគ្នាហើយ ពិធីនមស្សការព្រះរតនត្រ័យ ក៏ចាប់ផ្តើមឡើង បន្ទាប់មកសហជីវិន លាង ហ៊ាប អាង ថ្លែងសុន្ទរកថាមួយសម្តែងសមានចិត្ត ភក្តី និងកតញ្ញូតាធម៌ ចំពោះព្រះបរមសព មានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

សូមព្រះតេជៈតម្កល់លើត្បូង
សូមក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ នៃព្រះ
បរមសពសម្តេចព្រះសង្ឃរាជជាអម្ចាស់
សូមទ្រង់ជ្រាប ៕

សម្តេចជាអម្ចាស់ !

ក្នុងព្រះបរមនាមនៃសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកជាព្រះអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ព្រមទាំងព្រះសង្គីតិកាចារ្យជាសមា-

ដឹក ដែលមានព្រះតេជៈព្រះគុណព្រះមុនីកោសល ស៊ួរ-ហាយ ជា ព្រះអធិបតីវង្ស និងព្រះពុទ្ធាចារ្យ ហ៊ី-ជា ជាអាទិ៍, ក្នុងនាមនៃបុគ្គលិកទាំងអស់នៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមចូលមកគោរពចំពោះព្រះបរមសពនៃល្អងធូលីព្រះបាទ ដោយនាំមកនូវកម្រងផ្កា ទេយ្យវត្ថុ ព្រមទាំងបច្ច័យបួន ដើម្បីនិមន្តព្រះសង្ឃចម្រើនព្រះសត្តប្បករណាភិធម្មបង្សុកូល ឧទ្ទិសបុញ្ញកុសលថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធព្រះករុណាថ្លៃវិសេស សូមសម្តេចជាអម្ចាស់មេត្តាទទួលនូវកុសលផលបុណ្យនេះ អំពីទូលព្រះបង្គំជាខ្ញុំដោយព្រះមេត្តា ។

បពិត្រសម្តេចជាអម្ចាស់ !

ពិតមែនតែព្រះរូបព្រះកាយសម្តេច បានរលត់ទៅហើយក៏ដោយ ក៏ព្រះបរមកិត្តិនាម ព្រះរាជកេរ្តិ៍នៃល្អងធូលីព្រះបាទ បានដិតជាប់នៅក្នុងហឫទ័យ របស់ទូលព្រះបង្គំទាំងអស់គ្នាជានិច្ចអស់កល្បាវសាន ។ ទូលព្រះបង្គំយើងខ្ញុំមានសេចក្តីពេញចិត្តឥតឧបមា ដោយកាលសម្តេចជាអម្ចាស់គង់ព្រះជន្មនៅឡើយ ទូលបង្គំទាំងអស់គ្នា បានបំពេញករណីយកិច្ចក្នុងមុខការរបស់ខ្លួនតាមការសព្វព្រះរាជហឫទ័យ ដូចជា :

ទី ១- បានខិតខំពិនិត្យបោះពុម្ពព្រះត្រៃបិដកចប់សព្វគ្រប់ទាំង ១១០ ភាគ ដែលជាទំហំការងារយ៉ាងធំ មានរយៈវេលាប្រមាណ ៤០ ឆ្នាំ ។ គ្រាន់តែក្នុងរយៈវេលា ៣ ឆ្នាំប៉ុណ្ណោះ វិជ្ជាឋានបានប្រឹងញាប់ការបោះ

ពុម្ពផ្សាយព្រះពុទ្ធវចនៈនេះ បានដល់ទៅ ៣៨ ភាគ ។ ចំពោះកិច្ចការ
បម្រើនព្រះពុទ្ធសាសនានេះ ទូលព្រះបង្គំយើងខ្ញុំ មានសោមនស្សខ្លាំង
ទៅទៀត ដោយបានរួបរួមធ្វើពិធីសម្ពោធជូនគម្ពីរព្រះត្រៃបិដកទាំង ១១០
ភាគនេះ ជាឧឡារិកបានមុនការសោយព្រះទិវង្គតនៃសម្ដេចតែត្រឹម ៥ ខែ
បាយប៉ុណ្ណោះ, គឺជាបានតបស្នងព្រះមហាករុណាធិគុណ នៃសម្ដេចតាន់
ទ្រង់គង់ព្រះជន្មាយុនៅឡើយ ។

ទី ២. បានរៀបចំតាំងគណៈកម្មការពិសេស ដែលមានសមាជិកជា
ព្រះសង្ឃ និងគ្រហស្ថ គឺព្រះសាសនមុនី ភិម ទូរ, ព្រះញាណវង្ស
អ៊ុម ស៊ុម, លោក ញ៉ូង សឿង, និងចោង សំអ៊ុ, ដើម្បីរៀប
ចំផ្ទៀងផ្ទាត់បន្ថែមនូវពាក្យពេចន៍ បោះពុម្ពផ្សាយវចនានុក្រមខ្មែរទាំង ២
ភាគ ជាលើកទី ៥ ក្រោមព្រះរាជូបត្ថម្ភ ផ្ទាល់នៃសម្ដេចជាអម្ចាស់និងបាន
ហើយស្រេចតាំងពីឆ្នាំ ១៩៦៧ ។ កិច្ចការនេះនៅតែបន្តមកទៀត ទោះ
បីបានបោះពុម្ពសព្វគ្រប់ហើយក៏ដោយ កំណត់ចូលព្រះបាទសព្វព្រះរាជ
ហឫទ័យទ្រង់ការតាំងយប់តាំងថ្ងៃ គ្មានពេលល្ហែ ជាហេតុបណ្ដាលឲ្យ
ព្រះរោគមកញាំញីព្រះកាយរហូតដល់ស្ដេចសោយព្រះវិលាល័យ មុននឹង
សម្រេចបោះពុម្ពលើកទី ៦ ។

ទី ៣. បានប្រោះព្រំធ្វើពិធីបុណ្យរំលឹកខួបនៃក្រសួង ចាប់ពីឆ្នាំ
១៩៤៥ មក ដើម្បីឧទ្ទិសកុសលនិងសម្ដែងនូវកតញ្ញូតាធម៌ចំពោះវិញ្ញាណ

កូន នៃព្រះមហាក្សត្រ ព្រះសង្ឃគិតាចារ្យ គរុបណ្ឌិត ដែលមានព្រះគុណ បំពោះវិជ្ជាឋាន តាំងពីថ្ងៃកើតមកនោះ ។

ទី ៤- បានមរង្គើនការបោះពុម្ពផ្សាយនូវពុទ្ធវចនៈ ដែលអ្នកនិពន្ធ បច្ចុប្បន្នបានរៀបរៀងជាសៀវភៅ ដូចជាស្នាព្រះហស្តសម្តេចព្រះសង្ឃ នាយកជាម្ចាស់ជាដើម ។

ទី ៥- បានទាក់ទងនឹងក្រសួងអប់រំជាតិ (គណៈកម្មការខាងរៀបបំ កម្មវិធីសិក្សា) ដើម្បីបញ្ចូលនូវសៀវភៅផ្នែកពុទ្ធបក្រមួយចំនួនធំ ទៅ ក្នុងកម្មវិធីមធ្យមសិក្សាខាងសាលាគ្រហស្ថ ឲ្យស្របទៅតាមព្រះរាជហឫ- ទ័យនៃល្អងធូលីព្រះបាទ និងព្រះចិន្តាប្រោសប្រណីឧបត្ថម្ភ នៃសម្តេច ព្រះសង្ឃនាយក តាមសេចក្តីសម្រេចរបស់សមាជជាតិ ។

ទី ៦- បានរើរៀប បំពោះពុម្ពជាថ្មីនូវសៀវភៅ "គិត្តុបាដិមោក្ខ បាលី" បោះពុម្ពលើកមុនមានខុសអក្ខរាវិរុទ្ធ និងឃ្លៀងឃ្លាតលក្ខណៈ ដើមខ្លះនោះ ដើម្បីតម្រូវតាមសព្ទព្រះរាជហឫទ័យ ។

ទី៧- បានទទួលព្រះបរមរាជបញ្ជាបោះពុម្ពនូវសៀវភៅ "កច្ចាយនូ- បត្ថម្ភ" ជាស្នាព្រះហស្តផ្ទាល់របស់ល្អងធូលីព្រះបាទ ដែលបោះពុម្ព លើកក្រោយបានកែប្រែខ្លះខុសព្រះរាជហឫទ័យនោះ ឲ្យបានត្រឹមត្រូវដូច ដើមឡើងវិញ ។

ទី ៨- បានបន្ទាបនូវអ្នកនិពន្ធគ្មានការអៀនខ្មាសខ្លះ និងឈ្មួញ

ខិលខូចមួយចំនួន ដែលចូលចិត្តតែលួចដកស្រង់យកអត្ថបទត្រង់ ៗ ឬទាំងស្រុងអំពីសៀវភៅជាសម្បត្តិជាតិនិងជាស្នាដៃរបស់បុព្វបុរស យកទៅបោះពុម្ពលក់ ធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ដោយក្រសួងខិតខំទាញសតិសម្បជញ្ញអ្នកទាំងនោះ ឲ្យបេះមានហិរិឱត្តប្ប ខ្លះ ៗ មកវិញ ។

ទី ៩- បានរៀបចំបោះពុម្ពនូវសៀវភៅ អដ្ឋកថា ជាភាសាបាលី ដែលក្រុមជំនុំព្រះត្រៃបិដកបានរៀបរៀងប្រមូលសព្វគ្រប់ហើយនោះ ដើម្បីបន្ថែមបង្គ្រប់ទៅលើគម្ពីរព្រះត្រៃបិដកទាំង ១១០ ភាគ តាមសេចក្ដីសព្វព្រះរាជហឫទ័យនៃល្អងធូលីព្រះបាទ ។

សម្ដេចជាអម្ចាស់ !

លទ្ធផលទាំងប៉ុន្មានដែលវិទ្យាឋានបានសម្រេចហើយខាងលើនេះ គឺកើតឡើងដោយសារព្រះរាជកិច្ចណែនាំផ្ទាល់របស់ល្អងធូលីព្រះបាទ និងរបស់សម្ដេចព្រះសង្ឃនាយកជាម្ចាស់ ។ ខ្ញុំព្រះបង្គំយើងខ្ញុំ សូមសន្យាថានឹងបន្តការងារបម្រើជាតិ សាសនា ព្រះរាជបល្ល័ង្ក និងព្រះត្រៃរតន៍ តាមព្រះរាជបណ្ដាំរបស់ល្អងធូលីព្រះបាទជានិច្ច ។ ចំពោះវចនានុក្រមខ្មែរ ដែលសម្ដេចជាអម្ចាស់សព្វព្រះរាជហឫទ័យស្នើព្រះនេត្រ ព្រះករុណានោះ ខ្ញុំព្រះបង្គំយើងខ្ញុំនឹងរក្សាទុកនូវគណៈកម្មការដែលធ្លាប់ធ្វើការក្រោមព្រះរាជឧបត្ថម្ភរបស់ល្អងធូលី តាំងពីព្រះអង្គគង់ព្រះជន្មនៅនោះ ឲ្យបន្តការងាររហូតដល់បោះពុម្ពចប់ជាលើកទី ៦ នាឆ្នាំ ១៩៧០ ខាងមុខនេះ ។

ទូលព្រះបង្គំយើងខ្ញុំនឹងសម្រេចសូមដាក់នាមវចនានុក្រម ដែលបម្រុង បោះពុម្ពថា "វចនានុក្រម ជួន ណាត" ព្រមទាំងដាក់ព្រះបរមនាមលក្ខណ៍ព្រះអង្គដើម្បីគោរពតាមព្រះរាជបណ្ដាំថា "កាលណាអត់ពីអាត្មាទៅ វចនានុក្រមដែលអាត្មាបានពិត្រួសត្រាយធ្វើនេះ តាមតែអស់លោកដាក់នាម ដាក់រូបអាត្មាយ៉ាងណាក៏ដោយចុះ ប៉ុន្តែឥឡូវនេះ គឺពេលអាត្មានៅរស់ សុំដាក់ត្រឹម "វចនានុក្រមខ្មែរ" តែប៉ុណ្ណោះចុះ ។

ជាទីបញ្ចប់ ទូលព្រះបង្គំជាខ្ញុំទាំងអស់សូមលើកបុញ្ញកុសលក្នុងពិធីបង្សុកូលនេះថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃសម្ដេចជាអម្ចាស់ ! សូមទ្រង់បានគង់នៅជាបរមសុខក្នុងសុគតិភព រហូតដល់សម្រេចនូវសម្បត្តិព្រះនិព្វានជាបរិយោសាន ។

មួយចំណែកទៀត ទូលព្រះបង្គំជាខ្ញុំទាំងអស់ សូមឧទ្ទិសនូវមគ្គផលដែលសម្រេចឡើងក្នុងពេលនេះ, មួយចំណែកថ្វាយចំពោះសម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចព្រះប្រមុខរដ្ឋ សូមព្រះអង្គបានសម្រេចនូវសម្បត្តិសួគ៌ សម្បត្តិព្រះនិព្វាន ហើយមានព្រះជន្មាយុជានិរយព្រះវស្សា ដើម្បីជាម្លប់ដល់ពុទ្ធបរិស័ទ ប្រជាពលរដ្ឋជាកូនចៅក្នុងកម្ពុជរដ្ឋ, និងមួយចំណែកទៀត ប្រគេនចំពោះសម្ដេចព្រះសង្ឃនាយកជាអម្ចាស់ដែលគង់ជាអធិបតីក្នុងទីនេះ ព្រមទាំងសម្ដេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ, សូមសម្ដេចទាំងពីរព្រះអង្គមាន

ព្រះជន្មាយុយឺនយូរ ដើម្បីជាទីពំនឹងនៃពុទ្ធសាសនិកទាំងអស់ ។

សូមក្រាបបង្គំទូលថ្វាយនៅថ្ងៃពុធ ៩ រោច ខែកត្តិកត្រូវនឹងថ្ងៃទី ៣ ធ្នូ ឆ្នាំ ១៩៤៩ ។

ទូលព្រះបង្គំជាខ្ញុំ **ឈាវ ហ័មអាន**

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ជាតំណាងនៃបុគ្គលិកទាំងអស់ ។

បន្ទាប់ពីសុន្ទរកថានេះមក សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក មានពុទ្ធដីកាតបវិញ ក្នុងព្រះបរមនាមនៃព្រះសព ព្រមទាំងក្នុងនាមព្រះសង្ឃជាសិស្សគណទាំងអស់នៃសព ដើម្បីថ្លែងអំណរគុណនិងសេចក្ដីសរសើរជាឧឡារិក ចំពោះបុគ្គលិក នៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យដែលបេះសាមគ្គីប្រួមគ្នា និងមានចិត្តភក្ដីមករៀបចំពិធីថ្វាយព្រះរាជកុសលក្នុងវេលានេះ ។ សម្ដេចមានពុទ្ធដីកាដោយព្រះកត្រ្តស្ងួតស្ងប់ ថ្លែងបញ្ជាក់ពីទឹកព្រះទ័យនៃព្រះបរមសព ដែលតែងជាប់ជំពាក់នឹងកិច្ចការទាំងអស់របស់ពុទ្ធសាសនបណ្ឌិត្យ មានការតាក់តែងវចនានុក្រមខ្មែរជាដើម រហូតដល់ពេលមានព្រះអាពាធហើយ ក៏នៅតែជាប់ព្រះទ័យនឹងការងារនេះដែរ ។ បន្ទាប់មក សម្ដេចបានប្រសិទ្ធិពរប្រគេននិងជូនចំពោះបុគ្គលិកទាំងព្រះសង្ឃ ទាំងគ្រហស្ថ នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ សូមឲ្យបានប្រកបនឹងជោគជ័យក្នុងការងារបម្រើវប្បធម៌ជាតិនិងព្រះពុទ្ធសាសនា ។

តមក ព្រះសង្ឃ ២០ អង្គក៏ចាប់ចម្រើនព្រះសត្តប្បករណាភិធម្មបង្សុកូល ថ្វាយព្រះបរមសព ។ លុះចប់ព្រះធម៌នេះហើយ បុគ្គលិកទាំងអស់ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ លើកយកទេយ្យទាន ប្រគេនព្រះសង្ឃ ជាកិច្ចបង្ហើយបុណ្យ ។

ពិតមែនតែពិធីនេះ មិនជាធំដុំប៉ុន្មាន ប៉ុន្តែមានអត្ថន័យធំទូលាយវែងឆ្ងាយណាស់ ព្រោះជាការរំលឹកឡើងនូវព្រះកិត្តិគុណដែលមានមកជាច្រើនឆ្នាំហើយ និងជាកំណត់កត់ទុកក្នុងដួងចិត្តនៃជនទាំងអស់ ចំពោះព្រះកិត្តិគុណនេះ តទៅអនាគតពុំអាចរសាយរលុបរលាយបានឡើយ ។



សហជីវិននាយករដ្ឋាភិបាល ថ្លែងវិយោគទុក្ខ តាងនាមបុគ្គលិកទាំងអស់



សហជីវិន ឈាង-ហ័ប-អាន ប្រគេនទេយ្យទាន



សហជីវិន លាង-ហ័ប-អានលើកទេយ្យទានប្រគេនព្រះពុទ្ធាចារ្យ ហ៊ី-ជា
សមាជិកក្រុមជំនុំព្រះត្រៃបិដក ដើម្បីប្រគេនព្រះសង្ឃ



សហជីវិន នាយកវិដ្ឋាហានប្រគេនទេយ្យទាន



បុគ្គលិកវិជ្ជាហាឆប្រណាម្យគោរពបរមសព

# បញ្ជីអត្ថបទដែលបានផ្សាយហើយ
# ក្នុងកម្ពុជសុរិយា ឆ្នាំ ១៩៦៩

## ១- ផ្នែកសាសនា :

| លេខរៀង | នាមអ្នកនិពន្ធ | ចំណងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ១ | ព្រះមហា ប៉ុក សុខ | រឿងសុមនសាមណេរ ភាគ ៨ | ១ |
| ២ | ព្រះសិរីសម្មតិវង្ស ប៉ុណ្ណ សម្ភាជ | អង្គការព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា | ២ |
| ៣ | ព្រះមហា ប៉ុក សុខ | រឿងចន្ទាកេត្តរ | ២ |
| ៤ | ព្រះមហាព្រហ្មុនី ឡុង ណារ៉ និងព្រះធម្មកវីវង្ស គុងឈួន | បករសូត្រ | ៣ |
| ៥ | សម្ដេចព្រះពោធិវង្ស ហួត តាត | ពិធីសម្ពោធព្រះត្រៃបិដក និងពុទ្ធភាសិតខ្លះ ក្នុងបរិនិព្វានសូត្រ | ៤ |
| ៦ | ពុទ្ធសាសនបណ្ឌិត្យ | ឧប្បត្តិហេតុនៃព្រះត្រៃបិដក | ៤ |
| ៧ | ព្រះមុនីកោសល- សូ ហាយ | មហាបរិនិព្វានកថា | ៤ |
| ៨ | លោក ម៉េង ជ្រីវ | សេចក្ដីក្លាហាន | ៥ |

| លេខរៀង | នាមអ្នកនិពន្ធ | បំណងរឿង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ៩ | លោកហេង សំអាន | រឿងសតនបណ្ឌិត | ៥ |
| ១០ | -ដ- | អគ្គសាវគ្គជីវប្រវត្តិ | ៦ |
| ១១ | លោក ប៊ូ ប៉ូ | កម្លាំងនៃស្ត្រី | ៦ |
| ១២ | -ដ- | មជ្ឈិមសីល | ៧ |
| ១៣ | លោក ញ៉ូង សឿង | រឿងឧបគត និងមារ | ៧ |
| ១៤ | លោក ប៊ូ ប៉ូ | មហាសីល | ៨ |
| ១៥ | ព្រះមហា ប៉ាង ខាត | ទស្សនវិជ្ជាពុទ្ធសាសនា | ៥ដល់១១ |
| ១៦ | ភិក្ខុ លាប សារុន | អដ្ឋិកមគ្គកថា | ៩ |
| ១៧ | លោក ប៊ូ ប៉ូ | រឿងបណ្ឌិតសាមណេរ | ១០ |
| ១៨ | លោក ផល ទិត | រឿងគាមណិចន្ទ | ១១ |
| ១៩ | - ផេង ជ្រីវ | រូបជីវិត មច្ចានំ នាមគោត្ត និ ជីវិត | ១២ |

## ២- វិជ្ជាអក្សរសាស្ត្រ :

| | | | |
|---|---|---|---|
| ១ | សហ. ផេង-ជ្រីវ | អំពីពន្លឺព្រះអាទិត្យ | ១ |
| ២ | ព្រះភិក្ខុ ប៉ាង ខាត់ | វេទានុក្រមសំស្ក្រឹត ខ្មែរ | ១ដល់១២ |
| ៣ | ឧកញ៉ា នូ កន | រឿងសាមកុក | ១ដល់១២ |
| ៤ | អ្នកស្រី ពេជ សល | រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ | ១ដល់១២ |

| លេខរៀង | នាមអ្នកនិពន្ធ | បំណងរឿង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ៥ | សហ. លាង ហ៍បអាន | ល្បងសិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ | ១ |
| ៦ | សហ. ឌឹក គាម | សិលាចារឹកអង្គជុំទឹក | ២ |
| ៧ | សហ. លី ធាមតេង | ការកិច្ចនៃអ្នកនិពន្ធក្នុងការសាងជាតិ | ២ |
| ៨ | សហ. ញ៉ុក ថែម | ជីវប្រវត្តិរបស់លោក ញ៉ុក ថែម | ២ |
| ៩ | សហ. ស្ដើង ធួរ | អ្នកតាពោធិសាក្យ | ២ |
| ១០ | សហ. ព្រួច កុម | រឿងសូត្រសាច់អកកំបោរប្រាក់ | ៣ |
| ១១ | ព្រះមហាព្រហ្មមុនី ឡុង ណារ ទីងព្រះធម្មកវីវង្សត្រុង ឈួន | ជីវប្រវត្តិសម្តេចមង្គល ទេពាចារ្យ កែវ អ៊ុប | ៣ |
| ១២ | សហ. លី ធាមតេង | ពិធីដង្ហែក្បួនព្រះត្រ័យបិដក | ៤ |
| ១៣ | សហ. ឌឹក គាម | វប្បធម៌ខ្មែរ | ៥ |
| ១៤ | - ហ៊ែល សុំផា | របៀបរៀបចំខាងតុលាការ | ៦ |
| ១៥ | - ព៉យ ប៊ិក | ការប្រយុទ្ធ និង មធ្យោបាយ ដោះស្រាយសេចក្តីល្ងង់ | ៦ |
| ១៦ | - ឌឹក គាម | សិលាចារឹកព្រះគោ | ៦ |
| ១៧ | - ញ៉ុង សឿង | ពាក្យកាព្យពគ្រីបតុម្ភ | ៧ |
| ១៨ | - ហ៊ុន សារី | ប្រវត្តិភូមិក្បាលអ្នក ឬ ប៊ូអង់ | ៧ |

| លេខរៀង | នាមអ្នកនិពន្ធ | បំណងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ១៩ | សហ លី ឆាមតេង | ល្បើកអក(របស់លោកបម្រើឧទ័យ) | ៣ ដល់ ១១ |
| ២០ | - ឌឹក គាម | កវីទ្រូបណ្ឌិត | ៧ |
| ២១ | - លី ឆាមតេង | ទំនុកច្រៀងបុរាណខ្មែរ | ៩ |
| ២២ | ព្រះមហាប៉ាង ខាត | វប្បធម៌សំស្ក្រឹត | ៩ |
| ២៣ | លោក ប៉ាន តេង | សប្បុរិសធម៌ ៧ ប្រការ(ពាក្យកាព្យ) | ៩ |
| ២៤ | លោក ផេង ជ្រីវ | ការផ្លាស់ប្តូរប្រពៃណីក្នុងរឿងរកគូស្រករ | ១០ |
| ២៥ | - ញ៉ុង សឿង | ចម្រៀងបញ្ចសីខគន្ធព្វទេវបុត្រ | ១០ |
| ២៦ | — លី ឆាមតេង | កម្រងទំនុកចម្រៀងបុរាណខ្មែរ | ១០ |
| ២៧ | — ហប រិត | អំពីសត្វចិញ្ចឹម ( សត្វគោ ) | ១២ |
| ២៨ | អ្នកស្រី ពេជ សល់ | ប្រវត្តិក្រុងកេងហៅក្រុងយ៉ុយនៅកំពង់ចាម | ១២ |

## ៣-ផ្នែកកំណត់-ប្រវត្តិការណ៍

| | | | |
|---|---|---|---|
| ១ | | បុតហ្វាយអគ្គនាយកដ្ឋាននៃក្រសួងងាងា ក្នុងព្រះបរមរាជវាំង | ១ |

| លេខរៀង | នាមអ្នកនិពន្ធ | ចំណងជើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ២ | ការិយាល័យ-ទំនៀមទម្លាប់ | ប្រកាសប្រឡងទំនៀមទម្លាប់ខ្មែរ | ១ |
| ៣ | សហ.លី-ធាមតេង | អនុស្សាវរីយ៍មហាសន្និបាតមន្ត្រីសង្ឃលើកទី២៤ | ១ |
| ៤ | ង.ឌុ.អ៊ុំហុងសាធ | សាភបរលេខ ២០ កជ ស្ដីពីសាមគ្គីធម៌ | ២ |
| ៥ | ភិក្ខុ ប៊ុន-ចុល | បុណ្យបូជាសពព្រះតេជព្រះគុណង៉ួន ជន អាចារ្យកម្មដ្ឋាន | ៥ |
| ៦ | | ពិធីប្រគល់ព្រះត្រៃបិដកខ្មែរ ចំពោះមជ្ឈមណ្ឌលព្រះពុទ្ធសាសនា នៅប្រទេសអាល្លឺម៉ង់ខាងកើត | ៥ |
| ៧ | សហ.លី-ធាមតេង | ពិធីនមស្ការព្រះសក្យមុនីចេតិយ | ៥ |
| ៨ | | សេចក្ដីអំពាវនាវពីរដ្ឋាភិបាលពុទ្ធសាសនបណ្ឌិត្យ | ៥ |
| ៩ | | ប្រកាសប្រឡងប្រជែង ទំនៀមទម្លាប់ខ្មែរ ឆមាសទី ២ ១៩៦៩ | ៦ |

| លេខរៀង | នាមអ្នកនិពន្ធ | បំណងរឿង | លេខទស្សនាវដ្តី |
|---|---|---|---|
| ១០ | សហ. ម៉ែន ទន់ | ប្រវត្តិភូមិនិងកោះនានានៅខែត្រកោះកុង | ៦ដល់៨ |
| ១១ | ទំនៀមទម្លាប់ | ប្រកាសលទ្ធផលប្រឡងទំនៀមទម្លាប់ ឆមាសទី១ | ៧ |
| ១២ | សហ. លី-ធាមតេង | ពិធីបូជាសពព្រះសុមេធាវង្ស ព្រហ្ម ប៉ុល | ៨ |
| ១៣ | -ដ- | ពិធីប្រគេនព្រះរាជអំណោយសម្តេចជុន | ៨ |
| ១៤ | | ចុតហ្មាយសហ. ឌឹ ទូច រដ្ឋលេខាធិការធម្មការ | ១០ |
| ១៥ | គណៈកម្មការបុណ្យ | ព្រះរាជជីវប្រវត្តិនៃសម្តេចព្រះសង្ឃរាជ | ១០ |
| ១៦ | ក្រសួងធម្មការ | ព្រះរាជក្រិត្យតែងតាំងសម្តេចព្រះសុមេធាធិបតីសង្ឃនាយក ហួត តាត | ១១ |
| ១៧ | ក្រសួងសង្ឃនាយក | ព្រះសង្ឃដីកា នៃសម្តេចព្រះសង្ឃនាយកគណៈមហានិកាយស្តីពីការប្រួបប្រួមសាមគ្គី | ១២ |

| លេខរៀង | នាមអ្នកនិពន្ធ | បំណងដើង | លេខទស្សនាវដ្ដី |
|---|---|---|---|
| ១៨ | លោក លី ធាមតេង | បុគ្គលិកវិជ្ជាឋានពុទ្ធសាសន-បណ្ឌិត្យគោរពព្រះបរមសពសម្ដេចព្រះសង្ឃរាជ | ១២ |